ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# សិក្សាសង្គម



## ភូមិវិទ្យា

៩





គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាសង្គម

## ថ្នាក់ទី ៩

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៥៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោក អេង វ៉ាត់ | លោក ស្រ៊ុន ណាត្រី |
| | លោក មួង សុផាត | លោកស្រី មាស សុក្ខន |
| | លោក តែម គីមតុន | លោកស្រី បែន នាង |
| **អ្នកវាយអត្ថបទ** | លោក ហៃ វីរៈ | លោក ប៉ាន់ ជាតិ |
| **វិចិត្រករ** | លោក ឡុង សុវណ្ណា | |
| **អ្នករៀបរៀង** | លោក លឹម ហ៊ិន | លោក ខាត់ ធី |
| **រចនាទំព័រ** | លោក គង់ ចិត្រា | |
| **អ្នកឯកទេស** | លោកបណ្ឌិត នៅ ស៊ុន | |
| **គណៈកម្មការពិនិត្យ** | លោកស្រី ប៉ាង ចិន្ដា | លោកស្រី ព្រាប សុភួង |
| | លោក ភុក ប៉ាវ | លោកស្រី ស្វាយ ធឿម |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ១៥៤៨ អយក.ប្រក. ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ២០១៦

ISBN 9-789-995-001-339

# អារម្ភកថា

សៀវភៅសិក្សាសង្គមថ្នាក់ទី១ នេះ គណៈកម្មការនិពន្ធបានរៀបចំចងក្រងឡើងដោយផ្អែកលើកម្មវិធីសិក្សាថ្មី (2009) របស់ក្រសួងអប់រំ យុវជន និងកីឡា ។ នៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាសិក្សាសង្គម មានមុខវិជ្ជារងចំនួនបួន ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា និងគេហវិទ្យា ។

ខ្លឹមសារមេរៀនដែលមានក្នុងសៀវភៅនេះនឹងជួយប្អូនៗឱ្យមានចំណេះដឹងបន្ថែមទៀតទៅលើធនធានធម្មជាតិ រ៉ែ តំបន់ទេសចរណ៍ សេដ្ឋកិច្ចប្រទេសរបស់ខ្លួន និងប្រទេសមួយចំនួនក្នុងតំបន់និងបានដឹងពីប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួន ប្រទេសក្នុងតំបន់និងលើពិភពលោក ហើយនឹងមានចំណេះដឹងបន្ថែមទៀតទៅលើចំណងទាក់ទងជាមួយអ្នកជទៃ និងចំណងទាក់ទងជាមួយសហគមន៍ ពិសេសទៅទៀតក៏បានដឹងពីវិជ្ជាធ្វើម្ហូប វិជ្ជាកាត់ដេរ ប៉ាក់ និងសម្លៀកបំពាក់ជាដើម ។

គ្រប់មេរៀនដែលមាននៅក្នុងសៀវភៅនេះ គឺមានទម្រង់ដូចៗគ្នាទាំងអស់ដូចជាការកំណត់វត្ថុបំណងនៃមេរៀនសម្រាប់ឱ្យប្អូនៗដឹងពីអ្វីដែលត្រូវសិក្សាក្នុងមេរៀននីមួយៗ ពិសេសនៅចុងបញ្ចប់នៃជំពូកនីមួយៗមានតេស្តបញ្ចប់ជំពូក សម្រាប់វាយតម្លៃលើចំណេះដឹងនៅពេលរៀនចប់ជំពូកនីមួយៗ ។ តាមរយៈខ្លឹមសារមេរៀនដែលមាននៅក្នុងសៀវភៅនេះ ប្អូនៗនឹងទទួលបានចំណេះដឹងបំណិន ឥរិយាបថ ការសង្កេតរូបភាព ការបញ្ចេញមតិយោបល់ ការពិភាក្សាជាដៃគូ ឬជាក្រុម និងតាមការសិក្សាស្រាវជ្រាវជាដើម ។ ជាមួយនេះដែរការរៀបចំសៀវភៅនេះក៏មានការចូលរួមផ្ដល់យោបល់ កែលម្អពីសំណាក់លោកគ្រូ អ្នកគ្រូនៅតាមបណ្ដាខេត្តក្រុងមួយចំនួនផងដែរ ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅសិក្សាសង្គមថ្នាក់ទី១នេះនឹងក្លាយជាមិត្តដ៏ល្អរបស់ប្អូនៗសិស្សានុសិស្សជាក់ជាមិនខាន ។ ទន្ទឹមគ្នានោះដែរ គណៈកម្មការនិពន្ធរីករាយនឹងទទួលយករាល់មតិកែលម្អពីសំណាក់ លោកគ្រូ អ្នកគ្រូ និងគ្រប់មជ្ឈដ្ឋាន ។

គណៈកម្មការនិពន្ធ

ជំពូក 1 ៖ ប្រទេសកម្ពុជា (ភូមិវិទ្យា)
1. ធនធានរ៉ែនៅកម្ពុជា....................2
2. ភោគទ្រព្យទេសចរណ៍ធម្មជាតិនៅកម្ពុជា...10
3. សេដ្ឋកិច្ចកម្ពុជា....................22
ជំពូក 2 ៖ ប្រទេសមួយចំនួននៃអាស៊ី
1. ប្រទេសចិន....................38
2. ប្រទេសឥណ្ឌា....................48
3. ប្រទេសម៉ាឡេស៊ី....................56
4. ប្រទេសព្រុយណេ....................64
5. ប្រទេសមីយ៉ាន់ម៉ា....................72

# ជំពូកទី 1 ប្រទេសកម្ពុជា



*រមណីយដ្ឋានទឹកធ្លាក់ភ្នំគូលែន (សៀមរាប)*

កម្ពុជាជាប្រទេសមួយនៃអាស៊ីអាគ្នេយ៍ដីគោកស្ថិតនៅលើឧបទ្វីបឥណ្ឌូចិនដែលជាទ្រនទ្វីប និងស្ថិតនៅក្រោមឥទ្ធិពលអាកាសធាតុត្រូពិចមូសុងក្តៅហើយសើម ។ ដោយសារតែប្រទេសកម្ពុជាស្ថិតនៅលើទ្រនទ្វីបចាស់ ទើបប្រទេសនេះអាចគេចផុតពីគ្រោះរញ្ជួយដី និងបន្ទុះភ្នំភ្លើង ។ អាកាសធាតុត្រូពិចមូសុង អនុគ្រោះខ្លាំងដល់ការលូតលាស់រុក្ខជាតិ ពិសេសព្រៃឈើ និងដំណាំត្រូពិច ។

ម្យ៉ាងទៀត សណ្ឋានដី អាកាសធាតុ និងផ្លូវទឹកកម្ពុជាបានបង្កើតឱ្យមានរមណីយដ្ឋានធម្មជាតិដ៏ត្រកាលសម្រាប់អភិវឌ្ឍវិស័យទេសចរណ៍ ។ លើសពីនេះ តាមប្រវត្តិធរណីវិទ្យា គេអាចសន្និដ្ឋានបានថា ប្រទេសកម្ពុជាអាចមានកំណាប់រ៉ែច្រើនប្រភេទដែលជាធនធានសំខាន់សម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

ក្នុងជំពូកនេះ អ្នកនឹងបានសិក្សាពីធនធានធម្មជាតិ ការប្រើប្រាស់ ផលប៉ះពាល់លើបរិស្ថាន យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ពិសេសធនធានភោគទ្រព្យទេសចរណ៍ធម្មជាតិ និងសេដ្ឋកិច្ចកម្ពុជា ។

# 1 ធនធានរ៉ែនៅកម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីធនធានរ៉ែនៅកម្ពុជា មណ្ឌលរ៉ែ សន្ទស្សន៍រ៉ែ រ៉ែប្រេងកាត ផលប៉ះពាល់ទៅលើបរិស្ថាន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។

ប្រទេសកម្ពុជាយើងមានធនធានធម្មជាតិសំខាន់ៗច្រើនប្រភេទដូចជា ធនធានព្រៃឈើ ធនធានដី ធនធានទឹក ធនធានរ៉ែជាដើម ។ ក្នុងមេរៀននេះ យើងនឹងលើកយកធនធានរ៉ែមកធ្វើការសិក្សាតែប៉ុណ្ណោះ ។

## 1. ប្រវត្តិនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវផ្នែកធរណីវិទ្យានៅកម្ពុជាយើង បានចាប់ផ្ដើមតាំងពីឆ្នាំ 1866-1867 ក្រោមបេសកកម្មរបស់លោក កាញ៉េ (ជនជាតិបារាំង) ។ សមាជិកម្នាក់នៃបេសកកម្មនេះ គឺលោក ស៊ូប៊ែ(ជនជាតិបារាំង) ។ ស្នាដៃរបស់លោកឆ្នាំ 1873 ជាសំយោគយ៉ាងត្រួសៗពីធរណីវិទ្យាប្រទេសកម្ពុជា ។ ក្រោយមកស្របនឹងកំណើតរបស់ក្រសួងធរណីឥណ្ឌូចិន កិច្ចការលើដីផ្ទាល់ និងបន្ទប់ពិសោធន៍ជាច្រើនក៏បានចាប់ផ្ដើមបង្កើតឡើងសម្រាប់ធរណីវិទ្យាទូទៅ និងផូស៊ីលវិទ្យា សម្រាប់សិលាវិទ្យាស័កទី 4 និងបុរេប្រវត្តិ ។

ពីឆ្នាំ 1961 ដល់ 1970 ការិយាល័យផ្នែកស្រាវជ្រាវធរណី និងរ៉ែដែលមាននៅប្រទេសកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវរ៉ែ និងរូបធាតុក្រោមដីផ្សេងៗទៀត ព្រមទាំងគូសផែនទីធរណីពេញផ្ទៃប្រទេសកម្ពុជាចំនួន 17 សន្លឹកតាមមាត្រដ្ឋាន 1/200 000 ទុកប្រើការជាបណ្ដោះអាសន្នពីឆ្នាំ 1966 ដល់ 1970 ។ នៅចុងឆ្នាំ 1970 អគ្គស្នងការដ្ឋានទូទៅនៃការស្រាវជ្រាវរ៉ែ បានប្រមូលផ្ដុំសកម្មភាពធរណី និងរ៉ែនៃប្រទេសដោយមានជំនួយពីអ្នកបច្ចេកទេសកម្ពុជា និងបរទេសរួមគ្នា ។

ពីឆ្នាំ 1970 ដល់ 1993 ការសិក្សាស្រាវជ្រាវផ្នែកនេះត្រូវអាក់ខានដោយសារប្រទេសកម្ពុជាជួបនិងវិបត្តិសង្គ្រាមរ៉ាំរ៉ៃ ។

បច្ចុប្បន្ន គេឃើញមានក្រុមហ៊ុនបរទេសមួយចំនួន បានចូលមករកស៊ីនៅកម្ពុជាខាងការរុករក និងទាញយករ៉ែមាស ដែក និងប្រេងកាត ។

## 2. មជ្ឈមណ្ឌលរ៉ែ

រ៉ែដែលធ្លាប់បានធ្វើអាជីវកម្មជាយូរមកហើយមាន 6មណ្ឌលដូចខាងក្រោម :

- មណ្ឌលប៉ៃលិន មានត្បូងមានតម្លៃគឺ ទទឹមកណ្ដៀង និងត្បូងមានតម្លៃផ្សេងៗទៀត ។ នៅទីនោះពីដើមការជីកយករ៉ែប្រព្រឹត្តទៅដោយប្រើកម្លាំងកម្មករ និងដោយដៃ ។ នៅចុងសម័យសង្គ្រាមក្នុងស្រុក គេឃើញអាជីវកម្មត្បូង ប្រព្រឹត្តទៅដោយគ្រឿងចក្រដែលជាហេតុនាំឱ្យធនធានរ៉ែប្រភេទនេះស្ទើរតែវិនាសហិនហោចអស់ ។



គ្រឿងចក្រជីកកកាយយករ៉ែត្បូងនៅប៉ៃលិន

- មណ្ឌលបកែវ ស្ថិតក្នុងខេត្តរតនគិរីមានត្បូងខៀវ និងមាស ។ សព្វថ្ងៃក្រុមហ៊ុនរុករករ៉ែមាសមួយមកពីប្រទេសអូស្ត្រាលីឈ្មោះ សាវធឺនហ្គោលលីមីធីត (Southern Gold Limited) បានទទួលការអនុញ្ញាតឱ្យធ្វើការរុករករ៉ែ រ៉ែមាស និងលោហធាតុក្នុងមូលដ្ឋានចំនួនប្រាំពីរកន្លែងប៉ែកឦសាននៃប្រទេសកម្ពុជា ។





សកម្មភាពនៃការរុករករ៉ែ

- មណ្ឌលពោធិ៍សាត់ មានរ៉ែថ្មកែវនៅភ្នំតាសាយ ។ ថ្មកែវមានច្រើនពណ៌ដូចជា បៃតងខ្ចី ក្រហម ខ្មៅ ត្នោតចាស់ឬមានឆ្នូតប្រើសម្រាប់រចនាវត្ថុសិល្បៈនានា ។



ចម្លាក់ធ្វើពីថ្មកែវនៅខេត្តពោធិ៍សាត់

- មណ្ឌលកំពង់ធំ មានរ៉ែដែកនៅភ្នំដែក និងរ៉ែមាសកប់ក្នុងដីល្បាប់ សំណប៉ាហាំងពិសេសនៅជុំវិញភ្នំជីនិងភ្នំលៀង និងត្បូងសម្រាប់ធ្វើគ្រឿងអលង្ការ ។ តំបន់នេះសព្វថ្ងៃស្ថិតនៅក្នុងទឹកដីនៃខេត្តព្រះវិហារ ។ រ៉ែដែកនៅទីនោះមានទម្រង់ជាម៉ាញេទិក លីម៉ូនីត ស៊ីដេរីត ដែលជនជាតិកួយបានយកមកប្រើប្រាស់ផលិតសម្ភារៈ និងអាវុធ(ដាវ លំពែង...) ។ ក្នុងពេលកន្លងមក គេឃើញមានក្រុមហ៊ុនមួយរបស់ចិនកំពុងធ្វើការសិក្សាស្រាវជ្រាវរ៉ែដែកនៅតំបន់ភ្នំដែក (ខេត្តព្រះវិហារ) ។



រោងចក្រផលិតស៊ីម៉ង់ត៍នៅខេត្តកំពត

- មណ្ឌលកំពត មានកំណប់រ៉ែថ្មកំបោរ និងផូស្វាត ។ កាលពីមុនសង្គ្រាមឆ្នាំ 1970 ប្រទេសកម្ពុជាមានរោងចក្រស៊ីម៉ង់ត៍មួយនៅចក្រីទីង និងរោងចក្រជីផូស្វាតមួយនៅទូកមាស ។ រោងចក្រទាំងពីរត្រូវ ខកខានលែងមានដំណើរការក្នុងពេលសង្គ្រាម និងវិបត្តិនយោបាយជាងពីរទសវត្សរ៍នៅកម្ពុជា ។ សព្វថ្ងៃ មានក្រុមហ៊ុនស៊ីម៉ង់ត៍ចំនួន5 ផលិតស៊ីម៉ង់ត៍នៅលើទឹកដីនៃខេត្តកំពតដោយប្រើប្រាស់ថ្មកំបោរនៅទីនោះ ។ ក្រុមហ៊ុនទាំងនោះមានក្រុមហ៊ុនឧស្សាហកម្មស៊ីម៉ង់ត៍អាស៊ីចំកាត់ (Asia Cement Ind.Ltd) នៅប៉ែកខាងកើតទូកមាស ក្រុមហ៊ុនស៊ីម៉ង់ត៍ថៃប៊ុនរ៉ុងចំកាត់ (Thai Bun Roong Cement Co.Ltd) នៅភ្នំល្អាង ក្រុមហ៊ុនស៊ីម៉ង់ត៍អង្គរមាសចំកាត់(Golden Angkor Cement Ltd)របស់ចិននៅតំបន់កំពង់ត្រាច ក្រុមហ៊ុនឧស្សាហកម្មស៊ីម៉ង់ត៍ចក្រីទីងកម្ពុជាចំកាត់(Cambodia Chakrey Ting Cement Factory Ltd) នៅតំបន់បាត់ដំបង និងក្រុមហ៊ុនស៊ីម៉ង់ត៍កំពតចំកាត់ "ក្រុមហ៊ុនចម្រុះរវាងស្យាមស៊ីម៉ង់ត៍គ្រុប (Siam Cement Group) និងខូវជូលីគ្រុប(Khaou Chuly Group)" ។

- មណ្ឌលបាត់ដំបង មានថ្មកំបោរ និងផូស្វាត ។ ប្រជាជនយើងបានប្រើថ្មកំបោរយកមកដុតធ្វើកំបោរសសម្រាប់លាបផ្ទះ ។ ចំណែករ៉ែផូស្វាត ប្រជាជនយើងគ្រាន់តែយកមកកិនធ្វើទៅជាជីសម្រាប់ប្រើប្រាស់ក្នុងកសិកម្មប៉ុណ្ណោះ ។

## 3. សន្ទស្សន៍រ៉ែ

ក្រៅពីនេះ ប្រទេសកម្ពុជានៅមានសន្ទស្សន៍រ៉ែផ្សេងៗទៀតជាច្រើនដូចជា ត្បូងថ្ម(នៅកោះកុង គិរីរម្យ ក្រុងព្រះសីហនុ ស្ទឹងត្រែង និងរតនគិរី) ទង់ដែង(នៅក្រូចឆ្មារ ស្ទឹងត្រែង រតនគិរី ...) ស្ពាន់ធ័រ(ក្រុងព្រះសីហនុ ក្រចេះ ...) បុកស៊ីត(ឆ្លូងលើ បាត់ដំបង ...) និងម៉ង់កាណែស ម៉ាញេស្យូម ក្វាត ប្រាក់(ស្ទឹងត្រែង ព្រះវិហារ ...) ។

ប្រទេសកម្ពុជាសម្បូរដោយថ្មសំណង់ដូចជា ថ្មក្រៃ ថ្មបាសាល់ ថ្មក្រានីត ថ្មបាយក្រៀម ដីឥដ្ឋ ក្រួស ខ្សាច់ ... ។ ចំណែកកំណប់រ៉ែប្រេងកាត និងឧស្ម័នធម្មជាតិមាននៅខ្ពង់រាបបាតសមុទ្រកម្ពុជាហើយក៏អាចមានផងដែរ នៅតំបន់បឹងទន្លេសាប និងតំបន់ខ្ពង់រាបខាងកើត ។

## 4. ការរុករករ៉ែប្រេងកាត

ការរុករករ៉ែប្រេងកាត នៅខ្ពង់រាបបាតសមុទ្រខ្មែរបានប្រព្រឹត្តទៅក្នុងសម័យសាធារណរដ្ឋខ្មែរម្តងដែរ តែត្រូវរំខានដោយភ្លើងសង្គ្រាម ។ ចាប់ពីឆ្នាំ 1991 មកមានក្រុមហ៊ុនបី ធ្វើសកម្មភាពរុករកប្រេងកាត និងឧស្ម័នក្នុងដែនសមុទ្រកម្ពុជា ៖

- ក្រុមហ៊ុន **អ៊ិនធ័រប្រាយអយ** រុករកនៅប្លុកទី 1 (4 700 $km^2$) ប្លុកទី 2 (4 900 $km^2$) ហើយបានខួងដំបូងក្នុងប្លុកទី 1 ក្នុងជម្រៅ 3 952 m និងមានចម្ងាយប្រហែល 170 km ភាគនិរតីខេត្តព្រះសីហនុ ។ តាមការប៉ាន់ប្រមាណថាប្លុកទី 1 នេះនឹងផ្តល់ឧស្ម័ន 4.7 លានគូបភីត និងប្រេងកាតនៅ 180 ធុងក្នុងមួយថ្ងៃ (1 ធុង = 159 លីត្រ 1 គូបភីត = 0.305 $m^3$) ។
- ក្រុមហ៊ុន **កាំប៉ិច** ខួងអណ្តូងអប្សរា 1 ក្នុងជម្រៅ 3 308m ។ តាមការប៉ាន់ប្រមាណអណ្តូងអប្សរា 1 នឹងផ្តល់ឧស្ម័ន 73 200 គូបភីត និងប្រេងនៅ 244 ធុងក្នុងមួយថ្ងៃ ។ ឯអណ្តូងទេវតា 1 ខួងក្នុងជម្រៅ 3 207m ឃើញថាគ្មានប្រេងទេ ។ អណ្តូងទាំងពីរនេះស្ថិតនៅក្នុងប្លុកទី 3(3 660$km^2$) ។
- ក្រុមហ៊ុន **ព្រីមីញេរ៉អយ** (Premier Oil) ខួងក្នុងប្លុកទី 4 (4 015$km^2$) ឈ្មោះអណ្តូងកោះតាង 1 ក្នុងជម្រៅ 3 867m នៅឆ្នាំ 1994 ។ តាមការប៉ាន់ប្រមាណប្លុកនេះផ្តល់ឧស្ម័ន 1.3 លានគូបភីត និងប្រេងនៅ 1 180 ធុងក្នុងមួយថ្ងៃ ។

ដោយក្រុមហ៊ុនទាំងបីខាងលើបញ្ឈប់ការរុករក ទើបនៅឆ្នាំ 1997 ក្រុមហ៊ុនអាយ៍ដេមមីតស៊ូ (Idemitsu) ចុះកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលរុករកក្នុងប្លុកទី 1 និងប្លុកទី 4 ហើយខួងអណ្តូងកោះព្រីង 1 ក្នុងអំឡុងខែមេសា 1998 តែគ្មានលទ្ធផល ។ ក្រុមហ៊ុននេះ ក៏បោះបង់ចោលការងាររុករករបស់ខ្លួនទៀត ។

ថ្ងៃទី 25 មីនា 1999 ក្រុមហ៊ុន វូតសាយ (Woodside) របស់អូស្ត្រាលី បានចុះកិច្ចព្រមព្រៀងមួយដើម្បីសិក្សាឡើងវិញលើទិន្នន័យដែលមានស្រាប់នៅប្លុកទី 1, 2, 3, 4 និង 7 ព្រមទាំងខួងអណ្តូងចំនួន 8 កន្លែង ។ ក្រុមហ៊ុននេះមានជំនឿថានឹងទទួលបានជោគជ័យ ព្រោះគេប្រើបច្ចេកទេសទំនើបបំផុត តែលទ្ធផលហាក់ដូចជាស្ថិតនៅឆ្ងាយនៅឡើយ ។

កាលពីឆ្នាំ 2005 មហាក្រុមហ៊ុនប្រេង សឺវ៉ុង (The Oil Giant Chevron) ប្រកាសថា បានរកឃើញកំណប់ប្រេងដ៏ធំនៅក្នុងដែនសមុទ្រកម្ពុជា ។ មន្ត្រីខាងថាមពលជាតិបានប្រកាសថា ផលិតកម្មប្រេង និងឧស្ម័ននេះអាចចាប់ផ្តើមនៅឆ្នាំ 2011 ។ រាជរដ្ឋាភិបាលកម្ពុជាមានសុទិដ្ឋិនិយមថា រ៉ែប្រេងកាតយើងអាចជាជំនួយដ៏រឹងមាំក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិ ។

ក្រៅពីនេះគេឃើញមានក្រុមហ៊ុនផ្សេងៗទៀតដូចជា ៖

- ប៊ីអេចភី ប៊ីលីតុន (BHP Billiton) និងមិតស៊ូប៊ីស៊ីគ្រុប (Mitsubishi Group) ធ្វើអាជីវកម្ម បុកស៊ិតនៅខេត្តមណ្ឌលគិរី ។
- ក្រុមហ៊ុនកូរ៉េឈ្មោះខេណឺខិច រកឃើញអណ្តូងរ៉ែ ស័ង្កសី 2 កន្លែង ដែកម៉ង់កាណែស 3 កន្លែង និងរ៉ែត្បូង 3 កន្លែង ។
- គេរកឃើញរ៉ែត្បូងថ្មក្នុងតំបន់ពីរនៅភាគខាងជើងនៃប្រទេសកម្ពុជា ។

## 5. ផលប៉ះពាល់នៅលើបរិស្ថាន

ជាទូទៅ អាជីវកម្មរ៉ែតែងតែនាំមកនូវផលប៉ះពាល់ដល់បរិស្ថាន បើមិនច្រើនក៏តិចតួចដែរ ដូចជាបរិមាណរ៉ែកាន់តែចុះថយទៅៗ រហូតដល់អស់លែងមានទៀត ។ នេះជាផលប៉ះពាល់ផ្ទាល់ទៅលើកំណប់រ៉ែ តែផលប៉ះពាល់ទៅលើបរិស្ថានមានច្រើនបែបច្រើនយ៉ាងណាស់ ។

*ឧទាហរណ៍ :* អាជីវកម្មរ៉ែត្បូងនៅប៉ៃលិន ៖

- ដោយសារការធ្វើអាជីវកម្មដែលប្រើគ្រឿងចក្រ រ៉ែត្បូងត្រូវរេចរិលអស់ទៅយ៉ាងឆាប់រហ័ស ហើយមិនអាចកើតមានឡើងវិញទៀតទេ ។
- ការរុករករ៉ែនាំឱ្យមានការបាត់បង់ផលព្រៃឈើ ព្រោះក្នុងការរុករកគេត្រូវឈូសឆាយយកព្រៃឈើចេញ ដើម្បីជីកកាយឱ្យដល់ស្រទាប់រ៉ែ ។
- ដីស្រទាប់លើដីមានជីជាតិ ត្រូវបាត់បង់ដោយការឈូសឆាយ ដីស្រទាប់ក្រោមដែលជាសិលាត្រូវត្រឡប់មកលើផ្ទៃដី ដែលបង្កការលំបាកដល់ការប្រើប្រាស់ដី ។
- ដីគ្មានគម្របព្រៃឈើងាយរងសំណឹក ដោយទឹកភ្លៀងហូរច្រោះ ខ្សោះជីជាតិ ខូចគុណភាព ។
- ការរែងលាងរ៉ែ នាំឱ្យទឹកស្ទឹង ទន្លេល្អក់ ប៉ះពាល់ដល់សុខភាពប្រជាជននិងជីវិតសត្វក្នុងទឹក ។ ទឹកល្អក់នេះ ហូរចាក់ទៅក្នុងបឹងទន្លេ ហើយកករដីធ្លាក់បង្កជាល្បាប់ដែលធ្វើឱ្យបឹងទន្លេកាន់តែរាក់ទៅៗ ជាហេតុនាំឱ្យប៉ះពាល់ដល់ជីវចម្រុះនៃបឹង ។

- ផ្សែងគ្រឿងចក្រ ការបាត់បង់ព្រៃឈើ ជាកត្តាបង្កើនឧស្ម័នពុល គឺឧស្ម័នកាបូនិចទៅក្នុងបរិយាកាស រួមចំណែកក្នុងការបំពុលបរិយាកាស និងបង្កើនកម្តៅផែនដី ។
- សូរសំឡេងគ្រឿងចក្រ រំខានដល់ការរស់នៅរបស់សត្វព្រៃ ពោលគឺសត្វព្រៃភ័យខ្លាច ហើយផ្លាស់ទីរស់នៅ ជួនកាលឆ្លងដែនទៅរស់នៅក្នុងព្រៃនៃប្រទេសជិតខាង ។ នេះគឺជាការខាតបង់មួយយ៉ាងសំខាន់ ។




*ហេតុប៉ះពាល់បរិស្ថាននៃអាជីវកម្មរ៉ែ*

ដោយសារតែផលប៉ះពាល់ទាំងនេះ តំបន់ប៉ៃលិនសព្វថ្ងៃបានប្រែក្លាយទៅជាទឹកដីអភិវឌ្ឍផ្នែកកសិកម្ម គឺទៅជាចម្ការដំណាំសណ្តែកបាយ សណ្តែកសៀង ពោត និងឈើហូបផ្លែ... ផ្នែកទីផ្សារ ហើយក៏ក្លាយជាច្រកមួយសម្រាប់នាំទំនិញចេញនិងចូល ហើយក៏ជាផ្នែកទីផ្សារទេសចរណ៍ផងដែរ ព្រោះមានកាស៊ីណូ ឬបនល្បែងសម្រាប់ភ្ញៀវទេសចរបរទេសមកលេងកម្សាន្ត ។

## ៦. យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

ការគ្រប់គ្រងដោយនិរន្តរភាព មានន័យថាការគ្រប់គ្រងធនធានធម្មជាតិដើម្បីផ្តល់នូវអាហារថាមពល និងវត្ថុធាតុដើមដល់មនុស្សទាំងអស់ដោយមិនធ្វើឱ្យខូចខាតផលប្រយោជន៍មនុស្សជំនាន់ក្រោយ និងដោយគ្មានបន្សល់ទុកនូវការបំផ្លិចបំផ្លាញបរិស្ថាន ។

និរន្តរភាពនៃការអភិវឌ្ឍ មានន័យថាការធ្វើឱ្យរីកចម្រើនប្រព្រឹត្តទៅជាចង្វាក់ជាប់ៗគ្នារៀងទៅ ។ ចំណែកយុទ្ធសាស្ត្រនៃការអភិវឌ្ឍ គឺជាវិធីសាស្ត្រឬមធ្យោបាយទាំងឡាយដែលត្រូវប្រើសម្រាប់ធ្វើឱ្យការអភិវឌ្ឍមានដំណើរការទៅប្រកបដោយជោគជ័យជារៀងរហូត ។

ជាទូទៅ យុទ្ធសាស្ត្រនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព គឺការប្រើប្រាស់ធនធានធម្មជាតិមកជំនួស និងការកែច្នៃជាថ្មី ដោយរក្សាជាច់ខាតនូវលំនឹងបរិស្ថាន និងការធ្វើឱ្យអ្នកដែលនៅជុំវិញតំបន់អភិវឌ្ឍន៍បានទទួលផលពីការអភិវឌ្ឍថែមទៀតផង ។ នេះជាមេរៀនមួយពីការជីកយកត្បូងនៅតំបន់ប៉ៃលិន ។ ដោយសារសង្គ្រាម ទើបតំបន់ប៉ៃលិនគ្មានការគ្រប់គ្រងល្អក្នុងការធ្វើអាជីវកម្ម ត្បូងមានតម្លៃនៅប៉ៃលិនត្រូវវិនាសអន្តរាយអស់ ហើយថែមទាំងធ្វើឱ្យខូចលំនឹងបរិស្ថានផងដែរ ដូចជាការច្រោះដីការធ្វើឱ្យកករល្អក់ទឹកស្ទឹង បឹងបួជាដើម ។ ការហិនហោចកំណាប់ត្បូងនៅតំបន់ប៉ៃលិន គឺជាការបាត់បង់ដ៏ធ្ងន់ធ្ងរសម្រាប់ប្រទេសកម្ពុជា គឺបាត់បង់ថវិការដ្ឋ ជាពិសេសប្រជាជននៅតំបន់ប៉ៃលិនមិនបានទទួលអ្វីសោះពីអាជីវកម្មរ៉ែនេះ ។

ជាទូទៅយុទ្ធសាស្ត្រនៃការអភិវឌ្ឍគឺការយកថាមពលដែលអាចកើតឡើងវិញមកជំនួសថាមពលដែលមិនអាចកើតឡើងវិញ និងការកែច្នៃជាថ្មី ។ *ឧទាហរណ៍* ការកែច្នៃប្រេងរុក្ខជាតិជាជីវឥន្ធនៈ និងជីវឧស្ម័នជាដើម ។ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព មិនមែនត្រឹមតែប្រព្រឹត្តទៅដោយការថែរក្សាការពារលំនឹងបរិស្ថាន និងមិនធ្វើឱ្យខូចខាតផលប្រយោជន៍ដល់អ្នកជំនាន់ក្រោយប៉ុណ្ណោះទេ តែការអភិវឌ្ឍនេះត្រូវប្រព្រឹត្តទៅដោយមានការចូលរួមពីប្រជាពលរដ្ឋដែលនៅជុំវិញកន្លែងអភិវឌ្ឍ និងត្រូវតែធ្វើឱ្យប្រជាពលរដ្ឋក៏ដូចជាជាតិទាំងមូលបានទទួលកម្រៃផលប្រយោជន៍ពីការអភិវឌ្ឍផងដែរ ។

ប្រទេសកម្ពុជាយើង បានខាតបង់ធនធានធម្មជាតិយ៉ាងហោចណាស់ក៏មួយផងរួចមកហើយក្នុងទសវត្សរ៍ឆ្នាំ 90 នៃសតវត្សទី 20 គឺការរេចរិលធនធានត្បូងមានតម្លៃនៅប៉ៃលិន ហើយប្រជាជនខ្មែរ ក៏ដូចជាប្រជាជននៅតំបន់ប៉ៃលិនទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើលំនឹងបរិស្ថាន ។ ទឹកស្ទឹងបឹងបួប្រែជាល្អក់កករដោយសារការលាងត្បូង ។ ប្រជាពលរដ្ឋប្រើប្រាស់ទឹកលែងកើត ។ បឹងស្ទឹងរាក់ដោយសារកំណកកករដី ពូជត្រីថយចុះ និងទទួលការបាត់ពូជ ។ បាត់បង់ដីសម្រាប់ប្រកបរបរកសិកម្មដោយសារតែដីស្រទាប់ក្រោមដែលគ្មានជីជាតិត្រឡប់មកជំនួសដីស្រទាប់លើដែលពោរពេញដោយជីជាតិទៅវិញ ។ ដោយសារការរេចរិលធនធានធម្មជាតិនេះហើយ ប្រជាជនប្រទេសមួយចំនួនរស់ក្រោមបន្ទាត់នៃភាពក្រីក្រនៅឡើយ ថ្វីត្បិតតែប្រទេសទាំងនោះជាប្រទេសសម្បូរដោយភោគទ្រព្យធម្មជាតិក៏ដោយ ។

## ✍ ពាក្យគន្លឹះ

- **ទូនឌ្រ៊ិប** : អានថា [ទូ-ន] គឺជាគ្រឹះនៃទ្វីបបង្កើតឡើងដោយសិលាថាសរឹងមាំ ។
- **ខ្ពង់រាបបាតសមុទ្រ** : (ហៅម្យ៉ាងទៀតថាតំបន់ជាយទ្វីប)ជាភាគនៃបាតសមុទ្រគិតពីឆ្នេរ 0m ទៅដល់ជម្រៅទឹក 200m ។
- **ធរណីវិទ្យា** : វិទ្យាសាស្ត្រសិក្សាអំពីផែនដី ដែលទាក់ទងទៅនឹងសមាសធាតុបង្ក បង្កើតជាសិលា រ៉ែ ស្រទាប់ដីផូស៊ីលជាដើម ។
- **ផូស៊ីលវិទ្យា** : វិទ្យាសាស្ត្រ សិក្សាពីសំណៅសំណល់រុក្ខជាតិ និងសត្វ ដែលកើតមានតាំងពីយូរលង់ណាស់មកហើយក្នុងអតីតកាលផែនដី ។
- **សិលាវិទ្យា** : វិទ្យាសាស្ត្រសិក្សាពីកំណក់កំណើត វិវត្តន៍ ធាតុផ្សំប្រភេទសិលា ។
- **ម៉ាញេទិក** : ដែកអុកស៊ីតម្យ៉ាងមានលក្ខណៈជាមេដែក $Fe_3O_4$ ។
- **លីម៉ូនីត** : ដែកអ៊ីដ្រុកស៊ីត ជារ៉ែដែកម្យ៉ាងទៀត $Fe(OH)_2$
- **ស៊ីដេរីត** : ដែកកាបូណាត ជារ៉ែដែកម្យ៉ាងទៀត ($FeCO_3$)

## ? សំណួរ

1. តាមធរណីវិទ្យាប្រទេសកម្ពុជា តើគេអាចសន្និដ្ឋានបានយ៉ាងដូចម្ដេចចំពោះភោគទ្រព្យរ៉ែ ?
2. ចូររាប់មណ្ឌលរ៉ែទាំងអស់នៅប្រទេសកម្ពុជា ។ តើមណ្ឌលរ៉ែណាមួយដែលសព្វថ្ងៃកំពុងមានសកម្មភាពខ្លាំងក្លាជាងគេ ? ចូររាប់ឈ្មោះក្រុមហ៊ុនដែលកំពុងធ្វើដំណើរការផ្នែកនេះ ។
3. តើការធ្វើអាជីវកម្មរ៉ែនៅប៉ៃលិននាំមកនូវផលប៉ះពាល់អ្វីខ្លះដល់បរិស្ថាន ?
4. ផ្ដើមចេញពីអាជីវកម្មរ៉ែនៅប៉ៃលិន តើគេអាចនិយាយបានពីនិរន្តរភាពនៃអភិវឌ្ឍន៍ដែរឬទេ ? ចូរពន្យល់ ។
5. ហេតុអ្វីបានជាក្រុមហ៊ុនរុករករ៉ែប្រេងកាតនៅក្នុងឈូងសមុទ្រកម្ពុជា ច្រើនតែបោះបង់ចោលការរុករក ?

# 2 ភោគទ្រព្យទេសចរណ៍ធម្មជាតិនៅកម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

- អធិប្បាយពីភោគទ្រព្យទេសចរណ៍កម្ពុជាដូចជា រមណីយដ្ឋាននានា កិច្ចអភិវឌ្ឍន៍ និងផលប៉ះពាល់ព្រមទាំងយុទ្ធសាស្ត្រអភិវឌ្ឍន៍ភោគទ្រព្យទេសចរណ៍ធម្មជាតិ ។

ស្ថានភាពភូមិសាស្ត្រកម្ពុជារួមមាន ទីតាំងភូមិសាស្ត្រ សណ្ឋានដី អាកាសធាតុ ផ្លូវទឹក បានបង្កើតឱ្យមានតំបន់ទេសភាពប្លែកៗដែលជាកន្លែងទេសចរណ៍ធម្មជាតិ និងជាប្រភពចំណូលថវិកាជាតិមួយដ៏សំខាន់ ។ តើភោគទ្រព្យប្រភេទនេះមានអ្វីខ្លះ ? តើយើងអាចទាញយកអស់លទ្ធភាពពីអំណោយផលធម្មជាតិទាំងនេះបានដោយរបៀបណា ដើម្បីអាចរក្សាបាននូវនិរន្តរភាពនៃអភិវឌ្ឍន៍ ?

## 1. រមណីយដ្ឋានធម្មជាតិនៅកម្ពុជា



*ឆ្នេរខ្សាច់កែប*

គ្រប់ខេត្តក្រុងទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា សុទ្ធតែមានរមណីយដ្ឋានទេសចរណ៍ផ្ទាល់របស់ខ្លួន គ្រាន់តែកន្លែងខ្លះមានតិច ឯកន្លែងខ្លះមានច្រើនប៉ុណ្ណោះ ។

នៅប្រទេសកម្ពុជាមានរមណីយដ្ឋានទេសចរណ៍ដ៏ត្រកាល និងសម្បូរបែប ទាំងតំបន់មាត់សមុទ្រ តំបន់ខ្ពង់រាប តំបន់ភ្នំ និងតំបន់វាលរាប ។

នៅតំបន់មាត់សមុទ្រនៃខេត្តកែប កំពត ក្រុងព្រះសីហនុ និងកោះកុង គេឃើញមាន ៖

- រមណីយដ្ឋានកែប ដែលជារមណីយដ្ឋានដ៏ចំណាស់មួយ គឺជាទីក្រុងកម្សាន្តទឹកសមុទ្រ ។ នៅប្របឆ្នេរមានព្រៃភ្នំ ដែលជួយបង្កើនសោភណភាពឆ្នេរខ្សាច់កែប គួបផ្សំជាមួយខ្យល់ដ៏នោរដ៏បរិសុទ្ធជាប្រចាំ ។ ក្រៅពីនេះ គេឃើញមានរមណីយដ្ឋានផ្សេងទៀតដូចជារមណីយដ្ឋានកោះទន្សាយជាដើម ។
- រមណីយដ្ឋានទឹកឈូ រមណីយដ្ឋានភ្នំបូកគោ និងទឹកធ្លាក់ភ្នំពពកវិល ជារមណីយដ្ឋានដ៏ចំណាស់ដែរ ដែលតំណាងឱ្យសម្រស់ដ៏សែនមនោរម្យនៃទឹកដីខេត្តកំពត ។
- រមណីយដ្ឋានឆ្នេរអូរឈើទាល សុខា ហាវ៉ៃ ឯករាជ្យ ជ័យជម្នះ អូរត្រេះ កោះសំពោច កោះពស់ ក្បាលនាយ ភ្នំលើ... ជារមណីយដ្ឋានធម្មជាតិដ៏ស្រស់បំព្រង ប្រចាំទឹកដីនៃខេត្តព្រះសីហនុ ។
- ចាំយាម (រមណីយដ្ឋានធម្មជាតិនិងកែច្នៃ) កោះមូលឬកោះកុងក្រៅ (រមណីយដ្ឋានធម្មជាតិមានកូនភ្នំ ទឹកធ្លាក់ និងឆ្នេរខ្សាច់ជាច្រើន) កោះប៉ោ ទឹកធ្លាក់តាតៃ និងកោះស្តេច (ឆ្នេរខ្សាច់ផ្កាថ្ម និងត្រីសមុទ្រ ...) ជារមណីយដ្ឋានទេសចរណ៍ធម្មជាតិនៃទឹកដីខេត្តកោះកុង ។



ទឹកធ្លាក់តាតៃ(កោះកុង)

នៅតំបន់ភ្នំនិងខ្ពង់រាបនិងតំបន់ភ្នំនៃខេត្តកំពង់ស្ពឺ មណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង និង ព្រះវិហារ គេឃើញមានរមណីយដ្ឋាន ៖

- អំពែភ្នំ គិរីរម្យ ភ្នំព្រៃខ្មែរ និងតេទិកពុះ នៅខេត្តកំពង់ស្ពឺ ។
- ទឹកធ្លាក់ប៊ូស្រា ទឹកធ្លាក់សែនមនោរម្យ ទឹកធ្លាក់ជ្រៃធំ ឆ្នេរទន្លេនៃស្រុកកោះញែក ចម្ការស្រល់ភ្នំដោះក្រមុំ ជារមណីយដ្ឋានដ៏ស្រស់ស្អាតត្រជាក់ចិត្តរបស់ខេត្តមណ្ឌលគិរី ។ ខេត្តមណ្ឌលគិរី គឺជាខ្ពង់រាបមានផ្ទៃរាងជាដោមស្ថិតនៅរាយបន្តគ្នា គ្របដណ្ដប់ដោយវាលស្មៅពណ៌បៃតងស្រស់នៅរដូវវស្សា មើលទៅគួរឱ្យត្រជាក់ចិត្ត តែក្រៀមក្រោះនៅរដូវប្រាំង ។
- បឹងយក្សឡោម ទឹកធ្លាក់កាចាញ ទឹកធ្លាក់ចាអ៊ុង ទឹកធ្លាក់កាទៀង វាលរំបួង់(វាលថ្មរាបស្មើគ្មានដើមឈើដុះ) ភ្នំស្វាយ ជារមណីយដ្ឋានដ៏ត្រកាលរបស់ខេត្តរតនគិរី ។ បឹងយក្សឡោមគឺជាមាត់រន្ធភ្នំភ្លើង ។ តាមការសាកសួរព័ត៌មានគេបានឱ្យដឹងថា បឹងយក្សឡោមនេះជាពាក្យក្លាយមកពីពាក្យជនជាតិទំពួនដែលថា "យ៉ាកលោម" "យ៉ាក" មានន័យថា លោកឬលោកតា ចំណែកពាក្យ លោម ជាឈ្មោះមនុស្ស ដូច្នេះបឹងយ៉ាកលោមមានន័យថា បឹងលោកតាលោម ។ ក្រោយមកពាក្យ យ៉ាក ក្លាយជាពាក្យយក្ស ហើយពាក្យ លោមក្លាយជាពាក្យ ឡោម "បឹងយក្សឡោម" ។



*បឹងយក្សឡោម(រតនគិរី)*

- ភ្នំសំបុក ទឹកជ្រោះសម្បូណ៌ និងកាំពី ជារមណីយដ្ឋានដ៏ពិសេសរបស់ខេត្តក្រចេះ ។ ភ្នំសំបុកជារមណីយដ្ឋានប្រវត្តិសាស្ត្រនិងធម្មជាតិ ។ ទឹកជ្រោះសម្បូណ៌ នៅរដូវទឹកស្រកគេឃើញទឹកហូរយ៉ាងលឿនតាមចន្លោះជ្រោះថ្មនាបាតទន្លេកាត់ព្រៃលិចទឹកដ៏ស្រស់បំព្រង ។ កាំពីជាកន្លែងទស្សនាសត្វផ្សោតមេគង្គ ជាកន្លែងលេងកម្សាន្ត ដែលទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិកាន់តែច្រើនឡើងៗ ។
- អូរពងមាន់និងកោះខ្សាច់ ជារមណីយដ្ឋានសំខាន់ពីររបស់ខេត្តស្ទឹងត្រែង ។ អូរពងមាន់ជារមណីយដ្ឋានធម្មជាតិកែច្នៃ ។ កោះខ្សាច់នៅលើដងទន្លេកុង មានឆ្នេរខ្សាច់សក្បុសជារមណីយដ្ឋានធម្មជាតិសុទ្ធសាធ ។
- រមណីយដ្ឋានប្រាសាទព្រះវិហារ មានលក្ខណៈវប្បធម៌ប្រវត្តិសាស្ត្រច្រើនជាងធម្មជាតិជាប្រាសាទភ្នំ នៅលើជួរភ្នំដងរែក ។ នៅលើទួលខ្ពស់មួយខាងក្រោយប្រាសាទ ពិសេសត្រង់កន្លែងមួយឈ្មោះថា "ពយតាឌី" បើគេបែរមុខមកខាងត្បូង រួចមើលមកខាងក្រោម គេនឹងឃើញទិដ្ឋភាពរូមនៃទេសភាពវាលស្រែពណ៌បៃតងស្រស់ឬពណ៌មាសនៃទឹកដីខេត្តព្រះវិហារ ។ រមណីយដ្ឋានប្រាសាទកោះកេរ្តិ៍ មានលក្ខណៈដូចរមណីយដ្ឋានប្រាសាទព្រះវិហារដែរ គឺជារមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រនិងធម្មជាតិ ។



*ប្រាសាទព្រះវិហារ*

តំបន់បឹងទន្លេសាប ខេត្តសៀមរាប កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន ឧត្តរមានជ័យ និងបន្ទាយមានជ័យ គេឃើញមាន ៖

- ខេត្តសៀមរាប សម្បូរទៅដោយរមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រច្រើនជាងរមណីយដ្ឋានធម្មជាតិ។ ប្រាង្គប្រាសាទទាំងឡាយដែលជាកេរដំណែលវប្បធម៌សំខាន់ៗនៅក្នុងទឹកដីនៃខេត្តនេះ មានប្រាសាទបាយ័ន តាព្រហ្ម តាកែវ បន្ទាយស្រីជាដើម។ ភ្នំគូលែន ជារមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិមួយ (ព្រៃ ភ្នំ និងទឹកធ្លាក់)។ ដោយស្ថិតនៅជាប់មាត់បឹងទន្លេសាប ខេត្តសៀមរាបមានរមណីយដ្ឋានធម្មជាតិដូចជា ជំរំព្រៃដើមរាំងកំពង់ផ្លុល កំពង់ភ្លុក និងភូមិបណ្តែតទឹកចុងឃ្នៀស។
- ខេត្តបន្ទាយមានជ័យ មានភ្នំបាក់ និងភ្នំជញ្ជាំង (រមណីយដ្ឋានធម្មជាតិនិងវប្បធម៌) ល្អាងភ្នំតូច (រមណីយដ្ឋានវប្បធម៌ និងធម្មជាតិ) ប្រាសាទបន្ទាយឆ្មារអាងទឹកកងវ៉ា និងត្រពាំងថ្ម(រមណីយដ្ឋានធម្មជាតិ)។
- ខេត្តឧត្តរមានជ័យ មានរមណីយដ្ឋានមួយចំនួន ខ្លះជារមណីយដ្ឋានវប្បធម៌ ខ្លះជារមណីយដ្ឋានកែច្នៃ ខ្លះទៀតជាធម្មជាតិ និងខ្លះទៀតជាធម្មជាតិ និងរមណីយដ្ឋានប្រវត្តិសាស្ត្រដូចជាទឹកធ្លាក់ចំប៉ីឬទឹកធ្លាក់ល្អាងតាចង(រមណីយដ្ឋានធម្មជាតិ) តំបន់ទន្លេស អាងអូរអង្គ្រង អាងត្រពាំងបារាយណ៍(ធម្មជាតិ និងប្រវត្តិសាស្ត្រ)។
- រមណីយដ្ឋានធម្មជាតិខេត្តបាត់ដំបង មានរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រជាច្រើនដូចជាប្រាសាទភ្នំបាណន់ ឯកភ្នំ និងប្រាសាទស្នឹង ចំណែករមណីយដ្ឋានធម្មជាតិមានភ្នំសំពៅ សេកសក ពពុះពេជ្រចិន្តា ដងទង់ និងល្អាងស្ពាន។ រមណីយដ្ឋានសេកសកជាជម្រាលមាត់ស្ទឹងមានទឹកថ្លាឆ្វង់ ហូរលើផ្ទាំងសិលា និងចន្លោះផ្ទាំងសិលា អមដោយព្រៃព្រឹក្សាពណ៌បៃតងស្រងាត់ផ្តល់ម្លប់ត្រឈឹងត្រឈៃគួរជាទីរីករាយក្នុងចិត្ត។
- ខេត្តប៉ៃលិន មានរមណីយដ្ឋានភ្នំយ៉ាត ភ្នំកុយ ភ្នំខៀវ អូរអែប និងអូរតាវ៉ៅ។ ភ្នំយ៉ាតជារមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិ(សណ្ឋានដីជាកូនភ្នំមួយ ហើយពីលើកំពូលភ្នំគេអាចមើលឃើញទេសភាពជុំវិញភ្នំបានដូចជា ព្រៃព្រឹក្សា អូរ ភូមិឋានអ្នកស្រុក ...)។ ភ្នំកុយ អូរអែប និងអូរតាវ៉ៅ ជារមណីយដ្ឋានធម្មជាតិ ជាតំបន់ទឹកធ្លាក់ជាថ្នាក់ៗ ដែលអមសងខាងដោយព្រៃព្រឹក្សា។
- ខេត្តពោធិ៍សាត់ មានរមណីយដ្ឋាន ភ្នំបាក់ត្រា បាឃ្លះ និងកំពង់ហ្លួង។ បាក់ត្រា និង បាឃ្លះជារមណីយដ្ឋានវប្បធម៌ និងធម្មជាតិ។ កំពង់ហ្លួងជារមណីយដ្ឋានធម្មជាតិដោយមានទីតាំងស្ថិតនៅជាប់មាត់បឹងទន្លេសាប។

- ខេត្តកំពង់ឆ្នាំង មានរមណីយដ្ឋានភ្នំរាប់បាត្រ ភ្នំសន្ទូច ភ្នំក្រាំងដីមាស តំបន់ទេសភាពបឹងទន្លេសាប និងភ្នំតារាជ។ ភ្នំរាប់បាត្រជារមណីយដ្ឋានវប្បធម៌និងធម្មជាតិ។ ភ្នំសន្ទូច ភ្នំក្រាំងដីមាស និងតំបន់ទេសភាពបឹងទន្លេសាប ជារមណីយដ្ឋានធម្មជាតិ។ ភ្នំតារាជជារមណីយដ្ឋានធម្មជាតិ និងប្រវត្តិសាស្ត្រ។
- ខេត្តកំពង់ធំ មានរមណីយដ្ឋានច្រើនកន្លែងដែរ ដែលមួយចំនួនជារមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ ចំណែកភ្នំសន្ទុកជារមណីយដ្ឋានវប្បធម៌ធម្មជាតិ ប្រាសាទសម្បូរព្រៃគុហ៍ជារមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ ធម្មជាតិ ព្រៃប្រស់ជារមណីយដ្ឋានធម្មជាតិកែច្នៃ ប្រាសាទព្រះខ័នសម្បូរព្រៃគុហ៍។

នៅតំបន់វាលរាបនៃខេត្តកណ្ដាល កំពង់ចាម តាកែវ ព្រៃវែង ស្វាយរៀង និងរាជធានីភ្នំពេញ គេឃើញមាន៖

- ខេត្តកណ្ដាល មានរមណីយដ្ឋានច្រើនកន្លែង ហើយសុទ្ធតែជារមណីយដ្ឋានធម្មជាតិ វប្បធម៌ ដូចជាភ្នំអដ្ឋរស្ស(ភ្នំឧដុង្គ ឬភ្នំព្រះរាជទ្រព្យ) ភ្នំធនមន្ត ភ្នំប្រសិទ្ធិ ស្ពានភ្នំ វត្តភ្នំទំពែក វត្តអង្គរជ័យ វត្តកៀនស្វាយក្រៅ និងកោះដាច់។
- ខេត្តកំពង់ចាម មានរមណីយដ្ឋានច្រើនកន្លែងដែលភាគច្រើនជារមណីយដ្ឋានវប្បធម៌(ប្រាសាទនគរបាជ័យ ប្រាសាទព្រះធាតុ ថ្មដា ...) ខ្លះទៀតជារមណីយដ្ឋាន វប្បធម៌ និងធម្មជាតិ (ភ្នំប្រុស ភ្នំស្រី ភ្នំហាន់ជ័យ ប្រាសាទភ្នំជើងព្រៃ ...) ខ្លះទៀតជាធម្មជាតិឬធម្មជាតិកែច្នៃ(ទឹកធ្លាក់ហោង ជ្រោយចេក ទឹកឆា ...)។
- ខេត្តតាកែវ សម្បូរដោយរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ និងធម្មជាតិដូចជា ភ្នំដា ភ្នំបាយ័ង់ ភ្នំជីសូរ ភ្នំតាម៉ៅ ទន្លេបាទី...។



ផ្លូវចូលទៅកាន់សួនសត្វរមណីយដ្ឋានភ្នំតាម៉ៅ

- ខេត្តព្រៃវែង សម្បូររមណីយដ្ឋានវប្បធម៌ ។ បាភ្នំជារមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រនិងធម្មជាតិ ។
- ខេត្តស្វាយរៀង មានរមណីយដ្ឋានតែមួយគត់គឺ រមណីយដ្ឋានព្រៃបាសាក់ សម្បូរទៅដោយព្រៃស៊ុបទ្រុប ។
- រាជធានីភ្នំពេញ សម្បូរទៅដោយរមណីយដ្ឋាន វប្បធម៌ប្រវត្តិសាស្ត្រ។ ភ្នំដូនពេញជារមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ និងធម្មជាតិ(ជាកូនភ្នំដីតូចមួយស្ថិតនៅមិនឆ្ងាយប៉ុន្មានពីទន្លេសាប)ព្រះបរមរាជវាំង វិហារព្រះកែវមរកត សារមន្ទីរជាតិ ។ ចតុមុខជាចំណុចប្រសព្វនៃទន្លេទាំងបួនគឺទន្លេមេគង្គលើ ទន្លេមេគង្គក្រោម ទន្លេសាប និងទន្លេបាសាក់ បង្កើតបានជារមណីយដ្ឋានធម្មជាតិមួយ(ភ្ញៀវទេសចរអាចជិះកាណូតកម្សាន្តតាមដងទន្លេនៅពេលណាក៏បានពិសេសមុនពេលព្រះអាទិត្យអស្តង្គត) ។

## 2. កិច្ចអភិវឌ្ឍ និងផលប៉ះពាល់




*ផែនទីតំបន់អភិរក្ស (ផែនទីទេសចរណ៍)*

គ្រប់រមណីយដ្ឋានទាំងអស់ ទោះជាប្រភេទណាក៏ដោយ ក៏ទាមទារឱ្យមានការរៀបចំសម្រាប់បម្រើការលេងកម្សាន្តរបស់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ និងការទាក់ទាញភ្ញៀវផងដែរ ។ សេវាបម្រើភ្ញៀវទាំងនោះមានការថែរក្សាអនាម័យ សុវត្ថិភាព របៀបរៀបរយ សណ្ដាប់ធ្នាប់ ភាពស្អាតស្អំ ការធ្វើដំណើរ ការហូបចុក ការស្នាក់នៅ ប្រកបដោយផាសុកភាព និងភាពស្អាតស្អំ ... ។ ការធ្វើដំណើរ តម្រូវឱ្យមានមធ្យោបាយដឹកជញ្ជូនល្អដូចជា ផ្លូវថ្នល់ និងរថយន្ត ... ។ ការហូបចុក តម្រូវឱ្យសាងសង់អាហារដ្ឋានស្អាតប្រណីតៗ នៅទីជិតៗឬក្បែររមណីយដ្ឋាន រួមទាំងសេវាបម្រើមុខម្ហូបអាហារជូនភ្ញៀវបានរហ័សទាន់ពេល និងតម្លៃសមស្របផង ។ ការស្នាក់នៅរបស់ភ្ញៀវក៏ត្រូវយកចិត្តទុកដាក់ឱ្យបានល្អដែរ ពោលគឺឱ្យភ្ញៀវស្នាក់នៅបានស្រួលគ្មានក្ដីបារម្ភ ។ ការរក្សាសុវត្ថិភាពជូនភ្ញៀវទាមទារឱ្យមានកងសន្តិសុខ ដែលទទួលបានការហ្វឹកហាត់ត្រឹមត្រូវ សុភាពរាបសារតែម៉ឺងម៉ាត់ ។ កិច្ចអភិវឌ្ឍទាំងនេះ ត្រូវការជាចាំបាច់នូវទុនសម្រាប់ធ្វើវិនិយោគគ្រប់វិស័យជំនាញ និងផែនការអភិវឌ្ឍ ។ យើងឃើញមានក្រុមហ៊ុនទេសចរណ៍ជាច្រើន បានរៀបចំដំណើរកម្សាន្តតាមរថយន្តទៅកាន់រមណីយដ្ឋាននានានៃប្រទេសកម្ពុជា ។ កិច្ចអភិវឌ្ឍតម្រូវឱ្យមានការផ្សព្វផ្សាយពាណិជ្ជកម្មយ៉ាងទូលំទូលាយ ស្ដីអំពីរមណីយដ្ឋានធម្មជាតិដ៏ស្រស់ត្រកាលរបស់ប្រទេសយើង ដើម្បីទាក់ទាញភ្ញៀវទេសចរឱ្យបានកាន់តែច្រើនថែមទៀត មានដូចជាឧទ្យានជាតិ តំបន់ការពារព្រៃធម្មជាតិ ដែនជម្រកសត្វព្រៃ តំបន់អភិរក្សជីវចម្រុះ ដែនជម្រកមច្ឆជាតិ តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់ការពារទេសភាព តំបន់ការពារធនធានសមុទ្រ ទេសភាពព្រៃព្រឹក្សា ទេសភាពព្រៃភ្នំ ទេសភាពបឹងទន្លេសាប ទេសភាពដងទន្លេមេគង្គ ទន្លេសាប ... រួមទាំងសម្រស់កោះនានារបស់យើងផងដែរ ។

ទន្ទឹមនឹងនេះ កិច្ចអភិវឌ្ឍទាំងនោះតែងនាំមកនូវផលប៉ះពាល់ បើមិនច្រើនក៏តិចតួចដែរ ដោយចៀសមិនផុតដូចជា ការបាត់បង់ព្រៃឈើដោយការកាប់បំផ្លាញព្រៃឈើក្នុងព្រៃបម្រុងទុកដោយការឈូសឆាយ ធ្វើផ្លូវថ្នល់ទៅកាន់ទីរមណីយដ្ឋាន សង់អាហារដ្ឋាន កន្លែងទុកដាក់យានជំនិះ បន្ទប់ទឹកសាធារណៈ ... ។ ការដឹកជញ្ជូនភ្ញៀវតាមយានយន្ត ដើរដោយចំហេះប្រេងសាំង ប្រេងម៉ាស៊ូត រួមចំណែកបង្កើនជាតិពុលក្នុងបរិយាកាស ។ បញ្ហាមួយទៀតគឺកាកសំណល់ដែលភ្ញៀវបោះបង់ចោល បើគ្មានកន្លែងទុកដាក់ត្រឹមត្រូវ នាំឱ្យមានភាពកខ្វក់រមណីយដ្ឋានបាត់បង់សោភណភាព ។

## ៣. យុទ្ធសាស្ត្រនៃការអភិវឌ្ឍភោគទ្រព្យទេសចរណ៍ធម្មជាតិ

ដើម្បីរក្សានិរន្តរភាពនៃការអភិវឌ្ឍផ្នែកភោគទ្រព្យទេសចរណ៍ធម្មជាតិរបស់ប្រទេសយើង តើរាជរដ្ឋាភិបាលកម្ពុជាមានវិធានការអនុវត្តអ្វីខ្លះហើយ ក្នុងពេលកន្លងមកនិងទៅអនាគត ?



*តំបន់ការពារធម្មជាតិព្រែកទាល់*

នៅតាមខេត្តនានា មន្ទីរទេសចរណ៍មាននាទី ជាអ្នកគ្រប់គ្រង និងចាត់ចែងរៀបចំរមណីយដ្ឋានទាំងអស់ដែលមាននៅក្នុងខេត្តរបស់ខ្លួន ។ ប៉ុន្តែ គេឃើញរមណីយដ្ឋានមួយចំនួន ត្រូវបានប្រគល់ទៅឱ្យក្រុមហ៊ុនឯកជនកាន់កាប់រកស៊ី តាមអាជ្ញាប័ណ្ណរបស់ក្រសួងទេសចរណ៍ ឬរដ្ឋាភិបាលដូចជា ឆ្នេរសុខានៃខេត្តព្រះសីហនុជាដើម ។ ចំណែកតំបន់ទេសចរណ៍ខេត្តសៀមរាប ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ "អាជ្ញាធរអប្សរា" និងជាតំបន់ការពារទេសភាព សម្បូរប្រាង្គប្រាសាទ លម្អដោយព្រៃព្រឹក្សា ដែលជារមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិ ។

ការថែរក្សា និងអភិវឌ្ឍភោគទ្រព្យទេសចរណ៍ ជាតួនាទី និងជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។ ដូច្នេះហើយយើងម្នាក់ៗត្រូវចូលរួមចំណែកក្នុងការថែរក្សាបរិស្ថាន ជាពិសេសបរិស្ថានធម្មជាតិ ការរក្សាអនាម័យ និងរក្សាព្រៃធម្មជាតិដែលមាននៅក្នុងតំបន់ទេសចរណ៍ទាំងនេះ ។

- រមណីយដ្ឋានទឹកធ្លាក់អាចជាទីទាក់ទាញអារម្មណ៍ជនានុជនទាំងឡាយ អាស្រ័យដោយមានទឹកធ្លាក់ជាប្រចាំ និងលម្អជុំវិញដោយព្រៃឈើស្រស់ស្អាត និងទឹកដ៏ថ្លាឈ្វេង ។ បើគ្មានព្រៃឈើក៏គ្មានប្រភពទឹក ។ រមណីយដ្ឋានគ្មានទឹកគ្មានព្រៃឈើ ជារមណីយដ្ឋានស្លាប់ ។ យើងមិនអាច

ទាញយកផលកម្រៃអ្វីទៀតឡើយ ព្រោះគ្មានភ្ញៀវចេញចូលមកលេងកម្សាន្ត ។ ដូច្នេះជាចាំបាច់ យើងត្រូវរក្សាព្រៃឈើដែលជាប្រភពនៃទឹកជ្រោះ និងទឹកធ្លាក់ ។ រមណីយដ្ឋានទឹកធ្លាក់មួយចំនួនបានទទួលការរៀបចំត្រឹមត្រូវល្អ ទាំងសន្តិសុខ សណ្តាប់ធ្នាប់ និងសេវាផ្សេងៗ ដូចជា ទឹកឈូ ក្បាលឆាយ គីរីរម្យ ភ្នំគូលែន សេកសក អូរតាវ៉ៅ ជាដើម តែមួយចំនួនទៀតមិនទាន់ទទួលបានការរៀបចំល្អត្រឹមត្រូវនៅឡើយទេ ។



*ទឹកជ្រោះប៊ូស្រា(មណ្ឌលគិរី)*

- ភ្នំឧដុង្គ ភ្នំតាម៉ៅ ភ្នំជីសូរ ភ្នំសំពៅ ភ្នំសន្ទុក ភ្នំសន្ធូច ភ្នំក្រោម ... សុទ្ធសឹងជាកូនភ្នំនៃតំបន់ទំនាបកណ្តាលកម្ពុជា ជារមណីយដ្ឋាន ដែលទទួលបានការរៀបចំល្អហើយព្រមទាំងមានភ្ញៀវទេសចរចេញចូលទៅមកលេងកម្សាន្តមិនសូវដាច់ ពិសេសនៅថ្ងៃឈប់សម្រាកឬថ្ងៃបុណ្យទាន ។
- បឹងយក្សឡោម ដ៏ស្រស់ឆើតឆាយនៃតំបន់ខ្ពង់រាបកម្ពុជា ជារមណីយដ្ឋានមួយដែលគេនិយមទៅលេងកម្សាន្ត ។
- បឹងទន្លេសាប ជាបឹងធម្មជាតិមួយដ៏ល្បីល្បាញរបស់ប្រទេសកម្ពុជា ដោយសារភាពសម្បូរត្រី និងទិដ្ឋភាពបឹងដែលមានលក្ខណៈជាកូនសមុទ្រក្នុងនៅរដូវទឹកដំឡើង ផ្ទៃបឹងរួមតូចរាងដូចវីយ៉ូឡុងនៅរដូវទឹកសម្រក និងជាឡូត៍នេសាទដ៏សំខាន់ ។ កន្លងមក តំបន់ខ្លះនៃមាត់បឹងត្រូវ

បានរៀបចំឱ្យទៅជាតំបន់ទេសចរណ៍រួចហើយដូចជា រមណីយដ្ឋានកំពង់ហ្លួងនៃខេត្តពោធិ៍សាត់ ដំរីព្រៃវាំងលិចទឹកនៃខេត្តសៀមរាប ... ជាដើម ។ មានក្រុមហ៊ុនទេសចរណ៍ជាច្រើនបានរៀបចំឱ្យមានដំណើរកម្សាន្តជុំវិញបឹងទន្លេសាប តាមរថយន្តក្រុងរួចមកហើយ ។ គេអាចរៀបចំដំណើរកម្សាន្តតាមនាវាជូនភ្ញៀវទេសចរដើម្បីបានទស្សនាទេសភាពភូមិឋានអ្នកស្រុកតាមដងទន្លេ ទេសភាពមាត់បឹង ឡូត៍នេសាទ ភូមិអណ្តែតទឹក ... នៃបឹងទន្លេសាបជាបន្ថែមទៀត ។



*បឹងទន្លេសាប*

និយាយរួម ប្រទេសយើងសម្បូរភោគទ្រព្យទេសចរណ៍ធម្មជាតិ ដែលសុទ្ធតែអាចយកមកបម្រើឱ្យការអភិវឌ្ឍវិស័យទេសចរណ៍ បង្កើតបានជាប្រភពចំណូលថវិកាជាតិមួយផ្នែកដ៏សំខាន់ ។

## ✍ ពាក្យគន្លឹះ

- **ឧទ្យានជាតិ** : តំបន់ធម្មជាតិ និងមានទស្សនីយភាពប្រកបដោយសារៈសំខាន់ ដោយសារតម្លៃផ្នែកវិទ្យាសាស្ត្រ អប់រំ និងផ្នែកសម្រាកកម្សាន្ត ។
- **តំបន់ការពារទេសភាព** : តំបន់ទេសភាពធម្មជាតិឬពាក់កណ្តាលធម្មជាតិសំខាន់ៗដែលទាមទារឱ្យមានការថែរក្សា ដើម្បីផ្តល់នូវលទ្ធភាពដល់ការសម្រាកកម្សាន្ត និងទេសចរណ៍ ។

- តំបន់ប្រើប្រាស់ច្រើនយ៉ាង : តំបន់ដែលអាចផ្តល់នូវភាពស្ថិតស្ថេរលើប្រភពទឹក ព្រៃឈើ សត្វព្រៃ ត្រី វាលស្មៅ និងការកម្សាន្ត ដោយតម្រូវឱ្យមានការអភិវឌ្ឍអភិរក្សធម្មជាតិក្នុងគោលដៅចម្បងនៃសកម្មភាពសេដ្ឋកិច្ច ។
- ដែនជម្រកសត្វព្រៃ : ដែនធម្មជាតិដែលធានានូវលក្ខខណ្ឌធម្មជាតិចាំបាច់ក្នុងការការពារប្រភេទសត្វព្រៃ និងរុក្ខជាតិរបស់ជាតិសំខាន់ៗនិងសហគមន៍ធម្មជាតិឬលក្ខណៈរូបសាស្ត្ររបស់បរិស្ថានជាទីដែលភាវៈទាំងនេះត្រូវការ ជាពិសេសនូវអន្តរាគមន៍ពីមនុស្សសម្រាប់ភាពឋិតថេររបស់វា ។

## ? សំណួរ

1. តើនៅប្រទេសកម្ពុជាយើងសម្បូរភោគទ្រព្យទេសចរណ៍ធម្មជាតិដែរឬទេ ? ចូររាប់ឈ្មោះភោគទ្រព្យទេសចរណ៍ធម្មជាតិទាំងនោះឱ្យបានប្រាំយ៉ាងតិច ។
2. តើខេត្តណាខ្លះដែលមានទីតាំងស្ថិតនៅជាប់ និងតំបន់មាត់សមុទ្រ ? តើខេត្តទាំងនោះមានភោគទ្រព្យទេសចរណ៍ធម្មជាតិអ្វីខ្លះដែលទាក់ទាញភ្ញៀវទេសចរសំខាន់ជាងគេ ?
3. ចូររាប់ឈ្មោះភ្នំនៅតំបន់ទំនាបកណ្តាលកម្ពុជាយើងឱ្យបានប្រាំយ៉ាងតិច ដែលជារមណីយដ្ឋានដែលគេចូលចិត្តខ្លាំងជាងគេ ។
4. តើអ្នកធ្លាប់បានទៅកម្សាន្តនៅរមណីយដ្ឋានទឹកធ្លាក់ដែរឬទេ ? នៅខេត្តណាខ្លះ ? ចូររៀបរាប់ ។
5. តើភោគទ្រព្យទេសចរណ៍ធម្មជាតិទាំងនោះ អាចរីងស្ងួតដូចភោគទ្រព្យរ៉ែដែរឬទេ ? ចូរពន្យល់ ។
6. ដើម្បីទាញយកផលពីភោគទ្រព្យទេសចរណ៍ធម្មជាតិទាំងនោះ តើគេត្រូវធ្វើដូចម្តេចខ្លះ ?
7. ដើម្បីធានាបាននូវនិរន្តរភាពនៃការអភិវឌ្ឍផ្នែកភោគទ្រព្យទេសចរណ៍ធម្មជាតិ តើគេត្រូវធ្វើដូចម្តេច ?
8. តំបន់អង្គរ ជាតំបន់ការពារទេសភាព ៖

   ក. ចូរកំណត់ន័យនៃពាក្យ "តំបន់ការពារទេសភាព" ។

   ខ. តើតំបន់អង្គរអាចជារមណីយដ្ឋានប្រភេទណាខ្លះ ?

មេរៀនទី

# 3 សេដ្ឋកិច្ចកម្ពុជា

ចប់មេរៀននេះ សិស្សអាច

- ❑ បង្ហាញពីសេដ្ឋកិច្ចកម្ពុជា : កសិកម្ម ឧស្សាហកម្ម គមនាគមន៍ និងពាណិជ្ជកម្ម ។

មកទល់បច្ចុប្បន្ននេះ សេដ្ឋកិច្ចកម្ពុជាស្ថិតក្នុងស្ថានភាពអន់ថយនៅឡើយ ដោយផ្អែកលើកិច្ចការកសិកម្មជាធំ ។ ចំណែកឧស្សាហកម្មធុនធ្ងន់ដែលជាគ្រឹះនៃសេដ្ឋកិច្ចជឿនលឿន ប្រទេសយើងមិនទាន់មានទេ មានតែឧស្សាហកម្មធុនស្រាលប្រកបដោយកំណើនផលិតកម្មមិនទៀងទាត់ ។ រីឯពាណិជ្ជកម្មទៀតសោត ក៏មានកំណើនមិនថេរដែរ ។ ដកញ្ជីងពាណិជ្ជកម្មក៏មិនទាន់មានតុល្យភាពនៅឡើយ ។

## 1. កសិកម្មកម្ពុជា

កសិកម្មកម្ពុជា បានបំពេញតួនាទីយ៉ាងសំខាន់ក្នុងជីវភាពសេដ្ឋកិច្ចជាតិ ។ ប្រជាជនកម្ពុជាចំនួន 80.5% ជាកសិករ (ជំរឿន 2008) ។ យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផលិតផលកសិកម្មមានចំនួន 28.5% នៃផលិតផលក្នុងស្រុកសរុប (GDP) នៅឆ្នាំ 2007 ។

### 1.1. ដំណាំ

ដំណាំនៅប្រទេសកម្ពុជាយើងមានច្រើនមុខ តែគេអាចចែកដំណាំទាំងនោះ ជាពីរក្រុមធំៗ គឺដំណាំអាហារ និងដំណាំឧស្សាហកម្ម ។

#### ក. ដំណាំអាហារ

- ដំណាំស្រូវ : ដំណាំអាហារសំខាន់ជាងគេគឺដំណាំស្រូវ ព្រោះជាអាហារមូលដ្ឋានរបស់ប្រជាជនកម្ពុជាផង និងជាផលិតផលសម្រាប់នាំចេញទៅលក់នៅក្រៅប្រទេសទៀតផង ។

នៅកម្ពុជាយើង ដំណាំស្រូវមាននៅគ្រប់ខេត្ត ។ មជ្ឈមណ្ឌលផលិតស្រូវសំខាន់ជាងគេគឺទំនាបកណ្តាលកម្ពុជា ដែលចែកជាតំបន់ទន្លេសាប ជាជង្រុកស្រូវទីមួយ និងតំបន់វាលរាបជាជង្រុកស្រូវទីពីរ ។

បើយោលទៅតាមពេលវេលានៃការដាំដុះ គេចែកដំណាំស្រូវ ជាស្រូវវស្សា និងស្រូវប្រាំង។ ស្រូវវស្សារួមមាន ស្រូវសន្ទូង ស្រូវពង្រោះ ស្រូវឡើងទឹក និងស្រូវចម្ការព្រៃដុត។ ស្រូវប្រាំងរួមមាន ស្រូវសន្ទូង និងស្រូវប្រដេញទឹក។ ស្រូវសន្ទូងរដូវប្រាំងធ្វើនៅតំបន់ទំនាបទាបហៅថា ស្រែក្រោម ដោយបាចទឹកបញ្ចូល។ ស្រូវប្រាំងប្រដេញទឹកធ្វើនៅតាមមាត់បឹង ឬទន្លេ ស្ទូងទៅតាមកំពស់ទឹក។

យោលទៅតាមរយៈពេលដែលអាចប្រមូលផលបាន គេអាចចែកស្រូវជាបីប្រភេទ គឺស្រូវស្រាល (3-4 ខែ) ស្រូវកណ្ដាល (6 ខែ) និងស្រូវធ្ងន់ (8-9 ខែ)។

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជាហៅកាត់ថា **កាឌី (CARDI)** ដែលមានភារកិច្ចអភិរក្សពូជដំណាំ និងអភិវឌ្ឍពូជថ្មីៗតាមការបង្កាត់ពូជ ឬតាមការសម្រាំងពូជ បានបន្តថែរក្សាពូជស្រូវប្រពៃណីចំនួន 2 557 ប្រភេទ នៅក្នុងធនាគារពូជ និងបញ្ចេញពូជស្រូវមួយចំនួនជូនប្រជាកសិករប្រើប្រាស់ដូចជា ពូជស្រូវ បារាយណ៍ ផលសារ រំពេ របាត់ សែនពិដោរ ពកូល សារិកា រាំងជ័យ ផ្ការំដួល ផ្ការំចេក ផ្ការំចង់ ផ្ការមៀត និងផ្ការំដេង។ ពូជស្រូវទាំងឡាយដែលដាក់ចេញឱ្យប្រជាកសិករប្រើប្រាស់ដោយវិទ្យាស្ថាន កាឌី (CARDI) សុទ្ធសឹងតែពូជដែលផ្ដល់ទិន្នផលខ្ពស់។

នៅឆ្នាំ 1960 កម្ពុជាអាចនាំចេញស្រូវ 2.38 លានតោន និងសល់ផល 0.5 លានតោនទៀត។ នៅពេលនោះ កម្ពុជាផលិតស្រូវបាន 1.1% នៃផលិតផលស្រូវលើពិភពលោក។ នៅចន្លោះឆ្នាំ 1970-1980 ចម្បាំងក្នុងស្រុកនិងអស្ថិរភាពនយោបាយដ៏រ៉ាំរ៉ៃនៅកម្ពុជាធ្វើឱ្យផលិតផលស្រូវមិនអាចបំពេញតម្រូវការបានគ្រប់គ្រាន់ទេ។

នៅឆ្នាំ 1995 ផ្ទៃដីដាំស្រូវមានប្រមាណ 2.08 លានហិកតា តែផ្ទៃដីប្រមូលផលមានប្រមាណ 1.9 លានហិកតា បរិមាណផលិតផលស្រូវមាន 3.9 លានតោន និងទិន្នផលមធ្យម 1.7 តោន/ហិកតា។ នៅឆ្នាំ 2007 ផ្ទៃដីដាំស្រូវសរុប 2 585 905 ហិកតា កើនលើសឆ្នាំ 2004 ចំនួន 211 730 ហិកតា បរិមាណផលស្រូវដែលប្រមូលបានមាន 6 727 127 តោន កើនលើសចំនួន 2 556 843 តោន បើប្រៀបធៀបនិងឆ្នាំដដែល។



*ម៉ាស៊ីនច្រូតស្រូវ*

ក្នុងពេលបច្ចុប្បន្ន កសិករយើងមួយចំនួនប្រើប្រាស់គ្រឿងយន្តកសិកម្មមានគោយន្ត ត្រាក់ទ័រ ម៉ាស៊ីនស្ទូង ម៉ាស៊ីនច្រូត និងម៉ាស៊ីនបោកបែន ដើម្បីជួយសម្រាលការងារកសិកម្ម ដែលនាំឱ្យចំណេញពេល និងបង្កើនផលិតភាពការងារ ។

សន្និដ្ឋាន : កម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការពង្រីកដំណាំស្រូវ សំដៅឆ្ពោះទៅរកការប្រកួតប្រជែងលើទីផ្សារអន្តរជាតិ ព្រោះលក្ខខណ្ឌអភិវឌ្ឍន៍វិស័យនេះមានអំណោយផលច្រើន ហើយម្យ៉ាងទៀត ស្រូវអង្ករខ្មែរយើងធ្លាប់មានឈ្មោះបោះសំឡេងតាំងពីយូរមកហើយ ជាពិសេសលើទីផ្សារអាហ្វ្រិក ។

- **ដំណាំពោត** : ពោតជាដំណាំអាហារសំខាន់ទី 2 បន្ទាប់ពីស្រូវ ដំណាំពោតមានពីរប្រភេទ គឺពោតស និងពោតក្រហម ។ គេដាំពោតភាគច្រើននៅតាមដងទន្លេមេគង្គ (ក្នុងខេត្តក្រចេះ កំពង់ចាម កណ្ដាល និងព្រៃវែង) និងខេត្តផ្សេងៗទៀតដូចជា ខេត្តបាត់ដំបង ខេត្តប៉ៃលិន ។ ផលិតផលពោតក្រហមបម្រើជាពិសេសឱ្យការនាំចេញ ។ ចំណែកផលិតផលពោតសវិញ សម្រាប់បម្រើឱ្យការបរិភោគក្នុងស្រុកជំនួសស្រូវអង្ករបុំណ្ណោះ ។

វិទ្យាស្ថាន CARDI បានបញ្ចេញនូវពូជពោតពីរមុខ គឺពូជពោត "សជ័យ" និងពូជពោត "លឿងមង្គល" ដែលផ្ដល់ទិន្នផលខ្ពស់ (4 តោន / ហិកតាជាមធ្យម) នៅឆ្នាំ 2006 ដើម្បីឱ្យកសិករយកទៅដាំដុះ ។

- **ដំណាំសណ្តែកបាយ** : នៅតាមខេត្តនានានៃប្រទេសខ្មែរ គេនិយមដាំសណ្តែកបាយពីរប្រភេទ គឺសណ្តែកផេះ និងសណ្តែកប្រេង ។ តំបន់ដំណាំសណ្តែកបាយសំខាន់ៗ គឺតំបន់ដីខ្ពស់(ដីក្រហមក្នុងខេត្តកំពង់ចាម និងដីខ្មៅក្នុងខេត្តបាត់ដំបង) តំបន់មាត់ទន្លេមេគង្គ និងមាត់បឹងទន្លេសាប ។វិទ្យាស្ថាន CARDI បានបញ្ចេញពូជសណ្តែកបាយ កាឌីជ័យ ស៊ីអិមប៊ី 1 ស៊ីអិមប៊ី 2 និង ស៊ីអិមប៊ី 3 ដែលអាចផ្តល់ទិន្នផលជាមធ្យមពី 650kg ទៅ 900 kg/ហិកតា ដើម្បីឱ្យកសិករដាំដុះ ។
- **ដំណាំម្រេច** : ដំណាំគ្រឿងទេសសំខាន់ជាងគេ គឺដំណាំម្រេច ប្រហែលជាមានដើមកំណើតនៅប្រទេសឥណ្ឌា ។ គេដាំម្រេចនៅតំបន់កំពង់ត្រាចខេត្តកំពតនៅឆ្នាំ 1840 រីកលូតលាស់ខ្លាំងចាប់ពីឆ្នាំ 1892 មក ។ គេឃើញមានដំណាំម្រេចផងដែរនៅខេត្តកំពង់ចាម រតនគិរី ... ។ ម្រេចមានបីបែប គឺម្រេចខ្មៅ ម្រេចស និងម្រេចក្រហមដែលអាចបំពេញតម្រូវការក្នុងស្រុកបាន និងសល់សម្រាប់នាំទៅលក់នៅក្រៅប្រទេស ។
- **ដំណាំអាហារផ្សេងៗទៀត** : មានសណ្តែកសៀង ដំណាំផ្តល់ប្រេង (សណ្តែកដី ល្ង ល្ហុងខ្វែដូង) ដំណាំផ្តល់ស្ករ (ត្នោតនិងអំពៅ) ដំណាំមើម (ដំឡូងដូង ដំឡូងជ្វា ដំឡូងដៃខ្លា ដំឡូងឈើ ដំឡូងមី ត្រាវ...) ឈើហូបផ្លែ (ចេក ក្រូច ល្មុត មង្ឃុត មៀន ទៀប ខ្នុរ ល្ហុង ស្វាយ ទុរេន គូលែន សាវម៉ាវ ...) បន្លែ (សាលាដ ស្ពៃ សណ្តែក ត្រសក់ ត្រប់ ននោង ត្រឡាច ឃ្លោក ប៉េងប៉ោះ ឪឡឹក...) កាហ្វេ និងតែ ។



ចម្ការម្រេច



ដំឡូងមី

## ១. ដំណាំឧស្សាហកម្ម

- **ដំណាំកៅស៊ូ** : កៅស៊ូជាដំណាំទី 2 បន្ទាប់ពីដំណាំស្រូវ និងជាដំណាំឧស្សាហកម្មសំខាន់ជាងគេនៅកម្ពុជាយើង ។ ដំណាំនេះមានប្រភពពីប្រទេសប្រេស៊ីល ដែលនាំចូលមកប្រទេសកម្ពុជាដោយក្រុមហ៊ុនឯកជនបារាំងកាលពីឆ្នាំ 1920 ។ គេដាំកៅស៊ូជាលើកដំបូងនៅតំបន់ដីក្រហមនៃខេត្តកំពង់ចាម ក្រចេះ រួចពង្រីកទៅដល់ខេត្តរតនគិរី និងក្រុងព្រះសីហនុទៀត ។ មុនឆ្នាំ

1970 ដំណាំកៅស៊ូនៅកម្ពុជាមាន 67 000 ហិកតាផ្តល់ផល 52 000 តោនក្នុងមួយឆ្នាំ ។ ដោយអនុវត្តតាមរបបសេដ្ឋកិច្ចទីផ្សារ រដ្ឋបានផ្ទេរសិទ្ធិកាន់កាប់ចម្ការកៅស៊ូ ទៅឱ្យក្រុមហ៊ុនឯកជន ។ សព្វថ្ងៃ គេកាប់ដើមកៅស៊ូចាស់ៗចោលរួចដាំដុះថ្មីជំនួសវិញ ។ គេឃើញមានចម្ការកៅស៊ូដាំដុះថ្មីៗដែលជាកម្មសិទ្ធិផ្ទាល់របស់ប្រជាកសិករមួយចំនួនដែរ ។ នៅឆ្នាំ 1995 ផ្ទៃដីចៀរជ័រកៅស៊ូមាន 43 801 ហិកតាឱ្យផលជាជ័រស្ងួតបាន 35 429 តោន ហើយអាចនាំចេញបាន 32 171 តោន ។ ឆ្នាំ 1999 ផ្ទៃដីចៀរជ័រមាន 39 718 ហិកតា ផ្តល់ផលបាន 45 203 តោន ជាជ័រស្ងួតនិងនាំចេញបាន 44 376 តោន ។ នៅឆ្នាំ 2007 ដំណាំនេះត្រូវបានពង្រីកលើផ្ទៃដី 3 820.77 ហិកតា ធៀបទៅនឹងឆ្នាំ 2004 ពង្រីកបានតែ 1 938.7 ហិកតាប៉ុណ្ណោះ ។ ផលិតផលជ័រកៅស៊ូកើនបាន 18 316 តោននៅឆ្នាំ 2007 ដែលកាលពីឆ្នាំ 2004 កើនបានតែ 7 612 តោន ។

ដំណាំកៅស៊ូនៅកម្ពុជាអាចមានលទ្ធភាពនិងពង្រីកថែមទៀត ដោយសារតែដីក្រហមនៅតំបន់ខ្ពង់រាបមានទំហំដល់ទៅ 716 000 ហិកតា ។ ដំណាំកៅស៊ូជាដំណាំមួយដែលមានសារៈសំខាន់ខ្លាំងក្នុងសេដ្ឋកិច្ចជាតិ ជាប្រភពចំណូលថវិកាជាតិ និងប្រភពផ្តល់ការងារជូនប្រជាជនយើងបានមួយចំនួនធំ ។

- **ដំណាំល្ហុងប្រេង** : ពីដើមដំណាំផ្តល់ប្រេងនៅកម្ពុជាយើងមានតែសណ្តែកដី ល្ង ដូង និងល្ហុងខ្វង ។ បច្ចុប្បន្នល្ហុងប្រេង (Jatropha Curcas) ជាដំណាំផ្តល់ប្រេងដ៏សំខាន់ ប្រើសម្រាប់ទាញយកប្រេង ហៅថាជីវឌីយ៉េសែល (Bio Diesel) ជំនួសឱ្យផូស៊ីលឌីយ៉េសែល (Fossil Diesel) ពិសេសក្នុងពេលមានវិបត្តិប្រេងឡើងថ្លៃ ។

ល្ហុងប្រេងជាដំណាំធន់នឹងភាពរាំងស្ងួត ដុះលូតលាស់ល្អលើដីពុំសូវមានជីជាតិ អាចទាញយកផលបានចាប់ពីអាយុ 2 ឬ 3 ឆ្នាំ ហើយអាចរស់បានរហូតដល់ 60 ឆ្នាំ ។ សាច់គ្រាប់ល្ហុងប្រេងផ្តល់ប្រេងពី 40-60% មានចំហេះល្អជាងផូស៊ីលឌីយ៉េសែលទៅទៀត ។

- **ដំណាំឧស្សាហកម្មផ្សេងៗទៀតមាន** : ថ្នាំជក់ មន កប្បាស ថ្មៃ ក្រចៅ និងត ។



*ល្ហុងប្រេង*



*ចម្ការកៅស៊ូ*

## 1.2. ការចិញ្ចឹមសត្វ

ការចិញ្ចឹមគោ និងក្របីមាននៅគ្រប់ខេត្តនៃប្រទេសកម្ពុជា ។ ការចិញ្ចឹមគោមានច្រើនជាងគេនៅខេត្តកំពង់ចាម តាកែវ កំពង់ស្ពឺ ព្រៃវែង កំពត និងសៀមរាប ។ រីឯក្របីវិញមានចិញ្ចឹមច្រើននៅខេត្តព្រៃវែង ស្វាយរៀង កំពង់ចាម ពោធិ៍សាត់ និងក្រចេះ ។

ជាទូទៅ ការចិញ្ចឹមគោក្របីនៅកម្ពុជាយើង មានលក្ខណៈតូចតាច ប្រព្រឹត្តទៅក្នុងរង្វង់គ្រួសារ ដើម្បីប្រើជាកម្លាំងអូសទាញក្នុងការងារស្រែចម្ការ ពុំមែនសំដៅយកសាច់ ឬទឹកដោះសម្រាប់ធ្វើការជួញដូរឡើយ ជាការចិញ្ចឹមសត្វបែបបយថាផល ខ្វះបច្ចេកទេសវិទ្យាសាស្ត្រ ដូចជាខ្វះជម្រើសពូជសត្វ ខ្វះថ្នាំចាក់ការពារព្យាបាល គ្មានក្រោលត្រឹមត្រូវ ... ។

ចំណែកសត្វចិញ្ចឹមដទៃទៀត មានជ្រូក និងបក្សីស្រុក ។ កសិករយើងបានចិញ្ចឹមចៀម ពពែសេះ ដំរីផងដែរ ។

ការចិញ្ចឹមសត្វជាប្រភពចំណូលថវិការបស់កសិករកម្ពុជាមួយចំនួនធំ បន្ថែមពីលើប្រាក់កម្រៃដែលបានមកពីការដាំដុះ ។ ការចិញ្ចឹមសត្វបានដើរតួនាទីកាន់តែសំខាន់ក្នុងវិស័យកសិកម្មកម្ពុជា ជាមួយនិងកំណើនចំនួនសត្វឬកំណើនថវិកាប្រចាំឆ្នាំ 2009 រហូត 4.4% ។

សព្វថ្ងៃយើងមានស្ថានីយចិញ្ចឹមសត្វមួយកន្លែងនៅភ្នំតាម៉ៅក្នុងខេត្តតាកែវ ដែលមានពូជគោល្អៗជាច្រើន ។ យោលទៅតាមសណ្ឋានដី និងអាកាសធាតុ ប្រទេសកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការពង្រីកវិស័យនេះ ។ ប៉ុន្តែអ្វីដែលជាកត្តាអវិជ្ជមាននោះ គឺកង្វះទុន និងបច្ចេកវិទ្យា ។

## 1.3. ការនេសាទ

កាលពីមុនសង្គ្រាមឆ្នាំ 1970 ប្រទេសកម្ពុជា ជាប្រទេសមួយដែលសម្បូរត្រី ដោយសារលក្ខខណ្ឌបរិស្ថានធម្មជាតិ និងសង្គមនៅកម្ពុជា ផ្តល់ភាពអនុគ្រោះច្រើនដូចជា ភាពសម្បូរព្រៃលិចទឹក របបទឹកឡើង និងទឹកស្រកទៀងទាត់ ការប្រព្រឹត្តល្មើសច្បាប់នេសាទមានតិចតួច (ការអនុវត្តច្បាប់នេសាទមានប្រសិទ្ធភាពច្រើន) ។ ផ្ទុយទៅវិញចាប់ពីមានសង្គ្រាមមក លក្ខខណ្ឌអំណោយផលទាំងនោះត្រូវបានបំផ្លិចបំផ្លាញ ។ ព្រៃលិចទឹកដែលជាជម្រកត្រីពងនិងញាស់កូន ត្រូវគេកាប់បំផ្លាញស្ទើរអស់ ទាំងព្រៃទឹកសាប និងព្រៃទឹកប្រៃ ។ ការប្រព្រឹត្តល្មើសច្បាប់នេសាទមានច្រើនដូចជា នេសាទត្រីនៅរដូវត្រីពង ការប្រើអគ្គិសនី និងគ្រាប់បែកជាឧបករណ៍នេសាទខុសច្បាប់ដែលធ្វើឱ្យត្រីខ្លះជិតផុតពូជ ឬក៏ផុតពូជ ។

មជ្ឈមណ្ឌលនេសាទទឹកសាបដ៏ធំបំផុត គឺបឹងទន្លេសាប ដែលធ្លាប់ល្បីថា សម្បូរត្រីទឹកសាបបំផុតក្នុងពិភពលោក (10តោនក្នុងមួយគីឡូម៉ែត្រការេមុនឆ្នាំ 1970) ។ សព្វថ្ងៃបរិមាណត្រីក្នុងបឹងមាន

ការថយចុះ ហើយនេសាទបានតែត្រីតូចៗទៀតផង ។ ការនេសាទទឹកប្រៃប្រព្រឹត្តទៅតាមឆ្នេរជារៀងរាល់ឆ្នាំពីព្រំដែនថៃដល់ព្រំដែនវៀតណាម ។ សមុទ្រកម្ពុជាយើងក៏សម្បូរត្រីណាស់ដែរ ព្រោះជាប្រភេទសមុទ្រស្ងប់ សម្បូរជម្រកនិងចំណីអាហារ ... ។



*ការនេសាទត្រីនៅបឹងទន្លេសាប*

ផលិតផលត្រីនៅឆ្នាំ 2007 មានប្រហាក់ប្រហែលគ្នានឹងឆ្នាំ 2006 ដែរ ។ នៅឆ្នាំ 2007 ផលត្រីសមុទ្រ និងវារីវប្បកម្មកើនបានតិចតួចគឺ 5% និង 3.1% នៅពេលដែលត្រីទឹកសាបមានការថយចុះមកនៅត្រឹម 6.4% ។ ផលិតផលត្រីសរុបសង្ឃឹមថាមានការកើនឡើងតិចតួចគឺ 0.8% នៅឆ្នាំ 2007 ដែលបានចុះមកនៅត្រឹម 3.8% នៅឆ្នាំ 2006 ។ ផលិតផលត្រីនៅឆ្នាំ 2009 សង្ឃឹមថានឹងកើនដល់ 0.8% ។ ការនេសាទខុសច្បាប់ និងការបំផ្លាញជម្រកត្រី នាំមកនូវផលប៉ះពាល់ដល់កំណើនបរិមាណនេសាទ ។

ដោយសារតែបរិមាណត្រីថយចុះ ហើយបរិមាណត្រីនេសាទបានថយចុះក្នុងពេលសព្វថ្ងៃនេះ គេបែរមុខរកការចិញ្ចឹមត្រីវិញ ។

## 2. ឧស្សាហកម្មកម្ពុជា

ឧស្សាហកម្ម គឺជាសំណុំសកម្មភាពសេដ្ឋកិច្ច ដែលផលិតគ្រឿងសម្ភារៈតាមការប្លែងភាពនិងការប្រើប្រាស់រូបធាតុដើម ។ *ឧទាហរណ៍* : ឧស្សាហកម្មដែក ប្រើប្រាស់រ៉ែដែកដើម្បីប្លែងទៅជាដែកថែប ដែកស្នឹត ដែកបន្ទះ ដែកបំពង់ ... ។ ឧស្សាហកម្មរថយន្តប្រើប្រាស់ផលិតផលពាក់កណ្តាលសម្រេចផ្សេងៗ ដើម្បីបញ្ចេញជាផលិតផលសម្រេច គឺរថយន្ត ។ ឧស្សាហកម្មអាហារប្លែងផលិតផលកសិកម្មឱ្យទៅជាអាហារកំប៉ុង ដូចជាត្រីខប្រអប់ សាច់ខកំប៉ុង បន្លែកំប៉ុង ... ។

នៅប្រទេសកម្ពុជា សកម្មភាពសេដ្ឋកិច្ចផ្នែកនេះ មិនទាន់ទទួលបានការលូតលាស់ទេ។ គេឃើញមានតែរោងចក្រតូចៗ ផលិតមុខទំនិញសម្រាប់បំពេញតម្រូវការក្នុងស្រុកបន្តិចបន្តួច មិនទាន់ឆ្លើយតបនឹងតម្រូវការប្រើប្រាស់បានឡើយ។ ក្នុងបណ្ដារោងចក្រទាំងនោះ គេឃើញមានតែឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងឧស្សាហកម្មសំណង់ទេដែលលូតលាស់ជាងគេ ក៏ប៉ុន្តែវិស័យនេះជួបប្រទះនឹងការប្រឈមដូចជា រោចក្រខ្លះត្រូវបិទទ្វារ ខ្លះផ្អាកដំណើរការ ខ្លះមានដំណើរការឡើងវិញ ខ្លះបង្កើតថ្មី ហើយការងារសំណង់ ក៏ស្ថិតក្នុងស្ថានភាពបែបនេះដែរ។ សិប្បកម្មប្រពៃណី នៅតែដើរតួយ៉ាងសំខាន់ក្នុងការផលិតមុខទំនិញបំពេញតម្រូវការរបស់ប្រជារាស្ត្រខ្មែរ។



*ឧស្សាហកម្មកាត់ដេរ*

ប្រទេសកម្ពុជាធ្លាប់រស់នៅក្រោមអាណានិគមបារាំងអស់រយៈពេល 90ឆ្នាំ (1863-1953) មហាអំណាចអាណានិគមមួយនេះ មិនបានយកចិត្តទុកដាក់សាងសង់រោងចក្រឧស្សាហកម្មនៅលើទឹកដីប្រទេសខ្មែរសោះឡើយ។ គេឃើញមានតែក្រុមហ៊ុនផលិតទឹកកក និងស្រាបៀឥណ្ឌូចិន (B.G.I = Brasserie et Glacerie de l'Indochine) មួយប៉ុណ្ណោះ។ នៅមុនឆ្នាំ 1970 សម័យសង្គមរាស្ត្រនិយម (1955-1970) ឧស្សាហកម្មកម្ពុជាមានការលូតលាស់មួយកម្រិត គេឃើញមានរោងចក្ររដ្ឋចំនួន 28 និងរោងចក្រឯកជនធុនតូច និងមធ្យមចំនួន 3 700។ ក្រោយឆ្នាំ 1970 សមិទ្ធិទាំងនោះត្រូវបំផ្លិចបំផ្លាញដោយសារសង្គ្រាម និងរបបកម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហម)។ ក្រោយឆ្នាំ 1993 រាជរដ្ឋាភិបាលបានខិតខំអភិវឌ្ឍវិស័យឧស្សាហកម្មតាមបែបសេដ្ឋកិច្ចទីផ្សារ ដែលគ្រប់គ្រងដោយឯកជននិងមានការប្រកួតប្រជែង។ ឧស្សាហកម្មកម្ពុជាច្រើនប្រមូលផ្ដុំនៅទីក្រុងភ្នំពេញ និងនៅតំបន់ជុំវិញក្រុង បង្កើតបានជាប៉ូលឧស្សាហកម្មមួយដែលក្នុងនោះគេឃើញមានរោងចក្រកែវ ស័ង្កសី ចំណីសត្វ

សុរាគារ ទឹកក្រូច កៅស៊ូកង់រថយន្ត ស្រាបៀ ក្តារបន្ទះ ម៉ាស៊ីនកិនស្រូវ សហគ្រាសកាត់ដេរសម្លៀកបំពាក់ សហគ្រាសសំណង់ ។ នៅខេត្តខ្លះទៀតក៏មានរោងចក្រខ្លះៗដែរដូចជារោងចក្រស៊ីម៉ងត៍នៅកំពត ស្រាបៀនៅខេត្តកណ្តាល និងខេត្តព្រះសីហនុ រោងចក្រស្ករនៅខេត្តកោះកុង ។

យោងតាមសន្និបាតបូកសរុបការងារឆ្នាំ 2009 ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលបានបង្ហាញថា ផ្នែកឧស្សាហកម្មយើងមានរោងចក្រធុនមធ្យម 556 កន្លែង កើនបាន 2.5% ធៀបឆ្នាំ 2008 ប្រើប្រាស់កម្លាំងពលករចំនួន 392 373 នាក់ ។ ឧស្សាហកម្មធុនតូច និងសិប្បកម្មរីកដុះដាលបានចំនួន 35 560 មូលដ្ឋាន កើនបាន 8.4% និងមានពលករ 12 532 នាក់ កើនបាន 29% ។ តម្លៃបរិមាណផលិតផលសរុបមានចំនួន2 959 ពាន់លានរៀល កើនពី 9% ធៀបនឹងឆ្នាំ 2008 ។

សព្វថ្ងៃឧស្សាហកម្ម ដែលមានសកម្មភាពខ្លាំងក្លានៅកម្ពុជា មានឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ សហគ្រាសសំណង់ រោងចក្រអគ្គិសនី រោងចក្រអាហារ ភេសជ្ជៈ បារីជាដើម ។

## 3. គមនាគមន៍កម្ពុជា




*ផែនទីគមនាគមន៍កម្ពុជា*

គេអាចនិយាយបានថា គមនាគមន៍ជាសរសៃឈាមនៃសេដ្ឋកិច្ចជាតិ ព្រោះថាគមនាគមន៍ជាសកម្មភាពបម្រើឱ្យគ្រប់ផ្នែកនៃសេដ្ឋកិច្ច ។ បើគ្មានគមនាគមន៍ អ្វីៗទាំងអស់នឹងស្ទះដំណើរការ គ្មានអភិវឌ្ឍន៍ ។ គមនាគមន៍អាចប្រៀបប្រដូចបានទៅនឹងសរសៃឈាមដែលហូរនាំឈាមទៅចិញ្ចឹមសារពាង្គកាយមនុស្សឱ្យរីកលូតលាស់ដូច្នោះដែរ ។

ជាទូទៅ គមនាគមន៍ប្រទេសកម្ពុជា មានលក្ខណៈអន់ថយ នៅមិនទាន់រីកចម្រើនទូទាំងប្រទេសនៅឡើយ ។ តែជាបណ្តើរៗ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ពង្រីកវិស័យនេះ ទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ ព្រោះគេឃើញមានការសាងសង់ផ្លូវថ្នល់ជាច្រើនខ្សែ ស្ពានសំខាន់ៗជាច្រើនកន្លែង ។ ចំពោះវិស័យទូរគមនាគមន៍វិញ មានក្រុមហ៊ុនមួយចំនួនធំបានបោះទុនរកស៊ីក្នុងវិស័យនេះ ដែលធ្វើឱ្យទំនាក់ទំនង ពីកន្លែងមួយទៅកន្លែងមួយទៀត ទូទាំងព្រះរាជាណាចក្រកម្ពុជា និងជាមួយអន្តរជាតិប្រព្រឹត្តទៅបានយ៉ាងងាយស្រួល និងឆាប់រហ័ស ។

ប្រទេសកម្ពុជាមានផ្លូវគមនាគមន៍គ្រប់ប្រភេទ គឺផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស សម្រាប់ដឹកជញ្ជូនទាំងក្នុង និងក្រៅប្រទេស ។

ផ្លូវគោកមានពីរប្រភេទ គឺផ្លូវថ្នល់ និងផ្លូវដែក ដែលក្នុងនោះផ្លូវថ្នល់មានសារៈសំខាន់ជាងគេទាំងប្រវែង និងសកម្មភាព ។ ផ្លូវថ្នល់មានទាំងអស់ប្រវែង 38 093 km ដែលក្នុងនោះ 2 977 km ជាផ្លូវចាក់កៅស៊ូ និង 35 116 km មិនទាន់ចាក់កៅស៊ូ (ឆ្នាំ 2007) ។ ផ្លូវដែកមានពីរខ្សែ មានប្រវែងសរុប 651 km និងមានលក្ខណៈបុរាណនៅឡើយ ។ កម្ពុជាក៏ស្ថិតក្នុងគម្រោងមួយមានឈ្មោះថា "បណ្តាញផ្លូវដែកសិង្ហបុរី-គុនមិញ" សរសេរកាត់ថា SKRL (Singapore-Kunming Rail Link) ដែលមានប្រវែងសរុប 5 382 km ភ្ជាប់ពីទីក្រុងសិង្ហបុរី បាងកក ភ្នំពេញ ហូជីមិញ ហាណូយ និងគុនមិញ (ខេត្តយូណានប្រទេសចិន) ដែលបានដាក់ស្នើដល់កិច្ចប្រជុំកំពូលអាស៊ានកាលពីឆ្នាំ 1995 ។ កម្ពុជាត្រូវសាងសង់ផ្លូវដែកប្រវែង 255 km ភ្ជាប់ភ្នំពេញទៅឡុកនិញព្រំដែនវៀតណាមឱ្យហើយរួចរាល់នៅឆ្នាំ 2015 ។

ផ្លូវទឹកមានប្រវែងទាំងអស់ 2 400km (ឆ្នាំ 2008) ។ នាវាចរណ៍អាចប្រព្រឹត្តទៅតាមទន្លេមេគង្គ ទន្លេសាប បឹងទន្លេសាប ទន្លេបាសាក់ ដៃនានា និងតាមឆ្នេរ ។ នាវាចរណ៍តាមទន្លេសំខាន់ជាងគេ គឺទន្លេមេគង្គពីក្រចេះទៅសមុទ្រ ។ នាវាចរណ៍តាមឆ្នេរភ្ជាប់ទីក្រុងព្រះសីហនុទៅទីក្រុងខេមរភូមិន្ទ(ខេត្តកោះកុង) ។

ភ្នំពេញជាកំពង់ផែទន្លេផង និងជាកំពង់ផែសមុទ្រផង ព្រោះនាវាសមុទ្រធុនមធ្យមអាចចូលចតគ្រប់រដូវ ។ ក្រៅពីកំពង់ផែភ្នំពេញមានកំពង់ផែកំពង់ចាម ក្រចេះ កំពង់ឆ្នាំង សៀមរាប និងស្ទឹងត្រែង (បានតែនៅរដូវទឹកឡើង) ។ កំពង់ផែក្រុងព្រះសីហនុជាកំពង់ផែថ្នាក់អន្តរជាតិ អាចឱ្យនាវាសមុទ្រធំៗចេញចូលគ្រប់ពេល ។ កំពង់ផែរាមជាមូលដ្ឋានកងទ័ពជើងទឹករបស់កងយោធពលខេមរភូមិន្ទ ។ កំពង់

ផែក្រុងខេមរភូមិន្ទសម្រាប់ដឹកជញ្ជូនអ្នកដំណើរ និងទំនិញភ្ជាប់ទៅកំពង់ផែក្រុងព្រះសីហនុ ។ ប្រទេសកម្ពុជាមាននាវាជំនួញចំនួន 626 គ្រឿង និងនាវាបរទេសចំនួន 467 គ្រឿងដែលចេញចូលរកស៊ី ។




*សកម្មភាពនៅកំពង់ផែសមុទ្រ ខេត្តព្រះសីហនុ*

ការដឹកជញ្ជូនតាមផ្លូវអាកាសមានសកម្មភាពកាន់តែខ្លាំងឡើងជាលំដាប់ ។ យើងមានអាកាសយានដ្ឋានអន្តរជាតិពីរ គឺអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋានអន្តរជាតិសៀមរាប ។ ក្រៅពីនេះមានអាកាសយានដ្ឋានក្នុងស្រុកសម្រាប់យន្តហោះដឹកជញ្ជូនអ្នកដំណើររវាងទីក្រុងភ្នំពេញនិងទីក្រុងនៃខេត្តមួយចំនួនដូចជា ក្រុងបាត់ដំបង បានលុង(រតនគិរី) សែនមនោរម្យ (មណ្ឌលគិរី) ខេមរភូមិន្ទ ក្រុងស្ទឹងត្រែង ... ។ អាកាសយានដ្ឋានសៀមរាបមានសកម្មភាពមមាញឹកខាងដឹកជញ្ជូនភ្ញៀវទេសចរ ។

## 4. ពាណិជ្ជកម្មកម្ពុជា

ដោយវិស័យដទៃទៀតនៃសេដ្ឋកិច្ចកម្ពុជាស្ថិតក្នុងភាពអន់ថយ ដូចនេះពាណិជ្ជកម្មក៏ទន់ខ្សោយទៅតាមនោះដែរតាំងពីដើមរៀងដរាបមក ។ មុនឆ្នាំ 1993 ពាណិជ្ជកម្មកម្ពុជាជាការកាន់កាប់ផ្តាច់មុខរបស់រដ្ឋ ។ ក្រោយមក ការអនុវត្តរបបសេដ្ឋកិច្ចទីផ្សារបានផ្តល់ឱកាសឱ្យក្រុមហ៊ុនឯកជនជាច្រើនចូលមកប្រកបរបរអាហារិណានីហារិណានៅកម្ពុជា ធ្វើឱ្យវិស័យនេះមានសកម្មភាពយ៉ាងមមាញឹក ។

ពាណិជ្ជកម្ម ឬជំនួញ គឺជាសកម្មភាពទិញ លក់ ដោះដូរទំនិញ គ្រឿងបរិភោគ ឬលក់សេវា ។ ដូចនេះ បើនិយាយពីពាណិជ្ជកម្ម គឺគេត្រូវនិយាយពីការទិញ ការលក់ ទំនិញនិងអតិថិជនអ្នកទិញដូរ

សម្រាប់ជំនួញក្នុងស្រុក ពីការនាំចេញ ការនាំចូល ដៃគូពាណិជ្ជកម្ម និងជញ្ជីងពាណិជ្ជកម្មសម្រាប់ជំនួញក្រៅប្រទេស ។ ជំនួញក្នុងស្រុកជានារ៉ាប់រងបាននូវការដោះដូរមុខទំនិញទាំងក្នុងស្រុក និងមកពីបរទេសបានយ៉ាងរលូន ទោះបីពេលខ្លះតម្លៃទំនិញមានការប្រែប្រួលគួរឱ្យកត់សម្គាល់ក្តី ។ តទៅនេះ យើងនឹងលើកយកពាណិជ្ជកម្មក្រៅប្រទេសមកសិក្សា ។



*ការដឹកជញ្ជូនទំនិញនៅក្រុងកំពង់សោម*

## 4.1. ការនាំចេញ

សម្រាប់ផ្នែកនេះ ក្រសួងពាណិជ្ជកម្មបានចេញអាជ្ញាប័ណ្ណឱ្យក្រុមហ៊ុនដែលមានច្បាប់ត្រឹមត្រូវនាំចេញនូវទំនិញក្នុងស្រុកទៅកាន់បណ្តាប្រទេសមួយចំនួនក្នុងពិភពលោកដូចជា សហគមន៍អឺរ៉ុប សហរដ្ឋអាមេរិក អូស្ត្រាលី ថៃ ចិន ... ។ ទំនិញនាំចេញសំខាន់ជាងគេ គឺសម្លៀកបំពាក់ផលិតផលកសិកម្ម (អង្ករ ពោតក្រហម សណ្តែកសៀង ដំរកៅស៊ូ ផលនេសាទ...) ស្រាបៀរអង្គរ និងថាយត័រ ។

## 4.2. ការនាំចូល

ប្រទេសកម្ពុជានាំចូលទំនិញច្រើនបែបយ៉ាងដូចជា អង្ករ ម្សៅមី ប្រេងឥន្ធនៈ ឧស្ម័ន យានយន្ត គ្រឿងយន្តកសិកម្ម គ្រឿងសំណង់ គ្រឿងអគ្គិសនី ឧបករណ៍អេឡិចត្រូនិក ឧបករណ៍សម្រាប់រោងចក្រកាត់ដេរ ភេសជ្ជៈគ្រប់ប្រភេទ ជីគីមី ថ្នាំពេទ្យ បារី ស្ករស ក្រដាស បន្លែ ផ្លែឈើ ... ។ ទំនិញទាំងនោះនាំចូលមកពីបណ្តាប្រទេសនានានៅអាស៊ី អឺរ៉ុប និងសហរដ្ឋអាមេរិក ។

## ៤.១. ជញ្ជីងពាណិជ្ជកម្ម

ដោយសារការនាំចូលមានច្រើនជាងការនាំចេញ ជញ្ជីងពាណិជ្ជកម្មកម្ពុជាតែងមានឱនភាព ។ នៅឆ្នាំ 2009 ជំនួញក្រៅប្រទេសមានការថយចុះគួរឱ្យកត់សម្គាល់ ការនាំចេញចុះរហ័សជាងការនាំចូល ។ ការនាំចេញសម្លៀកបំពាក់ និងបារីថយចុះយ៉ាងច្រើន តែមុខទំនិញផ្សេងទៀតនៅរក្សាកំណើនប្រាកដប្រជា ពិសេសផលិតផលកសិកម្ម ។ ឱនភាពជញ្ជីងពាណិជ្ជកម្មឡើងដល់ 1.៨ ពាន់លានដុល្លារ ត្រូវជា 18.1% នៃផលិតផលក្នុងស្រុកសរុប (GDP = Gross Domestic Products) ។

| ជញ្ជីងពាណិជ្ជកម្មនៅកម្ពុជា(គិតជាលានដុល្លារអាមេរិក) | | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំ | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
| ការនាំចេញ | 2 910 | 3 693 | 4 088 | 4 708 | 4 130 | 4 427 |
| ការនាំចូល | 3 918 | 4 771 | 5 471 | 6 509 | 6 004 | 6 227 |

### ✍ ពាក្យគន្លឹះ

- **ឧស្សាហកម្មធុនធ្ងន់** : ហៅម្យ៉ាងទៀតថា ឧស្សាហកម្មមូលដ្ឋាន គឺជាប្រភេទឧស្សាហកម្មដែលផលិតរូបធាតុដើម ឬផលិតផលពាក់កណ្ដាលសម្រេច ។ *ឧទាហរណ៍* : ការជីកយករ៉ែ លោហកម្មដែក ឬក្រៅពីដែក ចម្រាញ់ប្រេងកាត ... ។
- **ឧស្សាហកម្មធុនស្រាល** : ជាប្រភេទឧស្សាហកម្មដែលបំប្លែងរូបធាតុដើម ឬផលិតផលពាក់កណ្ដាលសម្រេចឱ្យទៅជាគ្រឿងប្រើប្រាស់ ។ *ឧទាហរណ៍* : ឧស្សាហកម្មអាហារកំប៉ុង សំណង់គ្រឿងអគ្គិសនី និងអេឡិចត្រូនិក សំណង់គ្រឿងយន្ត ... ។
- **តុល្យភាព** : លំនឹង (តុល្យភាពជញ្ជីងពាណិជ្ជកម្ម=លំនឹងជញ្ជីងពាណិជ្ជកម្មបានមកពីការនាំចេញ ≥ ការនាំចូល) ។
- **ឱនភាព** : ភាពអន់ថយ (ឱនភាពជញ្ជីងពាណិជ្ជកម្ម=ជញ្ជីងពាណិជ្ជកម្មបាត់បង់លំនឹង គឺការខាតដោយការនាំចូលច្រើនជាងការនាំចេញ) ។

## ? សំណួរ

1. តើយើងអាចបង្កើនទិន្នផល និងផលិតផលស្រូវបានតាមមធ្យោបាយណាខ្លះ ?
2. តើការប្រើប្រាស់គ្រឿងយន្តកសិកម្ម (គោយន្ត ត្រាក់ទ័រ ម៉ាស៊ីនស្ទូង ម៉ាស៊ីនច្រូតកាត់ ម៉ាស៊ីនបោកបែន) ជាការចាំបាច់ដែរ ឬទេនៅកម្ពុជាបច្ចុប្បន្ន ? ចូរពន្យល់ ។
3. តើការពង្រីកការចិញ្ចឹម ត្រីនិងសត្វនៅកម្ពុជាជាការល្អប្រសើរដែរ ឬទេ ? ចូរពន្យល់ ។
4. ចូរនិយាយអំពីមុខងារកសិកម្មក្នុងវិស័យសេដ្ឋកិច្ចជាតិ ។
5. តើវិស័យគមនាគមន៍កម្ពុជាទទួលបានការរីកចម្រើនដែរ ឬទេ ? ចូរពន្យល់ ។
6. បច្ចុប្បន្ននេះ តើអ្នកយល់ថា ប្រទេសកម្ពុជាអាចមានលទ្ធភាពពង្រីកឧស្សាហកម្មណាខ្លះ ?
7. ជាទូទៅ ពាណិជ្ជកម្មក្រៅប្រទេសកម្ពុជាស្ថិតក្នុងស្ថានភាពដូចម្ដេច ? ចូរពន្យល់ ។
8. ដើម្បីរួមចំណែកកាត់បន្ថយឱនភាពជញ្ជីងពាណិជ្ជកម្ម តើយើងត្រូវធ្វើដូចម្ដេច ?

## ? សំណួរបញ្ចប់ជំពូកទី១

**I. ចូរគូសសញ្ញា ✓ មុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់**

1. ក្នុងបណ្តាពូជស្រូវខាងក្រោម ណាមួយជាពូជស្រូវប្រពៃណី ?

☐ ក. ផ្ការំចេក ☐ ខ. ផ្ការំចង់

☐ គ. ផ្ការំដួល ☐ ឃ. ផ្កាខ្ញី ។

2. ក្នុងបណ្តារោងចក្រខាងក្រោម តើរោងចក្រណាមួយដែលសំខាន់ជាងគេ ?

☐ ក. រោងចក្រអគ្គិសនី ☐ ខ. ការដ្ឋានសំណង់

☐ គ. រោងចក្រកាត់ដេរ ☐ ឃ. រោងចក្រស៊ីម៉ង់ត៍ ។

**II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ**

1. ការប្រើប្រាស់គ្រឿងយន្តកសិកម្មអាចជួយ ................................ ដល់កសិករយើង ។
2. មធ្យោបាយមួយ ដើម្បីកាត់បន្ថយឱនភាពជញ្ជីងពាណិជ្ជកម្មយើង គឺ ............................ ។

**III. ចូរផ្គូផ្គងផ្នែក A និង B រួចសរសេរចម្លើយត្រូវក្នុងផ្នែក C**

| A (ចម្ងាយផ្លូវ) | B (ប្រភេទផ្លូវ) | ចម្លើយ (C) |
|---|---|---|
| 1. 255 km | ក. ផ្លូវក្រាលថ្ម | 1. → ..... |
| 2. 2 977 km | ខ. ផ្លូវចាក់កៅស៊ូ | 2. → ..... |
| 3. 2 400 km | គ. ផ្លូវដែកដែលស្ថិតក្នុងគម្រោងអាស៊ាននៅកម្ពុជា | 3. → ..... |
| | ឃ. ផ្លូវទឹក | |

**IV. សំណួរត្រិះរិះ**

1. ចូររាប់ឈ្មោះមណ្ឌលរ៉ែទាំងអស់នៅកម្ពុជា ។
2. ចូរនិយាយអំពីស្ថានភាពរ៉ែកម្ពុជានៅមណ្ឌលណាមួយ ដែលទទួលរងការបាត់បង់ទៅ ។
3. ហេតុអ្វីបានជាប្រទេសកម្ពុជាយើងសម្បូរភោគទ្រព្យទេសចរណ៍ធម្មជាតិ ? ចូររាប់ឈ្មោះភោគទ្រព្យទេសចរណ៍ទាំងនោះឱ្យបាន 4 ប្រភេទ ព្រមទាំងបញ្ជាក់ដោយឧទាហរណ៍ផង ។
4. ចូររាប់ឈ្មោះពូជស្រូវ ពោត និងសណ្តែកបាយ ដែលដាក់ជូនប្រជាកសិករប្រើប្រាស់ដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ។
5. ចូរនិយាយអំពីសារៈសំខាន់សេដ្ឋកិច្ចផ្នែកឧស្សាហកម្មកម្ពុជា ។
6. ចូរនិយាយអំពីស្ថានភាពពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជានៅឆ្នាំ 2009 ។

# ជំពូកទី 2 ប្រទេសមួយចំនួននៃអាស៊ី




*គំនូសឆ្នូតជាទីតាំងអាស៊ីអាគ្នេយ៍*

ក្នុងជំពូកទីមួយ យើងបានសិក្សារួចមកហើយពីភោគទ្រព្យរ៉ែ ភោគទ្រព្យទេសចរណ៍ធម្មជាតិ និងសេដ្ឋកិច្ចកម្ពុជា។ តទៅនេះ យើងនឹងលើកយកប្រទេសធំពីរនៃអាស៊ីគឺប្រទេសចិននិងឥណ្ឌា និងប្រទេសបីទៀតនៃអាស៊ីអាគ្នេយ៍មាន ម៉ាឡេស៊ី ព្រុយណេ និងមីយ៉ាន់ម៉ា មកសិក្សាលើចំណុចសំខាន់បីគឺស្ថានភាពប្រជាជន ប្រព័ន្ធនយោបាយ និងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ។

មេរៀនទី

# 1 ប្រទេសចិន

**ចប់មេរៀននេះ សិស្សអាច**

- បង្ហាញពីស្ថានភាពប្រជាជន នយោបាយ និងសេដ្ឋកិច្ច ។

ចិនជាប្រទេសមួយដែលមានផ្ទៃដីធំជាងគេនៃទ្វីបអាស៊ី(9.6លានkm$^2$ )មានប្រជាជនច្រើនជាងគេនៅក្នុងពិភពលោក តែសព្វថ្ងៃប្រទេសនេះកំពុងខិតខំអភិវឌ្ឍសេដ្ឋកិច្ចខ្លួនយ៉ាងខ្លាំងក្លា ហើយសម្រេចបានជោគជ័យគួរឱ្យកោតសរសើរ ។




*ផែនទីសណ្ឋានដីប្រទេសចិន*

ប្រទេសចិនស្ថិតនៅចន្លោះខ្សែបណ្ដោយទី 74° ដល់ទី 135° នៃរយៈបណ្ដោយខាងកើត និងចន្លោះខ្សែស្របទី 18° ដល់ទី 53° នៃរយៈទទឹងខាងជើង ។ ចាប់ពីជួរភ្នំហិម៉ាល័យ សណ្ឋានដីមានផ្ទៃចុះជាថ្នាក់ៗរហូតដល់វាលទំនាបអាស៊ីកណ្ដាល និងទំនាបល្បាប់ធំៗនៃភាគខាងកើត ។ ដីដែលអាចភ្ជួររាស់បានមានប្រហែល 10% នៃផ្ទៃប្រទេស ។ របបខ្យល់មូសុងបង្កើតឱ្យមានភាពផ្ទុយគ្នាយ៉ាងខ្លាំងរវាងចិនភាគខាងកើតដែលសើមខ្លាំងដោយសារភ្លៀងវស្សានរដូវ និងអនុគ្រោះច្រើនដល់ដំណាំស្រូវឡើងទឹកនិងចិនភាគខាងលិចដែលស្ងួតនិងស្ងួតហែង ។ នៅភាគខាងកើតប្រទេសចិនដែលភាពរាំងស្ងួតនិងទឹកជន់លិចកើតមានឆ្លាស់គ្នា ភាពម្ចាស់ការលើទឹកនៅតែជាបញ្ហាសំខាន់ ។ តំបន់ដែលអនុគ្រោះខ្លាំងដល់ការងារកសិកម្មតែងមានមនុស្សរស់នៅកុះករ ។ ទីប្រជុំជនធំៗរបស់ប្រទេសក៏រីកដុះដាលនៅទីនោះ ដែលមួយចំនួនធំបានទទួលផលចំណេញច្រើនពីការបើកចំហសេដ្ឋកិច្ចតំបន់ឆ្នេរ ។

# 1. ស្ថានភាពប្រជាជនចិន

## 1.1. ទម្រង់ប្រជាសាស្ត្រ

បញ្ហាប្រជាសាស្ត្រចោទជាកង្វល់មួយដ៏ចម្បងចំពោះប្រទេសចិនតាំងពីយូរមកហើយ ។ នៅចន្លោះឆ្នាំ 1950 និង 1970 ចំនួនប្រជាជនបានកើនពី 220 ទៅ 435 លាននាក់ ។ កង្វះទំនើបកម្មផ្នែកបច្ចេកទេស និងភាពគ្មានការវិវឌ្ឍនៃសង្គមប្រពៃណីមួយ មិនអាចឆ្លើយតបនៅនឹងបន្ទុះប្រជាសាស្ត្រនោះទេ ។ ប្រទេសត្រូវធ្លាក់ទៅក្នុងភាពអន់ថយដែលជាហេតុនាំឱ្យវិបត្តិនៃរបបសាធារណរដ្ឋកាន់តែធ្ងន់ធ្ងរ ។




*ប្រជាជនចិន*

ប្រទេសចិនបានចូលទៅក្នុងដំណើរវិវត្តន៍នៃអន្តរភាពប្រជាសាស្ត្រចាប់ពីឆ្នាំ 1950 ។ ទោះបីឆ្លងកាត់សម័យកាល "មហាលោតផ្លោះ" (1958-1961) និង "បដិវត្តន៍វប្បធម៌" ក៏ប្រជាជនចិនបានកើនឡើងទ្វេដងនៅចន្លោះឆ្នាំ 1953 និង 1983 គឺពី 583 លានទៅ 1000 លាននាក់ ហើយដែលបច្ចុប្បន្នឡើងដល់ 1 338.612 លាន(2009) ។ អត្រាមរណៈចុះមកនៅត្រឹម 0.75% ហើយអត្រាសង្ឃឹមរស់ពីកំណើតកើនពីរដងដែរ(73.47 ឆ្នាំ) ។ អំណិះតទៅ ប្រទេសចិនកាន់តែខិតទៅកៀកទីបញ្ចប់នៃអន្តរភាពប្រជាសាស្ត្រហើយ ។ អត្រាជាតិប្រមាណបានចាប់ផ្តើមធ្លាក់ចុះនៅបណ្តាឆ្នាំ 1970 ហើយដែលសព្វថ្ងៃនៅត្រឹម 1.4% ។ ចំណែកអត្រាលទ្ធភាពបង្កកំណើតរបស់ស្ត្រីវិញមានត្រឹម 1.7 នាក់ ។ លើចំណុចនេះប្រទេសចិនរត់កាន់តែប្រកិតៗទៅនឹងប្រទេសអភិវឌ្ឍយ៉ាងប្រាកដ ។

## 1.2. នយោបាយ (កូនទោល)

ការថយចុះនៃអត្រាកំណើតធម្មជាតិបច្ចុប្បន្នមកនៅត្រឹម 0.65% (2009) ជាលទ្ធផលនៃការអនុវត្តនយោបាយប្រឆាំងកំណើតរបស់រដ្ឋាភិបាលចិន ។ តាំងតែពីឆ្នាំ 1953 មកម្ល៉េះ លោក ជូ អេនឡាយ (1898-1976) បានលើកទឹកចិត្តដល់ផែនការកំណត់កំណើតដោយអនុញ្ញាតឱ្យមានការរំលូតកូន ការពន្យារកំណើត ការធ្វើឱ្យអារ និងតម្រូវឱ្យពន្យារអាយុរៀបការ ។ នៅបណ្តាឆ្នាំ 1960 គេតម្រូវឱ្យគូស្រករមានកូនតែពីរនាក់ បន្ទាប់មកនៅឆ្នាំ 1979 ឱ្យមានតែកូនមួយប៉ុណ្ណោះ ។

មធ្យោបាយដាក់ការគាបសង្កត់ទៅលើប្រជាជន អនុវត្តមិនបានស្មើគ្នាទេ ។ នយោបាយ "កូនទោល" មានប្រសិទ្ធភាពតែនៅក្នុងទីក្រុង ដែលនៅទីនោះម្នាក់ៗគិតដល់បញ្ហារស់នៅបានគាប់ប្រសើរនិងខ្លាចក្រែងដល់ទោសបញ្ញត្តិដែលចែងដោយអង្គភាពការងារ ។ នៅជនបទស្រែចម្ការវិញ ការត្រួតពិនិត្យទៅលើប្រជាកសិករជួបនឹងការលំបាកខ្លាំង ដោយសារតែហេតុនេះទើបគេក៏អនុញ្ញាតឱ្យមានកូនទីពីរម្នាក់ទៀតនៅក្រោយពេលបង្កើតកូនស្រីបានបួនឆ្នាំ ។

ចំណោលប្រជាសាស្ត្រមួយដែលថាប្រជាជនចិននឹងឡើងដល់ 1.3 ពាន់លាននាក់នៅឆ្នាំ 2000 ហាក់ដូចជាសម្រេចបាននៅពេលបច្ចុប្បន្ននេះ ប៉ុន្តែបញ្ហាប្រជាសាស្ត្រនៅតែជាបញ្ហាគួរឱ្យបារម្ភ ។ ឥទ្ធិពលនៃអន្តរភាពប្រជាសាស្ត្រនិងមិនអាចធ្វើឱ្យចំនួនប្រជាជនស្ថិតក្នុងលំនឹងបានមុនឆ្នាំ 2025 សោះឡើយ ។ ប្រទេសចិននឹងត្រូវប្រឈមមុខទៅនឹងបញ្ហាថ្មី គឺភាពចំណាស់នៃប្រជាជនក្នុងពេលបន្តិចទៀត ។

រូបពីរ៉ាមីតអាយុប្រជាជនចិនឆ្នាំ 1953 មានរាងរីកបាត នេះបញ្ជាក់ថា អត្រាជាតិប្រមាណខ្ពស់និងអត្រាកំណើនប្រជាជនលឿន ក្រោយពីពេលមានការថយចុះនៃកំណើតពីឆ្នាំ 1937 មក ឆ្នាំ 1949 ដែលទាក់ទងទៅនឹងចម្បាំង ចិន-ជប៉ុន និងចម្បាំងក្នុងស្រុក ។

ជំរឿនឆ្នាំ 1953 និង 1982 ទម្រង់ពីរ៉ាមីតមានការប្រែប្រួល ដែលបង្ហាញពីភាពចំណាស់នៃប្រជាជនចិនក្រោមទំនោរទៅរកការកាត់បន្ថយអត្រាជាតិប្រមាណ និងអត្រាមរណៈប្រមាណ ។ ពីរ៉ាមីតឆ្នាំ 1982 ក៏បានបង្ហាញផងដែរ នូវការថយចុះនៃកំណើតពីឆ្នាំ 1958-1961 ដែលទាក់ទងទៅនឹងនយោបាយមហាលោតផ្លោះរបស់លោកប្រធាន ម៉ៅសេទុង និងគ្រោះទុរ្ភិក្សដែលកើតមានជាបន្តមកទៀត ។ រូបពីរ៉ាមីតនេះក៏បានបញ្ជាក់ផងដែរ ពីការបាត់បង់ជីវិតដែលបណ្តាលមកពីបដិវត្តន៍វប្បធម៌នៅប្រទេសចិន ការថយចុះនៃលទ្ធភាពបង្កកំណើតដែលបង្កឡើងដោយការត្រួតពិនិត្យកំណើតដែលកាន់តែតឹងរឹងខ្លាំងឡើងៗ និងដោយការអនុវត្តនយោបាយកូនទោលរបស់រដ្ឋាភិបាលចិនពីឆ្នាំ 1979 មក ។ ក្រុមអាយុ 15-64 ឆ្នាំតាង 2/3 នៃប្រជាជនឆ្នាំ 1995 នៅឡើយ ប៉ុន្តែ 6.4% នៃប្រជាជនចិនចូលដល់វ័យចំណាស់ជាស្រេច( 65 ឆ្នាំឡើង)ទល់នឹង 4.9% នៅឆ្នាំ 1982 ។

ទម្រង់ប្រជាជនចិនតាមអាយុ(ឆ្នាំ 2009 )មានការប្រែប្រួលច្រើន

- ក្រុមកុមារ (0-14 ឆ្នាំ) មាន 19.8% បុរសមាន 140 877 745 នាក់ ស្ត្រីមាន 124 290 090 នាក់ ។
- ក្រុមសកម្ម (15-64 ឆ្នាំ) មាន 72.1% បុរសមាន 495 724 889 នាក់ ស្ត្រីមាន 469 182 087 នាក់ ។
- ក្រុមមនុស្សចាស់ (65 ឆ្នាំឡើង) មាន 8.1% បុរសមាន 51 774 115 នាក់ ស្ត្រីមាន 56 764 042 នាក់ ។



ពីរ៉ាមីតអាយុប្រជាជនចិន



ការផ្សព្វផ្សាយស្តីពីប្រជាសាស្ត្រនៅកង់តុង(Canton)

## 2. ប្រព័ន្ធនយោបាយចិន

ក្រោយជ័យជំនះលើកងទ័ពចិនជាតិនិយមរបស់លោក ចាងខាយចៀក កងទ័ពក្រហមចិនដឹកនាំដោយម៉ៅ សេទុង បានប្រកាសឈ្មោះប្រទេសថា "សាធារណរដ្ឋប្រជាមានិតចិន" កាលពីថ្ងៃទី 1 ខែតុលា ឆ្នាំ 1949 ។ ពីឆ្នាំ 1949 មកដល់ដំណាច់ទសវត្សរ៍ឆ្នាំ 1970 ប្រទេសចិនបានអនុវត្តលទ្ធិកុម្មុយនីស្តបែបម៉ៅនិយមតឹងរ៉ឹង ។ ចាប់ពីក្រោយឆ្នាំ 1978 មក តេងសៀវពីង និងមេដឹកនាំដទៃទៀតបានចាប់អារម្មណ៍មកលើការអភិវឌ្ឍ "សេដ្ឋកិច្ចបែបទីផ្សារតម្រង់ទិស" អាចហៅម្យ៉ាងទៀតថា "សេដ្ឋកិច្ចសង្គមនិយមទីផ្សារ" ដោយធ្វើការកែច្នៃយ៉ាងស៊ីជម្រៅនៃរបបសេដ្ឋកិច្ចផែនការ តែនៅប្រកាន់យករបបគ្រប់គ្រងនយោបាយតាមបែបសង្គមនិយមដដែល ។

### 2.1. របៀបរៀបចំផ្នែករដ្ឋបាល

ប្រទេសចិនជារដ្ឋកុម្មុយនីស្ត មានទីក្រុងប៉េកាំងជារដ្ឋធានី ចែកចេញជា 23 ខេត្ត 5 តំបន់ស្វយ័ត និងក្រុងស្វយ័ត 4 ។ ចិនបានចាត់ទុកកោះតៃវ៉ាន់ជាខេត្តទី 23 ចំណែកក្រុងហុងកុង និងម៉ាកាវជាតំបន់រដ្ឋបាលពិសេស ។

### 2.2. របៀបរៀបចំផ្នែកនយោបាយ

រដ្ឋធម្មនុញ្ញចិនដែលប្រកាសឱ្យប្រើថ្មីបំផុត គឺរដ្ឋធម្មនុញ្ញថ្ងៃ 4 កញ្ញា 1982 ជាមួយនឹងវិសោធនកម្មឆ្នាំ1988 1993 និង 2004 ។ ការបោះឆ្នោតប្រព្រឹត្តទៅជាសកល ដោយប្រជាជនដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ ។ ចំណែកស្ថាប័នរដ្ឋមានបីគឺ ៖

- អំណាចនីតិប្រតិបត្តិជារបស់គណៈប្រធានរដ្ឋ និងគណៈប្រធានរដ្ឋាភិបាល ។
  - គណៈប្រធានរដ្ឋ មានប្រធានាធិបតីមួយរូប និងអនុប្រធានាធិបតីមួយរូប ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយសមាជប្រជាជនចិនសម្រាប់អាណត្តិ 5 ឆ្នាំ ។
  - គណៈប្រធានរដ្ឋាភិបាល មាននាយករដ្ឋមន្ត្រីមួយរូប និងឧបនាយករដ្ឋមន្ត្រី 4 រូប ។ នាយករដ្ឋមន្ត្រីតែងតាំងដោយប្រធានាធិបតីដោយមានការយល់ព្រមពីសមាជប្រជាជនចិនផងដែរ ។
- អំណាចនីតិប្បញ្ញត្តិ ជារបស់សមាជប្រជាជនចិនតែមួយគត់ មានចំនួន 2987 អាសនៈដែលត្រូវបោះឆ្នោតជ្រើសតាំងដោយសមាជប្រជាជន ក្រុង តំបន់ ខេត្ត និងដោយកងទ័ពរំដោះប្រជាជនសម្រាប់អាណត្តិ 5 ឆ្នាំ ។
- អំណាចតុលាការ ជារបស់តុលាការជាន់ខ្ពស់នៃប្រជាជនចិន(ចៅក្រមកាត់ក្តីតែងតាំងដោយសមាជប្រជាជនចិន) តុលាការតំបន់(តុលាការមូលដ្ឋាន កណ្តាល និងជាន់ខ្ពស់) និងតុលាការពិសេសនៃប្រជាជន(តុលាការយោធា នាវាចរណ៍សមុទ្រ ការដឹកជញ្ជូនផ្លូវដែក និងរុក្ខកម្ម) ។

ចំណែកគណបក្សនយោបាយវិញ គេឃើញមានបក្សកុម្មុយនីស្ត ដែលមានលោក ហ៊ូជិនតាវជាប្រធាន និងគណបក្សតូចៗចំនួន 8 ទៀតដែលស្ថិតក្រោមការត្រួតពិនិត្យរបស់កុម្មុយនីស្តចិន ។ ប្រទេសនេះគ្មានគណបក្សប្រឆាំងទេ ។

# ៣. សេដ្ឋកិច្ចចិន

## ៣.១. ការជំរុញសេដ្ឋកិច្ច

### ក. ពីភាពសម្បូរធនធាន ទៅកាន់ការបើកចំហទៅរកពិភពលោក

ពីឆ្នាំ 1949 ដល់ដំណាច់ទសវត្សរ៍ឆ្នាំ 1970ប្រទេសចិនបានស្គាល់នូវរបបកុម្មុយនីស្តដ៏តឹងរ៉ឹងមួយ ដោយឈរលើទស្សនៈម៉ៅនិយម ដែលរុញច្រានប្រទេសឱ្យធ្លាក់ក្នុងស្ថានភាពសេដ្ឋកិច្ច និងសង្គមមួយប្រកបដោយគ្រោះថ្នាក់ ។ សម័យមហាលោតផ្លោះ ពីឆ្នាំ 1958ដល់ 1961 គ្រោះទុរ្ភិក្សដែលលាក់កំបាំងមួយបានកើតមានឡើងយ៉ាងប្រាកដ ។ ម្យ៉ាងទៀត ការផ្តាច់ទំនាក់ទំនងជាមួយសហភាពសូវៀតនៅឆ្នាំ1960 គ្រាន់តែជាការដាក់ឱ្យប្រទេសចិនឱ្យស្ថិតក្នុងភាពឯកោកាន់តែខ្លាំងឡើង ក្នុងការជំនួសបំណងប្រាថ្នា បង្ហាញដល់ពិភពលោកនូវគំរូសង្គមថ្មីមួយ ។

មរតកដ៏ធ្ងន់ធ្ងរនៃសម័យកាលម៉ៅនិយម ជំរុញឱ្យលោកតេងសៀវពីង លើកឡើងនូវនយោបាយ "ទំនើបកម្មបួនបែប" ឧស្សាហកម្ម កសិកម្ម វិទ្យាសាស្ត្រ និងការពារជាតិ ។ ការបើកចំហទៅរកពិភពលោក និងគំនិតផ្តួចផ្តើមជាបុគ្គលត្រូវពន្យល់បានលើកទឹកចិត្ត តែទន្ទឹមនឹងនេះក៏នៅមានការជ្រុលជ្រួសផ្នែកនយោបាយខ្លះៗដែរ ដោយសារកង្វះខាតផ្នែកប្រជាធិបតេយ្យនៃរបបមួយ ដែលគ្រប់គ្រងបែបកុម្មុយនីស្ត ។

ការរៀបចំសេដ្ឋកិច្ចចុងក្រោយ គឺការផ្តល់សិទ្ធិឱ្យដល់សហគ្រាសឯកជនចិន និងបរទេស និងសេចក្តីទុកចិត្តទៅលើគំនិតផ្តួចបផ្តើមរបស់វណ្ណៈកណ្តាលដែលជឿនលឿនបំផុត ដោយបោះបង់ចោលមនោគមន៍វិជ្ជាម៉ាក់និយម ក៏ដូចជាសិទ្ធិផ្តាច់មុខនៃវណ្ណៈអធន ។ ការតម្រង់ទិសថ្មីនេះមានឈ្មោះថា "ភាពជាតំណាងទាំងបី" បង្ហាញពីគំនិតរបស់លោក ជាំងចឺមិន(Jiang Zemin)ដែលត្រូវដោយលោក ហ៊ូជិនតាវ(Hu Jintao)មេដឹកនាំថ្មីចូលមកបំពេញការងារនាចុងឆ្នាំ 2002 យកទៅអនុវត្តបន្ត ។ ម្យ៉ាងទៀតប្រទេសចិនទើបតែបានចូលជាសមាជិកនៃអង្គការសេដ្ឋកិច្ចពិភពលោក(WTO)ក្នុងពេលថ្មីៗនេះ ។

### ខ. ភាពចាំបាច់ថ្មីៗក្នុងវិស័យសេដ្ឋកិច្ច

មេដឹកនាំចិនបានមើលឃើញច្បាស់ណាស់ពីភាពយឺតយ៉ាវនៃសេដ្ឋកិច្ចជាតិ ។ ជោគជ័យនៃសេដ្ឋកិច្ចរបស់កោះតៃវ៉ាន់ និងកូរ៉េខាងត្បូងនាំឱ្យចិនមានបំណងយ៉ាងមុតមាំក្នុងការធ្វើទំនើបកម្មសេដ្ឋកិច្ចដោយផ្តល់អាទិភាពទៅលើ :

- ការអភិវឌ្ឍបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ ។
- ហេដ្ឋារចនាសម្ព័ន្ធផ្នែកទូរគមនាគមន៍(បណ្តាញព័ត៌មាន ទូរស័ព្ទចល័ត) ចាំបាច់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចទំនើប ។
- គ្រឿងបរិក្ខារសម្រាប់បម្រើការដឹកជញ្ជូនដូចជាផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ និងអាកាសយានដ្ឋាន ។
- ការផ្តល់ឥណទានសម្រាប់ទ្រទ្រង់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ដែលបានកើតឡើងទ្វេដងក្នុងរយៈពេល 5ឆ្នាំ តែក្នុងអត្រា 1% នៃ GDP ប៉ុណ្ណោះ ។
- ការខិតខំប្រឹងប្រែងមួយទៀត គឺការបណ្តុះបណ្តាលធនធានមនុស្ស ។ ប្រទេសចិនមានសកលវិទ្យាល័យចំនួន 1 225 ហើយវិស្វករចំនួន 450 000 នាក់បានបញ្ចប់ការសិក្សាកាលពីឆ្នាំ 2000 ។

ប្រទេសចិនមានការកែប្រែមួយយ៉ាងស៊ីជម្រៅ គឺការផ្ទេរសហគ្រាសរដ្ឋ ឬការជំនួសដោយសហគ្រាសឯកជនដែលទទួលបានផលចំណេញច្រើនពីមូលធនបរទេស ឬការធ្វើកិច្ចសហការជាមួយសហគ្រាសអន្តរជាតិ ។

## 3.2. ចិនជាមហាអំណាចសេដ្ឋកិច្ចថ្មីមួយ

### ក. អានុភាពសេដ្ឋកិច្ចចិន




*ការដឹកជញ្ជូនរបស់ប្រទេសចិន*

ផលិតផលក្នុងស្រុកសរុប (GDP)មានជាង 1 200 ពាន់លានដុល្លារបានលើកតម្កើងប្រទេសចិនឱ្យទៅស្ថិតនៅជួរទី 6 នៃពិភពលោក ។ បច្ចុប្បន្ននេះ ប្រទេសចិនបានជាប់ចំណាត់ថ្នាក់លេខ 3 (ឆ្នាំ 2009) GDP តាមផ្នែកនីមួយៗមាន កសិកម្ម 10.9% ឧស្សាហកម្ម 48.6% និងសេវាកម្ម 40.5% ។ ប៉ុន្តែ

ចង្វាក់នៃកំណើនប្រចាំឆ្នាំ 7% ឬ 8% ជួនកាល 9% ឯណោះទេ ដែលបង្ហាញស្ថានភាពសេដ្ឋកិច្ចដ៏ចម្លែករបស់ចិន ។ ពាណិជ្ជកម្មក្រៅប្រទេសក៏មានការលូតលាស់ខ្លាំងក្លាណាស់ដែរ ។ ក្នុងរយៈពេលមិនដល់ 20 ឆ្នាំផង ប្រទេសចិនបានឡើងពីជួរទី 32 មកជួរទី 9 លើពិភពលោក ។ ដក្បឹងពាណិជ្ជកម្មចិនទទួលបានចំណេញច្រើន (ជាង 100 ពាន់លានដុល្លារក្នុងការធ្វើពាណិជ្ជកម្ម ជាមួយសហរដ្ឋអាមេរិកកាលពីឆ្នាំ 2002) ហើយអាចឱ្យចិនប្រមូលប្រាក់កម្រៃពីការលក់ដូរបានយ៉ាងច្រើនសម្បើម និងមានសមត្ថភាពវិនិយោគខ្លាំងក្លាទៀតផង ។ នៅឆ្នាំ 2009 នេះ ចិនបានលេខ 2 ខាងការនាំចេញ និងលេខ 4 ខាងនាំចូល ។

ការលូតលាស់ដ៏សំខាន់របស់ប្រទេសចិនស្តែងចេញពីផ្នែកឧស្សាហកម្ម(54 % នៃ GDP) ។ សព្វថ្ងៃប្រទេសចិនដែលស្ថិតនៅជួរទី 4 ក្នុងពិភពលោក ផលិតម៉ាស៊ីនថត (ពាក់កណ្តាលនៃផលិតផលពិភពលោក) ទូរទស្សន៍ 30% នៃការផលិតផលពិភពលោក គ្រឿងអេឡិចត្រូនិកប្រើប្រាស់ប្រចាំគ្រួសារ 25% នៃផលិតផលពិភពលោក ។ ផលិតផលទាំងនេះ មួយភាគធំបានមកពីឧស្សាហកម្មដែលបំបែកទីតាំងរបស់បរទេស ហើយដែលនៅតែបន្តធ្វើវិនិយោគយ៉ាងច្រើនសម្បើម ។ ការដ្ឋានធំៗ(សង្កាត់ពួជុងនៅស៊ាំងហៃ ទំនប់ទឹកបីច្រក អាកាសយានដ្ឋាន យន្តបថ ... ) អាចជួយផ្គត់ផ្គង់គ្រឿងបរិក្ខារដល់ប្រទេសចិនបាន ។

## ខ. មហិច្ឆតាដ៏ធំមួយ

វឌ្ឍនភាពសេដ្ឋកិច្ចនឹងនាំឆ្ពោះទៅរកការបង្កើនប្រាក់បៀវត្សកម្រិតមធ្យមមួយ ។ ចំណែកសហគ្រាសបរទេសដែលស្ម័គ្រចិត្តចូលទៅធ្វើវិនិយោគនៅប្រទេសចិន ក៏ដោយសារតែនៅទីនោះប្រាក់ឈ្នួលរបស់កម្មករថោក ។ ចំពោះមុខបញ្ហាទាំងនេះ រដ្ឋាភិបាលចិនអាចរក្សាតម្លៃផលិតកម្មឱ្យនៅទាបបាន លុះត្រាតែក្រុមកម្មករបម្រុងដែលស៊ីថ្លៃថោកនៅមានសល់ចំនួនច្រើន ។ ភាពឥតការងារធ្វើបានទប់ប្រាក់បៀវត្សមិនឱ្យកើនបាន ហើយប្រជាជនជនបទរត់ចូលមករស់នៅទីក្រុងកាន់តែច្រើនឡើងៗទៀតផង ។

អានុភាពវិស័យអវកាសរបស់ចិនមិនអាចឱ្យគេបំភ្លេចនូវការពង្រឹងអានុភាពយោធាចិនក្នុងពេលជំណាលគ្នានេះបានទេ ។ ប្រការនេះបានធ្វើឱ្យប្រទេសជិតខាងដែលជាដៃគូសេដ្ឋកិច្ចនៅក្នុងសមុទ្រចិនមានក្តីបារម្ភ ។

### គ. តំបន់ជំរុញសេដ្ឋកិច្ចចិន

តំបន់ប៉េកាំង ធានជីន បានទទួលដោយក្តីសោមនស្សនូវសហគ្រាស កូរ៉េ ឬជប៉ុន ដែលមានឯកទេសខាងគ្រឿងបរិក្ខារ ។ ការប្រកាសពីតួនាទីជាអន្តរជាតិរបស់ចិន កើតឡើងស្របគ្នានឹងល្បែងអូឡាំពិកឆ្នាំ 2008 នៅប៉េកាំង ។




*តំបន់សេដ្ឋកិច្ចទីក្រុងហុងកុង*

ទីក្រុងស៊ាងហៃ ដោយសារតែមានទំនាក់ទំនងសេដ្ឋកិច្ចជាមួយតៃវ៉ាន់និងលោកខាងលិច បានទទួលការរីកចម្រើនមួយយ៉ាងខ្លាំង និងសង្ឃឹមថាអាចក្លាយជាទីក្រុងថ្នាក់ពិភពលោកមួយនៅក្នុងសតវត្សយើងនេះ ។

តំបន់ត្រីកោណចិនភាគខាងត្បូង តំបន់ជុំវិញក្រុងហុងកុង ដោយសារតែឯកទេសខាងហិរញ្ញវត្ថុ និងកំណើនសហគ្រាសឯកជននៅតំបន់នេះបង្កើតបានជាប៉ូលកំណើនមួយដែលមានឥទ្ធិពលទៅលើផ្នែកមួយនៃអាស៊ីអាគ្នេយ៍ ។

## ✍ ពាក្យគន្លឹះ

- **អន្តរភាពប្រជាសាស្ត្រ** : ដំណើរប្រែប្រួលកំណើនធម្មជាតិនៃប្រជាជន មានពីរវគ្គ វគ្គទីមួយកត់សម្គាល់ដោយការថយចុះនៃអត្រាមរណប្រមាណ និងការរក្សាទុកនូវអត្រាជាតិប្រមាណ ។ វគ្គទីពីរ ការថយចុះនៃកំណើនធម្មជាតិដោយសារការថយចុះនៃលទ្ធភាពបង្កកំណើតរបស់ស្ត្រី គឺអត្រាជាតិប្រមាណ ។

- **មហាលោតផ្លោះ** : នយោបាយអភិវឌ្ឍសង្គម សេដ្ឋកិច្ចតាមបែបម៉ៅនិយម (ទ្រឹស្តីសង្គមនិយមរបស់លោកម៉ៅសេទុង មេដឹកនាំបដិវត្តន៍នៅប្រទេសចិន) ។
- **បដិវត្តន៍វប្បធម៌** : ដំណើរផ្លាស់ប្តូរយ៉ាងគំហុកផ្នែកវប្បធម៌នៅប្រទេសចិន តាមបែបម៉ៅនិយម ។
- **ភាពជាតំណាងទាំងបី** : ទ្រឹស្តីនយោបាយថ្មីរបស់ចិនដែលបក្សកុម្មុយនីស្តចិនបានលើកឡើង មានកម្លាំងផលិតកម្មជឿនលឿនបំផុត វប្បធម៌មួយជឿនលឿនបំផុត និងផលប្រយោជន៍ធំធេងបំផុតរបស់ប្រជាជនចិន ។

## ? សំណួរ

1. តើការអនុវត្តនយោបាយប្រឆាំងកំណើតនៅប្រទេសចិនពីឆ្នាំ 1953 មកដល់សព្វថ្ងៃទទួលបានលទ្ធផលដូចម្តេចខ្លះ ?
2. តើរបៀបរៀបចំផ្នែករដ្ឋបាល នៅប្រទេសចិនមានយ៉ាងដូចម្តេចខ្លះ ?
3. ចូរនិយាយពីស្ថាប័ននយោបាយសំខាន់ៗទាំងបីនៅប្រទេសចិន ?
4. តើនយោបាយ "ទំនើបកម្មបួនបែប" លើកឡើងដោយមេដឹកនាំចិនរូបណា ? មានអ្វីខ្លះ ?
5. តើអ្វីទៅហៅថា "ភាពជាតំណាងទាំងបី" ?
6. តើអានុភាពសេដ្ឋកិច្ចចិនមានដូចម្តេចខ្លះ ?
7. ហេតុអ្វីបានជារដ្ឋាភិបាលចិន អាចរក្សាតម្លៃផលិតកម្មរបស់ខ្លួនឱ្យនៅទាបបាន ?
8. ចូរនិយាយអំពីប៉ូលជំរុញសេដ្ឋកិច្ចទាំងបីរបស់ចិន ។

មេរៀនទី

# 2 ប្រទេសឥណ្ឌា

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីប្រជាជន ប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចប្រទេសឥណ្ឌា ។




*ផែនទីសណ្ឋានដីប្រទេសឥណ្ឌា*

ឥណ្ឌាជាប្រទេសធំមួយទៀតនៃទ្វីបអាស៊ី បានទទួលចំណាត់ថ្នាក់លេខ 7 ខាងផ្ទៃដី (3 287 263km$^2$) និងលេខ 2 ខាងចំនួនប្រជាជន (1 156 897 766 នាក់)នៅឆ្នាំ 2009 ។

ប្រទេសឥណ្ឌាមានទីតាំងស្ថិតនៅភូមិភាគអាស៊ីខាងត្បូងចន្លោះខ្សែស្របទី 8° ដល់ទី 36° នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្ដោយទី 68° ដល់ទី 98° នៃរយៈបណ្ដោយខាងកើត ។ សណ្ឋានដីមានលក្ខណៈជាអនុទ្វីបមួយ ស្រោចស្រពដោយមហាសមុទ្រឥណ្ឌា មានជួរភ្នំពីរសណ្ដូកតាមបណ្ដោយឆ្នេរ គឺជួរភ្នំឃាតខាងលិច និងជួរភ្នំឃាតខាងកើត ។ ទំនាបឆ្នេរទាំងពីរភ្ជាប់ទៅទំនាបទន្លេ ឥណ្ឌុស-គង្គាដ៏ធំដែលស្ថិតនៅចន្លោះខ្ពង់រាបដេកង់ និងជួរភ្នំហិមាល័យ និងវាលលំហនៅប៉ែកពាយ័ព្យប្រទេស ។ អាកាសធាតុមានពីរ គឺអាកាសធាតុត្រូពិចមូសុងនៅភាគខាងត្បូងប្រទេស និងអាកាសធាតុត្រជាក់បង្គួរនៅភាគខាងជើង ។

ទោះបីស្ថិតនៅក្រោមតំនាបសង្កត់នៃបញ្ហាជាច្រើនដូចជា បញ្ហាភាពក្រីក្រ បញ្ហាចិញ្ចឹមប្រជាជនដ៏ច្រើន បញ្ហាជម្លោះដែនដីដែលបន្សល់ទុកដោយពួកអាណានិគមអង់គ្លេស(រដ្ឋកាស្មៀ) បញ្ហាជម្លោះជនជាតិ (ពួកហិណ្ឌូ និងអ៊ីស្លាម)ក៏ដោយ ក៏ប្រទេសឥណ្ឌាខិតខំដោះស្រាយបញ្ហា និងលើកស្ទួយប្រទេសជាតិតាមមាគ៌ាអភិវឌ្ឍន៍បែបឥណ្ឌា ទាំងកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ហើយសម្រេចបានជោគជ័យគួរជាទីមោទនៈ ។

# 1. ប្រជាជនឥណ្ឌា

ឥណ្ឌាជាប្រទេសមួយដែលមានប្រជាជនច្រើនជាងគេក្នុងលោក បន្ទាប់ពីប្រទេសចិន ហើយត្រូវប្រឈមមុខនិងបញ្ហាដ៏ធំមួយគឺចិញ្ចឹមមនុស្សចំនួន 17 លាននាក់បន្ថែមទៀតជារៀងរាល់ឆ្នាំ ។ ដូចនេះ សូចនាករប្រជាសាស្ត្របានបង្ហាញបញ្ហាចោទជាយូរយារមកហើយ តែសញ្ញានៃកំណែលម្អក៏កើតមានដំណាលគ្នានោះដែរ ។ ភាពម្ចាស់ការលើកំណើនប្រជាជន និងអភិវឌ្ឍន៍សេដ្ឋកិច្ចត្រូវដើរទន្ទឹមគ្នាដើម្បីរំដោះប្រជាជនឥណ្ឌារាប់លាននាក់ឱ្យចេញពីទុរគតភាពបាន ។

## 1.1. អន្តរភាពប្រជាសាស្ត្រ

ប្រទេសឥណ្ឌាកំពុងស្ថិតនៅក្នុងអន្តរភាពប្រជាសាស្ត្រនៅឡើយ គឺចាប់ពីបណ្ដាឆ្នាំ 1950 មកអត្រាមរណៈប្រមាណបានធ្លាក់ចុះអស់ពីរភាគបី ដោយសារតែការរីកចម្រើនផ្នែកអនាម័យ និងសុខភាព និងដោយសារតែការកែលម្អផ្នែកផលិតកម្មកសិកម្ម ។ ប៉ុន្តែ អត្រាជាតិប្រមាណមិនទាន់ថយចុះបានសមស្របនៅឡើយទេ ។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំនៅតែ



ប្រជាជនឥណ្ឌា

ស្ថិតក្នុងកម្រិតខ្ពស់នៅឡើយ(1.9%ជាមធ្យមនៅចន្លោះឆ្នាំ 1990-1995 និង 1.4% នៅឆ្នាំ 2009)។ នៅក្នុងប្រទេសមួយដែលឪពុកម្ដាយយល់ថាកូនៗជាកម្លាំងជួយដល់ការងារចិញ្ចឹមជីវិត ជួយពួកគាត់នៅពេលចាស់ជរា នយោបាយកម្រិតកំណើតដែលប្រព្រឹត្តទៅតាមការឃោសនាផ្សព្វផ្សាយព័ត៌មានប្រាកដជាមិនបានទទួលលទ្ធផលល្អដូចសង្ឃឹមទុកឡើយ។ លើសពីនេះទៀត យុទ្ធនាការដែលបង្ខំឱ្យអារនៅចន្លោះឆ្នាំ 1975-1977 បណ្ដាលឱ្យមានការប្រឆាំងពីសំណាក់ប្រជាជនជនបទ។

ប្រទេសឥណ្ឌានៅមានអនក្ខរជនចំនួន 50% នៅឡើយ ហើយមនុស្សជិត 300 លាននាក់រស់នៅក្នុងភាពក្រីក្របំផុត។ ទុគ៌តភាពជនបទបានរុញច្រានកសិករដែលគ្មានដីធ្លី ឬអ្នកជំពាក់បំណុលគេជាច្រើនលាននាក់មកកាន់ទីក្រុងធំៗ។ ពួកគេមករស់នៅពាក់ពពូនក្នុងសំណង់អនាធិបតេយ្យ ឬរស់នៅលើចិញ្ចើមថ្នល់ក៏មាន។ ចំណាកស្រុកស្រែមកកាន់មេត្រូប៉ូលធំៗ(ញូដេលី បុមបៃ កាល់កុត្តា ម៉ាដ្រាស) សព្វថ្ងៃមានចំនួនជិត 40 លាននាក់។ ចំណាកស្រុកស្រែមកកាន់ទីក្រុងកំពុងតែបន្ថយល្បឿនបន្តិចហើយ ព្រោះថាទីក្រុងទាំងនោះមិនអាចផ្ដល់ការងារបានតទៅទៀត។ ផ្ទុយទៅវិញ ទីក្រុងដែលមានមនុស្សពី 100 000 ទៅ 500 000 នាក់ទទួលបានការរីកលូតលាស់យ៉ាងឆាប់រហ័ស ហើយភូមិមួយចំនួនធំបានក្លាយទៅជាទីប្រជុំជនក្រុង។

## 1.2. ការចិញ្ចឹមប្រជាជនជាងមួយពាន់លាននាក់ (បដិវត្តន៍បៃតង)

ទន្ទឹមគ្នានិងការកាត់បន្ថយចំនួនកំណើត រដ្ឋាភិបាលឥណ្ឌាក៏ខិតខំខ្លាំងក្លាណាស់ដែរក្នុងការបង្កបង្កើនផលកសិកម្ម។ ការបញ្ចូលពូជដែលផ្ដល់ទិន្នផលខ្ពស់ គួបផ្សំនិងការប្រើប្រាស់ជីគីមី ថ្នាំសម្លាប់សត្វចង្រៃ ការងារបញ្ចូលទឹក និងការបញ្ចូលគ្រឿងយន្តកសិកម្មបានផ្ដល់លទ្ធផលយ៉ាងចំចែង ពិសេសក្នុងរដ្ឋប៉ិនចាប់(Pendjab) និងកេរ៉ាឡា(Kerala)។ ចាប់តាំងពីពេលនោះមក ប្រទេសឥណ្ឌាទទួលបានភាពស្វ័យគ្រប់គ្រាន់ខាងចំណីអាហារ ដែលអាចឱ្យគេបង្វែរជញ្ជីងចំណាយទៅរកការវិនិយោគលើវិស័យផ្សេងៗវិញ ហើយថែមទាំងអាចសល់ផលសម្រាប់នាំចេញទៀតផង។ ប៉ុន្តែបដិវត្តន៍បៃតងបានបង្កើតវិសមភាពសង្គម និងវិសមភាពតាមតំបន់ដោយមិនបាននាំមកនូវកំណែទម្រង់ក្សេត្រសាស្ត្រមួយប្រកបដោយប្រសិទ្ធភាពទេ។ ការអភិវឌ្ឍសហករណ៍ឥណទានកសិកម្មមិនទាន់បានបំបាត់ចោលទាំងស្រុងនូវការចងការប្រាក់ថ្លៃលើសលប់ ហើយកសិករមួយចំនួនធំនៅតែក្រីក្រខ្លាំង និងជំពាក់បំណុលគេយ៉ាងធ្ងន់ធ្ងរ ដែលជាហេតុធ្វើឱ្យប្រទេសនេះគ្មានលទ្ធភាពក្នុងការធ្វើទំនើបកម្មអាជីវកម្ម ឬក្នុងការបង្កើតទីផ្សារប្រើប្រាស់មួយពេញលេញសម្រាប់លំហូរទំនិញឧស្សាហកម្មជាតិឡើយ។

### 1.3. ការរីកលូតលាស់មានលក្ខណៈខ្វះខាតនៅឡើយ

បដិវត្តន៍បៃតងហាក់ដូចជាទទួលបានជោគជ័យខ្លាំងជាងយុទ្ធនាការប្រឆាំងកំណើត ទោះបីវិស័យនេះមានការរីកលូតលាស់ជាក់លាក់ក៏ដោយ ។ នៅចន្លោះឆ្នាំ 1951 និង 1995 អត្រាលទ្ធភាពបង្កកំណើតរបស់ស្ត្រីឥណ្ឌាមានពី 5.9 ទៅ 3.8 នាក់ (បច្ចុប្បន្នមាន 2.68 នាក់ ឆ្នាំ 2009) អត្រាមរណភាពកុមារ ពី 15% មក 9.6% (5.78% នាក់ ឆ្នាំ 2009) និងសង្ឃឹមរស់ពីកំណើតពី 32 មក 60 ឆ្នាំ (2009 មាន 66 ឆ្នាំ) ។ រដ្ឋទាំងឡាយដែលបានទទួលផលចំណេញច្រើនពីបដិវត្តន៍បៃតង មានអត្រាកំណើនប្រជាជនទាបជាងមធ្យមភាគជាតិ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏គេត្រូវតែរិះរកគ្រប់មធ្យោបាយចិញ្ចឹម ផ្តល់ជម្រក ព្យាបាល អប់រំប្រជាជនដែលមានទាំងអស់ជាងមួយពាន់លាននាក់(2009)ដោយមិនទាន់ទាំងគិតដល់ការបង្កើតការងារថ្មីៗផ្តល់ជូនប្រជាជនទាំងនោះផង ។

## 2. ប្រព័ន្ធនយោបាយឥណ្ឌា

អរិយធម៌នៃជ្រលងទន្លេឥណ្ឌុស ជាអរិយធម៌ដ៏ចំណាស់បំផុតមួយក្នុងលោក ហើយរីកចម្រើនយ៉ាងត្រចះត្រចង់នៅសហស្សវត្សរ៍ទី 3 និងទី 2 មុនគ្រិស្តសករាជ ។ ពួកអ្នករុករកជាតិអឺរ៉ុបបានមកឈរជើងនៅលើឧបទ្វីបឥណ្ឌានៅសតវត្សទី 16 ។ ចក្រភពអង់គ្លេសបានដាក់និមត្តត្រួតត្រាលើអនុទ្វីបនេះនៅសតវត្សទី 19 ។ ចលនាតស៊ូដោយអហិង្សាប្រឆាំងការគ្រប់គ្រងរបស់អង់គ្លេសដឹកនាំដោយលោក មហាត្មៈគន្ធី និងលោក នេរុ បាននាំមកនូវឯករាជ្យជូនប្រទេសឥណ្ឌាកាលពីថ្ងៃទី 15 ខែសីហា ឆ្នាំ 1947 ។ អំពើហិង្សាដែលកើតមាននៅលើឧបទ្វីប នាំឆ្ពោះទៅរកការបង្កើតរដ្ឋពីរដាច់ចេញពីគ្នា គឺឥណ្ឌា(ពួកហិណ្ឌូ) និងប៉ាគីស្ថាន(ពួកមូស្លីម) ។ ក្រោយមក ប្រទេសទាំងពីរបានច្បាំងគ្នាចំនួនបីលើកដែលលើកចុងក្រោយនៅឆ្នាំ 1971 ។ ជាលទ្ធផល ប្រទេសប៉ាគីស្ថានខាងកើតបានក្លាយទៅជាប្រទេសមួយដាច់ដោយឡែក មានឈ្មោះថាប្រទេសបង់ក្លាដែស ។

### 2.1. របៀបរៀបចំផ្នែករដ្ឋបាល

សាធារណរដ្ឋឥណ្ឌាជារដ្ឋសហព័ន្ធ មានរដ្ឋទាំងអស់ចំនួន 28 ជាសមាជិក និងតំបន់ត្រួតត្រាចំនួន 7 ទៀត ។ ញូដេលីជារដ្ឋធានីនៃសាធារណរដ្ឋឥណ្ឌា ។ ថ្ងៃទី 26 មករា 1950 ជាថ្ងៃប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ និងក៏ជាថ្ងៃបុណ្យជាតិឥណ្ឌាផងដែរ ។ បញ្ហាដែលបន្សល់ទុកដោយពួកអាណានិគមអង់គ្លេស គឺបញ្ហារដ្ឋកាស្មៀ ដែលបណ្តាលឱ្យមានសង្គ្រាមរវាងឥណ្ឌា និងប៉ាគីស្ថានដែលធ្វើឱ្យមនុស្សស្លាប់អស់យ៉ាងច្រើន ។

## 2.2. របៀបរៀបចំផ្នែកនយោបាយ

រដ្ឋធម្មនុញ្ញឆ្នាំ 1950 បានប្រកាសប្រទេសឥណ្ឌាជាសាធារណរដ្ឋឥណ្ឌា ។ រដ្ឋធម្មនុញ្ញនេះបានទទួលវិសោធនកម្មជាច្រើនលើកមកហើយ និងបានបែងចែកអំណាចជាស្ថាប័នឯករាជ្យបី ៖

- **អំណាចនីតិប្រតិបត្តិ** : កាន់កាប់ដោយប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល ។
  - ប្រមុខរដ្ឋ : មានប្រធានាធិបតី និងអនុប្រធានាធិបតី ។ ប្រធានាធិបតីជ្រើសតាំងដោយការបោះឆ្នោតពីសមាជិកសភាទាំងពីរ និងសភានៃរដ្ឋសម្រាប់អាណត្តិ 5 ឆ្នាំ (មិនកំណត់អាណត្តិទេ) ។ អនុប្រធានាធិបតី ក៏ត្រូវបោះឆ្នោតជ្រើសតាំងដោយសភាទាំងពីរដែរ សម្រាប់អាណត្តិ 5 ឆ្នាំដូចគ្នា ។
  - ប្រមុខរដ្ឋាភិបាល : មាននាយករដ្ឋមន្ត្រីដែលជាអ្នករៀបចំគណៈរដ្ឋមន្ត្រី ។ នាយករដ្ឋមន្ត្រីត្រូវបានជ្រើសរើសក្នុងចំណោមសមាជិកសភារបស់គណបក្សឈ្នះឆ្នោត សម្រាប់អាណត្តិ 5 ឆ្នាំដែរ ។
- **អំណាចនីតិបញ្ញត្តិ** : មានសភាដែលអមដោយសភាពីរ គឺក្រុមប្រឹក្សារដ្ឋ និងរដ្ឋសភា ។
  - ក្រុមប្រឹក្សារដ្ឋ : មានសមាជិកមិនលើសពី 250 នាក់ឡើយ ដែលក្នុងនោះចំនួន 12 នាក់ត្រូវតែងតាំងដោយប្រធានាធិបតី ហើយក្រៅពីនេះត្រូវជ្រើសរើសពីសមាជិកជាប់ឆ្នោតនៅតាមរដ្ឋ និងតាមដែនដីត្រួតត្រា សម្រាប់អាណត្តិ 6 ឆ្នាំ ។
  - រដ្ឋសភា : មានសមាជិកទាំងអស់ 545 នាក់ ។ ចំនួន 543 នាក់ជ្រើសតាំងដោយការបោះឆ្នោតពីប្រជាជន 2 រូបទៀតចាត់តាំងដោយប្រធានាធិបតីសម្រាប់អាណត្តិ 5 ឆ្នាំ ។
- **អំណាចតុលាការ** : តុលាការជាន់ខ្ពស់ ដែលមានប្រធានតុលាការម្នាក់ និងសហការី 25 រូបទៀត តែងតាំងដោយប្រធានាធិបតី និងស្ថិតនៅក្នុងការងាររហូតដល់ពួកគេមានអាយុ 65 ឆ្នាំ ឬក៏ត្រូវផ្លាស់ប្តូរនៅពេលដែលគេរកឃើញថាមានកំហុសធ្ងន់ ។

ឥណ្ឌាជាសាធារណរដ្ឋសេរីបែបសហព័ន្ធនិយម ប្រទេសនេះមានគណបក្សនយោបាយច្រើនណាស់ដូចជាគណបក្ស **AIADMA AITC BSP BJP BJD CPI CPI-M DMK INC** ជាដើម ។ ក្នុងពេលបោះឆ្នោតឆ្នាំ 2009 កន្លងមក មានគណបក្សនយោបាយសំខាន់ពីរដែលបានទទួលសំឡេងច្រើនជាងគេ គឺគណបក្សសមាជជាតិឥណ្ឌា INC (Indian National Congres ) បាន 206 កៅអី និងគណបក្សបារ៉ាទីយ៉ាជនតា BJP( Bharatiya Janata Party ) បាន 116 កៅអី ។

# 3. សេដ្ឋកិច្ចឥណ្ឌា

សាធារណរដ្ឋឥណ្ឌាបានដើរតាមមាគ៌ាអភិវឌ្ឍន៍ផ្ទាល់របស់ខ្លួនមួយយ៉ាងជាប់លាប់ ។ មាគ៌ាអភិវឌ្ឍន៍នេះមានការប្រែប្រួលទៅតាមពេលដោយចេញដំណើរតាមមាគ៌ាសង្គមនិយមឆ្ពោះទៅគំរូអភិវឌ្ឍន៍បច្ចុប្បន្ន ដែលមានលក្ខណៈសេរី និងបើកទូលាយដល់វិនិយោគទុនបរទេសបានខ្លាំងជាង ។ ផលិតកម្មកសិកម្ម និងឧស្សាហកម្មឥណ្ឌាបានកើនឡើងយ៉ាងច្បាស់ ។ តាំងពីពេលនោះមក ប្រទេសនេះក៏មានមុខមាត់ជាប្រទេសឧស្សាហកម្មថ្មី ។

## 3.1. មាគ៌ាអភិវឌ្ឍន៍មួយដែលមានការប្រែប្រួល

ក្រោយពេលឯករាជ្យ សហភាពឥណ្ឌាបានជ្រើសរើសយកមាគ៌ាអភិវឌ្ឍន៍មួយតាមបែបសង្គមនិយម ។ ក្រោមការគាំទ្ររបស់លោក នេរូ (1889-1964) និងគណបក្សសមាជដែលដឹកនាំប្រទេសដល់ឆ្នាំ (1977) សេដ្ឋកិច្ចចម្រុះមួយត្រូវបានគេដាក់ឱ្យអនុវត្ត ។ រដ្ឋអំណាចមជ្ឈិមដើរតួនាទីជាចលករ និងដឹកមុខដោយពង្រីកឧស្សាហកម្មធុនធ្ងន់ ធ្វើផែនការកម្មសេដ្ឋកិច្ចដោយដឹកនាំគំនិតផ្តួចផ្តើមរបស់សហគ្រិនឯកជន ។

កិច្ចអភិវឌ្ឍតាមបែបសង្គមនិយមបែបនេះ បានចោទជាបញ្ហានៅបណ្តាឆ្នាំ 1980 ។ ទម្ងន់ការងារបែបការិយាធិបតេយ្យ កង្វះសមត្ថភាពប្រកួតប្រជែងនៃផលិតផលឥណ្ឌាដោយសារនយោបាយការពារនិយម និងជម្រើសសេដ្ឋកិច្ចដែលផ្តល់អាទិភាពដល់ហេដ្ឋារចនាសម្ព័ន្ធ និងឧស្សាហកម្មធុនធ្ងន់ច្រើនជាងកសិកម្ម ជាឧបសគ្គដល់ការកែលម្អលក្ខខណ្ឌជីវភាពរបស់ប្រជាជនដែលមាន 73% ជាកសិករ ។ ចាប់ពីពេលនោះមក ឥណ្ឌាក៏បានឈានចូលទៅក្នុងសេរីភាវូបនីយកម្មសេដ្ឋកិច្ចមួយ ។ នៅខែឧសភា 1991 លោក ណារ៉ាស៊ីមហារ៉ាវ នាយករដ្ឋមន្ត្រីឥណ្ឌាបានបើកទូលាយដល់វិនិយោគទុនបរទេសដោយបញ្ចុះតម្លៃពន្ធគយចំនួនពាក់កណ្តាលចំពោះផលិតផលខ្លះ លុបបំបាត់ចោលអាជ្ញាប័ណ្ណផលិត និងនាំចូល ប្តូរតម្លៃខ្លះនៃប្រាក់រូពី ។ តាំងពីពេលនោះមក សហគ្រាសឥណ្ឌា និងទីផ្សារហ៊ុនឆេងក៏ទាក់ទាញវិនិយោគទុនបរទេសបានយ៉ាងច្រើន ។

## 3.2. កសិកម្មទទួលបានជោគជ័យមិនស្មើភាព

ឥណ្ឌាជាមហាអំណាចកសិកម្មមួយដ៏ធំ ។ ទោះបីទុរ្ភិក្សនៅតែជាបញ្ហាមួយតាមដោយកន្លែងក៏ដោយ ក៏ទុរ្ភិក្សកម្រិតថ្នាក់ជាតិចុងក្រោយបានកើនឡើងនៅឆ្នាំ 1943 ។ ផលិតកម្មអាហារកើនឡើងជាងពីរដងតាំងពីបណ្តាឆ្នាំ 1950 ហើយជញ្ជីងពាណិជ្ជកម្មក៏ទទួលបានចំណេញច្រើនលើវិស័យនេះ ។

ដំណាំសំខាន់ៗមានធញ្ញជាតិ(ស្រូវ ស្រូវសាលី ស្រូវមីយេ) លេគុយមីណឺ(អំបូរបន្លែមានក្តួរដូចជា សណ្តែកបារាំង សណ្តែកបាយ ...) និងដំណាំជំនួញ(កប្បាស សណ្តែកដី តែ) ។

ការរីកចម្រើនផ្នែកកសិកម្មទាំងនេះជាលទ្ធផលនៃបដិវត្តន៍បៃតងដែលបង្កើតមានឡើងក្រោយឆ្នាំ 1965 ។ បដិវត្តន៍នេះបានស្តែងឱ្យឃើញតាមរយៈការធ្វើជម្រើសពូជធញ្ញជាតិច្រើនប្រភេទ ការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វចង្រៃ និងសមិទ្ធផលការងារបញ្ចូលទឹកធំៗ (សំណង់ទំនប់ អាងទឹក អណ្តូង) ។ ផ្ទៃដីបញ្ចូលទឹកបានកើនឡើងពីរដង ចាប់ពីបណ្តាឆ្នាំ 1960មក ។



*កសិកម្មនៅប្រទេសឥណ្ឌា*

កំណែទម្រង់ដីធ្លីដែលប្រព្រឹត្តទៅនៅក្រោយពេលឯករាជ្យ មិនអាចដោះស្រាយវិសមភាពនៅពិភពជនបទបានទេ ។ ដីធ្លីរបស់ពួកសាមិនដា(Zamindars )ត្រូវយកមកបែងចែកឡើងវិញបានដោយផ្នែកប៉ុណ្ណោះ ។ អាជីវករចំនួន 9% នៅតែកាន់កាប់ដី 45% នៃផ្ទៃដីកសិកម្មឥណ្ឌានៅឡើយ នៅក្នុងពេលដែល 78% នៃអាជីវករ មានដីដាំដុះតែ 32% នៃផ្ទៃដីសរុបប៉ុណ្ណោះ ។ ដីអាជីវកម្មធុនមធ្យមមានទំហំតូចគឺ 1.57 ហិកតា ។

## ៣.៣. ប្រទេសឧស្សាហកម្មថ្មីមួយ

សហភាពឥណ្ឌាបានស្គាល់នូវកំណើនឧស្សាហកម្មថ្មី ដែលធ្វើឱ្យប្រទេសនេះក្លាយជាប្រទេសឧស្សាហកម្មថ្មីមួយក្នុងពេលបច្ចុប្បន្ន ។ ឥណ្ឌាចេះធ្វើឱ្យមរតកបន្សល់ទុកដោយពួកអង់គ្លេសលេចចេញជាផ្លែផ្កាឡើង (ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក ការបង្កើតឧស្សាហកម្ម) និងចេះគាំទ្រដល់ក្រុមគ្រួសារឥណ្ឌាធំៗ (ពួកតាតានៅចាមសិតពួ) ។ ប្រទេសនេះក៏មានសហគ្រាសធុនតូច និងមធ្យមច្រើនណាស់ដែរ ។ ផ្នែកទីពីរនៃសេដ្ឋកិច្ចនេះតាង 30% នៃផលិតផលក្នុងស្រុកសរុប (GDP) និង 17% នៃប្រជាជនសកម្ម ។ ផលិតផលឧស្សាហកម្មផ្តល់បាន 76% នៃការនាំចេញនៅឆ្នាំ 1996 ។ សព្វថ្ងៃសហគ្រាសពហុជាតិរបស់ឥណ្ឌាបានបង្ហាញមុខនៅលើទីផ្សារមជ្ឈិមបូព៌ា ។

ឧស្សាហកម្មឥណ្ឌានៅមានផលិតភាពទាបនៅឡើយនៅផ្នែកខ្លះនៃឧស្សាហកម្មបញ្ញា ។ ប្រទេសឥណ្ឌាមានធនធានរ៉ែច្រើនមុខ (ធ្យូងថ្ម ដែក បុកស៊ិត ទង់ដែង) និងថាមពលវារីអគ្គិសនីដ៏ធំធេង ។ ឧស្សាហកម្មកប្បាសជាប់លេខមួយក្នុងប្រទេស ។ ផ្នែករថយន្តទទួលបានកិច្ចការពារតាំងពីយូរមកហើយ ។ ផ្នែកឧស្សាហកម្មបញ្ញារួមមានរោងចក្រផ្តល់ផលិតផលសម្រេច រោងចក្រនុយក្លេអ៊ែរ រោងចក្រផលិតកុំព្យូទ័រ ផ្កាយរណប និងយន្តហោះ ។

ជារួម សូចនាករសេដ្ឋកិច្ចឥណ្ឌា បើគិតតាម GDP បានជាប់លេខ 5 ក្នុងពិភពលោក អត្រាកំណើនពិតនៃ GDP មាន 6.5% (2009) 7.4% (2008) និង 9% (2007) GDP សម្រាប់ប្រជាជនម្នាក់ៗក្នុងមួយឆ្នាំមាន 3 100 ដុល្លារ (2009) 2 900 ដុល្លារ (2008) និង 2 800 ដុល្លារ (2007) និង GDP តាមផ្នែកដូចជាកសិកម្មតាងបាន 17.5% ឧស្សាហកម្ម 20% និងសេវាកម្ម 62.5% នៅឆ្នាំ 2009 ។

## ✍ ពាក្យគន្លឹះ

- **សូចនាករប្រជាសាស្ត្រ** : កំណត់ចង្អុលបង្ហាញទម្រង់ប្រជាជន ភាគច្រើនជាលេខ (ភាគរយឬចំនួន) សម្រាប់សម្គាល់ទម្រង់ប្រជាជននៃប្រទេសមួយឬតំបន់មួយ ។
  ***ឧទាហរណ៍ :*** អត្រាកំណើនប្រជាជន = 1.4%
  អត្រាលទ្ធភាពបង្កកំណើត = 3.2 នាក់
  សង្ឃឹមរស់ពីកំណើត = 65 ឆ្នាំ
- **បដិវត្តន៍បៃតង** : ការផ្លាស់ប្តូរយ៉ាងរហ័សផ្នែកកសិកម្មដែលកត់សម្គាល់ដោយការធ្វើជម្រើសពូជការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វចង្រៃ ប្រព័ន្ធបញ្ចូលទឹកសំខាន់ៗ ទិន្នផល និងផលិតផលខ្ពស់ ។
- **សហគ្រិន** : ម្ចាស់សហគ្រាស ម្ចាស់ក្រុមហ៊ុនធំៗ
- **ការិយាធិបតេយ្យ** : ក្រុមអ្នករដ្ឋការ អ្នកធ្វើការនៅការិយាល័យដែលប្រើអំណាចខុសច្បាប់ធ្វើតែតាមទម្លាប់ ។
- **សាមិនដា (Zamindars)** : ពួកអ្នកប្រមូលពន្ធ និងម្ចាស់ដីធំៗ ក្រោមនឹមអាណានិគមអង់គ្លេស ។

## ? សំណួរ

1. តើប្រទេសឥណ្ឌាជួបនឹងបញ្ហាអ្វីខ្លះ ? ចូររៀបរាប់ ។
2. តើឥណ្ឌាបានឆ្លងផុតអន្តរភាពប្រជាសាស្ត្រហើយឬនៅ ? ចូរពន្យល់ ។
3. ដូចម្តេចហៅថា បដិវត្តន៍បៃតង ? តើបដិវត្តន៍នេះអាចបញ្ចប់គ្រោះទុរ្ភិក្សនៅប្រទេសឥណ្ឌាបានដែរឬទេ ? ចូរបង្ហាញ ។
4. តើប្រទេសឥណ្ឌាប្រកាន់យករបបគ្រប់គ្រងនយោបាយបែបណា ?
5. តើគំរូអភិវឌ្ឍន៍សេដ្ឋកិច្ចបែបឥណ្ឌាមានលក្ខណៈដូចម្តេចខ្លះ ?

មេរៀនទី

# 3 ប្រទេសម៉ាឡេស៊ី

**ចប់មេរៀននេះ សិស្សអាច**

❑ រៀបរាប់ពីស្ថានភាពប្រជាជន ប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចប្រទេសម៉ាឡេស៊ី ។




*ផែនទីសណ្ឋានដីឧបទ្វីបម៉ាឡេស៊ី*

ក្នុងចំណោមប្រទេសទាំងដប់នៃអាស៊ីអាគ្នេយ៍ ប្រទេសម៉ាឡេស៊ីបានជាប់ចំណាត់ថ្នាក់ទី 5 ខាងផ្ទៃដី (329 758 Km$^2$ ) និងទី 6 ខាងចំនួនប្រជាជន (25 715 819 នាក់នៅឆ្នាំ 2009) ។ ប្រទេសនេះមានទីតាំងស្ថិតនៅលើឧបទ្វីបមលក្កាភាគខាងត្បូងមួយផ្នែក និងនៅលើកោះប័រនេអូភាគខាងជើងមួយផ្នែក ក្នុងចន្លោះខ្សែស្របទី 1° ដល់ទី 8° នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្ដោយទី 100° ដល់ទី 120° នៃរយៈបណ្ដោយខាងកើត ស្ថិតនៅក្រោមឥទ្ធិពលអាកាសធាតុត្រូពិកសមុទ្រ ដែលមានរបបខ្យល់មូសុង ។ កម្ពស់ទឹកភ្លៀងមាន 2500mm – 3000mm ។ សីតុណ្ហភាពមធ្យមមាន 21°C – 32°C ។

ក្នុងរយៈពេល 22 ឆ្នាំ(1981-2003) ប្រទេសម៉ាឡេស៊ីបានធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើន ពីការពឹងផ្អែកតែលើការនាំចេញរូបធាតុដើមទៅជាការពង្រីកឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍។ ក្រោយពេលចូលកាន់តំណែងនាយករដ្ឋមន្ត្រីលោក អាប់ឌូឡា ខិតខំបន្តអភិវឌ្ឍសេដ្ឋកិច្ច ដោយការទាក់ទាញវិនិយោគទៅលើវិស័យឧស្សាហកម្មបច្ចេកទេសខ្ពស់ បច្ចេកទេសវិទ្យាពេទ្យ និងឱសថ ។

# 1. ស្ថានភាពប្រជាជនម៉ាឡេស៊ី

## 1.1. របាយប្រជាជន

ប្រជាជនម៉ាឡេស៊ីជាង 80% ប្រមូលផ្តុំគ្នារស់នៅលើឧបទ្វីបឬម៉ាឡេស៊ីខាងលិចដែលមានផ្ទៃដីតែ 40% នៃផ្ទៃប្រទេសប៉ុណ្ណោះ ។ ចំណែកម៉ាឡេស៊ីដីកោះ ឬម៉ាឡេស៊ីខាងកើត(រដ្ឋសារ៉ាវ៉ាក់ និងរដ្ឋសាបា) មានរបាយប្រជាជនមិនសូវញឹក នាំឱ្យដង់ស៊ីតេប្រជាជនមធ្យមខ្ទង់ចុះថយយ៉ាងសម្បើម ។ ប្រជាជនមានលក្ខណៈជាតិពន្ធុខុសប្លែកពីប្រជាជននៅលើឧបទ្វីបដែលមានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចរីកចម្រើន និងសម្បូរបែបជាង ពោលគឺ សកម្មភាពសេដ្ឋកិច្ច នយោបាយ វប្បធម៌ ប្រមូលផ្តុំខ្លាំងតែនៅលើឧបទ្វីបតែប៉ុណ្ណោះ ។



ប្រជាជនម៉ាឡេស៊ី

ប្រជាជនម៉ាឡេស៊ីចម្រុះដោយជនជាតិ ។ ជនជាតិម៉ាឡេ 61.7% ចិន 29.7% ឥណ្ឌា 8.1% និងជនជាតិដទៃទៀត 0.5% ។ ជនជាតិចិនមានឥទ្ធិពលយ៉ាងខ្លាំងក្នុងជីវភាពសេដ្ឋកិច្ចម៉ាឡេស៊ី ។ ពួកនេះធ្វើដំណើរមកពីប្រទេសចិនច្រើនឡើងៗ ដោយសារលក្ខខណ្ឌសង្គម និងធម្មជាតិម៉ាឡេស៊ីដែលមានការអនុគ្រោះដល់ការរស់នៅរបស់ពួកគេ ។ នៅលើកោះជនជាតិម៉ាឡេ ចិន ឥណ្ឌា មានមិនសូវច្រើនទេ ។ នៅក្នុងរដ្ឋសារ៉ាវ៉ាក់ ជនជាតិទាំងបីក្រុមនេះមានមិនលើសពី 50% នៃប្រជាជនឡើយ ។ ពួក អ៊ីបាន (Ibans) ជាក្រុមអ្នកស្រុកអាយសំខាន់មួយមានចំនួនជិត 30% នៃចំនួនប្រជាជនសរុប ។ នៅក្នុងរដ្ឋសាបា គេពិបាកដឹងពីចំនួនអ្នកស្រុកអាយឱ្យពិតប្រាកដណាស់(ប្រហែលជា 65%) ជាតួលេខដែលមានការលាក់កំបាំង ។

## 1.2. ទម្រង់ប្រជាជន

ទម្រង់តាមអាយុនៃប្រជាជនម៉ាឡេស៊ីនៅឆ្នាំ 2009 មាន ៖

- ក្រុមអាយុពី 0-14ឆ្នាំ ស្មើនឹង 31.4% ដែលក្នុងនោះ កុមារាមានចំនួន4 153 621 នាក់ កុមារីមាន 3 914 962 នាក់ ។
- ក្រុមអាយុពី 15-64 ឆ្នាំស្មើនឹង 63.6% (បុរសមានចំនួន 8 210 373 នាក់ ស្ត្រីមាន 8 143 043 នាក់) ។
- ក្រុមអាយុ 65 ឆ្នាំឡើងស្មើនឹង 5% (បុរសមានចំនួន 569 245 នាក់ ស្ត្រីមាន 724 575 នាក់) ។

តាមអត្រាខាងលើ គេអាចនិយាយបានថា ប្រជាជនម៉ាឡេស៊ីនៅមានទម្រង់ក្មេងនៅឡើយ ពោលគឺចំនួនកុមារមានអត្រាខ្ពស់ដល់ទៅ 31.4% ធៀបនឹងប្រទេសអភិវឌ្ឍដូចជាជប៉ុនមានត្រឹមតែ 13.5% សហភាពអឺរ៉ុប 15.44% ប៉ុណ្ណោះ ។

បើនិយាយពីទម្រង់តាមភេទវិញ ឃើញថាប្រជាជនម៉ាឡេស៊ីមានអត្រាភេទដូចខាងក្រោម ៖

- ទារកទើបកើត 1.07 ទារក ទារិកា
- ក្រោម 15ឆ្នាំ 1.06% កុមារា កុមារី
- 15-64ឆ្នាំ 1.01% បុរស ស្ត្រី
- 65 ឆ្នាំឡើង 0.79 បុរស ស្ត្រី
- ប្រជាជនសរុប 1.01 បុរស ស្ត្រី

តាមរយៈអត្រាភេទនេះ ប្រទេសម៉ាឡេស៊ីមានចំនួនបុរសច្រើនជាងស្ត្រី ផ្ទុយពីប្រទេសខ្លះទៀតនៃអាស៊ីអាគ្នេយ៍ ឬនៃទ្វីបអាស៊ី ដែលចំនួនស្ត្រីតែងមានច្រើនជាងបុរស ។

ចំណែកសូចនាករប្រជាសាស្ត្រផ្សេងៗទៀតរបស់ប្រទេសម៉ាឡេស៊ី មានអត្រាជាតិប្រមាណ 2.224% អត្រាមរណប្រមាណ 0.502% អត្រាកំណើនប្រជាជន 1.72% អត្រាមរណប្រមាណកុមារ 1.587% លទ្ធភាពបង្កកំណើតរបស់ស្ត្រី 2.95 នាក់ សង្ឃឹមរស់ពីកំណើត 73.29 ឆ្នាំ (បុរស 70.56ឆ្នាំ ស្ត្រី 76.21 ឆ្នាំ) អត្រាអក្ខរភាព 88.7% ។ ប្រជាជនទីក្រុងនៅម៉ាឡេស៊ីមាន 70% នៃប្រជាជនសរុប(ឆ្នាំ 2008) ។

ចំពោះអ្នកកាន់សាសនាវិញមាន ឥស្លាម 60.4 % ពុទ្ធសាសនិក 19.2% គ្រិស្តសាសនិក 9.1% ហិណ្ឌូសាសនិក 6.3% ខុងជឺនិយម និងតាវនិយម(ពួកចិន) 2.6% ផ្សេងៗទៀត 1.6% និងអ្នកគ្មានសាសនា 0.8 % ។

ភាសាប្រើផ្លូវការគឺភាសា បាហាសាម៉ាឡេ ។ ក្រៅពីនេះមានភាសាអង់គ្លេស ចិន តាមីល តេលេគូ ម៉ាឡាយ៉ាឡាំ បញ្ចាប៊ី ថៃ ។ នៅម៉ាឡេស៊ីខាងកើតមានភាសាអ្នកស្រុកអាយជាច្រើន សំខាន់ជាងគេ គឺភាសាអ៊ីបង់ និងកាដាសង់ ។

## 2. ប្រព័ន្ធនយោបាយម៉ាឡេស៊ី

ប្រទេសម៉ាឡេស៊ីបានទទួលឯករាជ្យពីអង់គ្លេសនៅ ថ្ងៃ 31 សីហា 1957 និងជាថ្ងៃខែឆ្នាំដែលដាក់ឱ្យប្រើរដ្ឋធម្មនុញ្ញថ្មីដែរ ។ រដ្ឋធម្មនុញ្ញឆ្នាំ 1957 ត្រូវបានធ្វើវិសោធនកម្មជាច្រើនសា ដែលលើកចុងក្រោយនៅឆ្នាំ 2007 ។ ប្រទេសនេះមានឈ្មោះជាសហព័ន្ធម៉ាឡេស៊ី ហៅកាត់ថាម៉ាឡេស៊ី ប្រកាន់យករបបគ្រប់គ្រងតាមបែបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ។

## 2.1. របៀបរៀបចំផ្នែករដ្ឋបាល

ម៉ាឡេស៊ីជារដ្ឋសហព័ន្ធ មានរដ្ឋទាំងអស់ចំនួន 13 ជាសមាជិក និងដែនដីក្រួតត្រារបស់សហព័ន្ធចំនួនបីទៀត គឺជានីកូឡាឡាំពួ ឡាប៊ូអាន (Labuan ) និងបុត្រាជ័យ (Putrajaya) ។ កូឡាឡាំពួជារាជធានីមានប្រជាជន 1 410 000 នាក់នៅឆ្នាំ 2001 ហើយនៅឆ្នាំ 2008 មានប្រជាជនចំនួន 1 809 699 នាក់ ។ ចំណែកក្រុងដទៃទៀតក៏មានកំណើនប្រជាជនជាលំដាប់ដែរ ។

## 2.2. របៀបរៀបចំផ្នែកនយោបាយ

ម៉ាឡេស៊ីជារដ្ឋសហព័ន្ធ ប្រកាន់យករបបនយោបាយបែបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ និងប្រជាធិបតេយ្យសេរីពហុបក្ស ឈរលើការបែងចែកអំណាចជាស្ថាប័នរដ្ឋសំខាន់បីគឺ ៖

### ក. អំណាចនីតិប្រតិបត្តិ

ដឹកនាំដោយប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល ។

- ប្រមុខរដ្ឋ គឺជាតួអង្គព្រះមហាក្សត្រ ឬព្រះចៅស៊ុលតង់ដែលត្រូវជ្រើសតាំងដោយការបោះឆ្នោតក្នុងបណ្តាក្សត្រទាំង 9 អង្គនៃរដ្ឋនានាសម្រាប់អាណត្តិ 5 ឆ្នាំ ។
- ប្រមុខរដ្ឋាភិបាលគឺជានាយករដ្ឋមន្ត្រី ចាត់តាំងក្នុងបណ្តាសមាជិករដ្ឋសភា(សភាតំណាងរាស្ត្រ) ណាម្នាក់ ដែលទទួលបានការគាំទ្រដោយសំឡេងភាគច្រើន ពីសមាជិកសភាសម្រាប់អាណត្តិ 5 ឆ្នាំ ។ តាំងពីបានឯករាជ្យមក តំណែងនាយករដ្ឋមន្ត្រីត្រូវបានទៅប្រធានបក្ស "អង្គការរួបរួមជាតិម៉ាឡេ UMNO(United Malays National Organization)" ។

### ខ. អំណាចនីតិប្បញ្ញត្តិ

គ្រប់គ្រងដោយសភាពីរ គឺព្រឹទ្ធសភា និងសភាតំណាងរាស្ត្រ(រដ្ឋសភា) ។

- ព្រឹទ្ធសភាមានអាសនៈទាំងអស់ចំនួន 70 គឺ 44 អាសនៈតែងតាំងដោយព្រះចៅស៊ុលតង់ 26 អាសនៈទៀតបានមកពីសភារបស់រដ្ឋនានា សម្រាប់អាណត្តិ 3 ឆ្នាំ កំណត់បានត្រឹមតែ 2 អាណត្តិ ។
- សភាតំណាងរាស្ត្រមាន 222 អាសនៈ បោះឆ្នោតជ្រើសរើសដោយប្រជារាស្ត្រសម្រាប់អាណត្តិ 5 ឆ្នាំ ។ ការបោះឆ្នោតប្រព្រឹត្តទៅជាសកល ដោយប្រជារាស្ត្រដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ ។

### គ. អំណាចតុលាការ

គ្រប់គ្រងដោយតុលាការស៊ីវិល (Civil Court) និងតុលាការ សារិអា (Sharia Court) ។

- តុលាការស៊ីវិលរួមមានតុលាការសហព័ន្ធ សាលាឧទ្ធរណ៍ តុលាការម៉ាឡេស៊ីជាន់ខ្ពស់នៃឧបទ្វីប និងតុលាការជាន់ខ្ពស់នៃរដ្ឋសាបា និងសារ៉ាវ៉ាក់ នៅលើកោះប័រនេអូ ។ ចៅក្រមទាំងឡាយត្រូវចាត់តាំងដោយព្រះចៅស៊ុលតង់ ដែលផ្តល់ការប្រឹក្សាពីនាយករដ្ឋមន្ត្រី ។
- តុលាការសារិអារួមមាន សាលាឧទ្ធរណ៍ សារិអាតុលាការ សារិអាជាន់ខ្ពស់ និងតុលាការសារិអាថ្នាក់ទាប កម្រិតថ្នាក់រដ្ឋ និងពាក់ព័ន្ធនៅនឹងសាសនា និងបញ្ហាគ្រួសារដូចជា សិទ្ធិព្យាបាល ការលែងលះប្តីប្រពន្ធនិងមតិក(សម្រាប់តែពួកឥស្លាមប៉ុណ្ណោះ) ។ រាល់សេចក្តីសម្រេចរបស់តុលាការសារិអាមិនអាចត្រូវបានធ្វើឧទ្ធរណ៍ទៅកាន់តុលាការស៊ីវិលឡើយ ។

នៅសហព័ន្ធម៉ាឡេស៊ីមានគណបក្សនយោបាយជាច្រើនដែលបង្កើតជាចង្កោមគណបក្សធំៗពីរ :

- រណសិរ្សជាតិ BN រួមមានគណបក្សចំនួន 13 ដូចជា PGRM LDP MCA MIC PBRS PBS PBB PRS SUPP UMNO UPKO PPP និង SPDP ។
- សម្ព័ន្ធប្រជារាស្ត្រ PR រួមមាន DAP PAS PKR SNAP ជាគណបក្សប្រឆាំង ។ គណបក្សឯករាជ្យ SAPP នេះជាគណបក្សមួយដាច់តែឯង ។

ក្នុងការបោះឆ្នោតជ្រើសរើសសភាតំណាងរាស្ត្រកាលពីថ្ងៃ 8 មីនា 2008 រណសិរ្សជាតិ BN បានសំឡេងឆ្នោតចំនួន 50.3% បក្សប្រឆាំងបាន 46.8% បក្សផ្សេងៗបាន 2.9% ។

## ៣. សេដ្ឋកិច្ចម៉ាឡេស៊ី

សហព័ន្ធម៉ាឡេស៊ី ជាប្រទេសមួយនៃអាស៊ីអាគ្នេយ៍ ដែលបានអភិវឌ្ឍសេដ្ឋកិច្ចខ្លួនតាមគំរូនាគទាំងបួនប្រចាំអាស៊ី (កូរ៉េខាងត្បូង តៃវ៉ាន់ ហុងកុង និងសិង្ហបុរី)ក្នុងក្តីជឿជាក់ថានឹងអាចឆ្លងកាត់អន្តរកាលពីសេដ្ឋកិច្ចដែលធ្លាប់តែពឹងផ្អែកលើអាជីវកម្មរ៉ែ និងកសិកម្ម ទៅកាន់សេដ្ឋកិច្ចមួយដែលឈរលើមូលដ្ឋានឧស្សាហកម្មកាន់តែខ្លាំងឡើង ។ បច្ចុប្បន្ន ម៉ាឡេស៊ីបានក្លាយទៅជាកូនខ្លា(ឬកូននាគ) ដូចហ្វីលីពីន និងឥណ្ឌូណេស៊ីដែរ ។

### ៣.១. នយោបាយសេដ្ឋកិច្ចថ្មី

នៅឆ្នាំ 1971 ពេលផ្សព្វផ្សាយផែនការប្រាំឆ្នាំទីពីរ(1971-1975) នយោបាយសេដ្ឋកិច្ចថ្មីមួយ NEP (New Economic Policy) ត្រូវបានប្រកាសឡើងជាផ្លូវការ ។ NEP មានគោលដៅធំៗពីរគឺការបំបាត់ភាពក្រីក្រ និងការរៀបចំរចនាសម្ព័ន្ធសង្គមជាថ្មី ក្នុងន័យកាត់បន្ថយ និងបំបាត់ចោល ជាយថាហេតុនូវឯកទេសកម្មមុខរបររបស់ក្រុមជនជាតិ ពិសេសជនជាតិចិន ។ NEP បានផ្តល់អាទិភាពច្រើន

បែបយ៉ាងណាស់ដល់ជនជាតិម៉ាឡេ ដូចជាការកំណត់យកភាសាបាហាសាម៉ាឡេ ជាភាសាផ្លូវការប្រើប្រាស់ក្នុងផ្នែករដ្ឋបាល ក្នុងការសិក្សាអប់រំ ជាហេតុនាំឱ្យខូចប្រយោជន៍ដល់ក្រុមជនជាតិដទៃមានចិន ឬតាមិលជាដើម ។ ជនជាតិម៉ាឡេបានឈានចូលនៅក្នុងផ្នែកឧស្សាហកម្មថែមទៀត(ប្រេងកាត ការដឹកជញ្ជូន កសិកម្ម សំណង់រថយន្ត...)ដែលជាភាពអនុគ្រោះដល់ការលេចឡើងនៃស្រទាប់សហគ្រិនថ្មីមួយ តាមរយៈការបណ្តុះបណ្តាលមុខរបរ ការបង្កើត និងការផ្តល់ហិរញ្ញវត្ថុដល់សហគ្រាសតូច និងមធ្យមរបស់ជនជាតិម៉ាឡេ ។ តាមពិតទៅ NEP បានជោគជ័យក្នុងការបង្កើតស្រទាប់អ្នកជំនួញថ្នាក់កណ្តាលឬថ្នាក់ខ្ពស់ជាជនជាតិម៉ាឡេ ។

## 3.2. ការពង្រីកវិស័យកសិកម្ម


*ចំការកៅស៊ូនៅម៉ាឡេស៊ី*

ការងារដ៏ធំធេងនេះបាននាំឱ្យមានកំណើនផ្នែកកសិកម្មយ៉ាងជាក់ស្តែង ។ នៅចន្លោះឆ្នាំ 1965-1985 ផ្ទៃដីសរុបសម្រាប់ដំណាំប្រាំមុខបានកើនពី 2.7 ទៅ 4.6 លានហិកតា គិតជាអត្រាកំណើនមាន 70% ។ ការងារនេះអាចសម្រេចឡើងបានដោយសារតែមានការកែប្រែក្នុងរបាយផលិតកម្ម ។ ហេតុដូច្នេះហើយ បានជានៅសម័យឯករាជ្យ បរិមាណកៅស៊ូនាំចេញរបស់ម៉ាឡេស៊ីមានកម្រិតខ្ពស់ប្លែកគឺ 55% នៃការនាំចេញសរុបនៅឆ្នាំ 1961 ។ នៅឆ្នាំ 1983 ការនាំចេញកៅស៊ូមិនលើសពី 11.0 % ទេ ។ នៅឆ្នាំ 1991 ការនាំកៅស៊ូចេញធ្លាក់មកនៅត្រឹម 3.1% ។ នៅឆ្នាំ 2003 ប្រទេសម៉ាឡេស៊ីផលិតកៅស៊ូបាន 589 000 តោនស្មើ 7.9% នៃផលិតផលពិភពលោក ទទួលបានចំណាត់ថ្នាក់លេខ 4 បន្ទាប់ពីប្រទេសថៃ ឥណ្ឌូណេស៊ី និងឥណ្ឌា ។ កម្មវិធីពង្រីកដំណាំដូងប្រេងដ៏ធំសម្បើមមួយ ត្រូវបានដាក់ឱ្យអនុវត្តលើផ្ទៃដីពី 100 000 ទៅ 1 400 000 ហិកតា នៅចន្លោះឆ្នាំ 1965-1985 ។ បន្ថែមពីលើនេះ ដំណាំដូងប្រេងជាគោលដៅមួយនៃការធ្វើឱ្យប្រសើរឡើងផ្នែកបច្ចេកទេសផលិតកម្ម និងការកាត់បន្ថយផ្ទៃដីដាំដុះ នៅពេលដែលដំណាំកាកាវបានរីកដុះដាលឡើង ហើយជួនកាលដំណាំនេះក៏ជំនួសដំណាំដូងតែម្តង ឬជួនក៏ដាំចន្លោះដើមដូង ។ ចុងបញ្ចប់ គឺដំណាំស្រូវដែលទទួលបាននូវប្រពលវប្បកម្មយ៉ាងខ្លាំងក្លាបំផុត ។ ទោះបីដំណាំនេះមានការថយចុះនៅដើមទសវត្សរ៍ឆ្នាំ 1980 ក៏វាបានជួយកាត់បន្ថយការនាំចូលស្រូវបានយ៉ាងច្រើន និងបានបង្កើនវត្តមានរបស់រដ្ឋនៅក្បែរសហគមន៍ជនជាតិម៉ាឡេថែមទៀតផង ។

## ៣.៣. យុទ្ធសាស្ត្រឧស្សាហកម្ម

NEP ផ្ដោតលើអន្តរាគមន៍ផ្ទាល់របស់រដ្ឋលើវិស័យកសិកម្ម និងការរៀបចំលំហដែនដីក៏ពិតមែនហើយ តែក៏ផ្ដោតលើនយោបាយឧស្សាហកម្មផងដែរ ។ ផែនការកម្មនៃលំហអភិវឌ្ឍន៍ឧស្សាហកម្មហាក់ដូចជាមិនសូវមានលក្ខណៈទូទៅ និងមិនសូវទទួលបានការធានារ៉ាប់រងដូចវិស័យកសិកម្មក៏ដោយ ក៏ផែនការកម្មសេដ្ឋកិច្ចនៃឧស្សាហកម្មក៏មានភាពខ្លាំងក្លាណាស់ដែរ ។ គោលដៅពីរដែលមានលក្ខណៈផ្ទូវការ និងបង្គ្រប់ត្រូវបានលើកឡើង ទីមួយ ការបង្កើតការងារឧស្សាហកម្មដែលជាជំនួយកាន់តែច្រើនឡើងជំនួសការថយចុះការងារកសិកម្ម ទីពីរការបង្កើនការចូលរួមក្នុងផ្នែកឧស្សាហកម្មរបស់ពួកម៉ាឡេ ទាំងការគ្រប់គ្រងក៏ដូចជាកម្លាំងពលកម្ម ។ ឆ្លើយតបទៅនឹងគោលបំណងទាំងនេះ បន្ថែមពីលើការជំរុញ និងការការពារដល់ការចូលរួមរបស់ពួកម៉ាឡេទៅក្នុងការងារសហគ្រាសតូច និងមធ្យម រដ្ឋម៉ាឡេស៊ីបានបើកទូលាយដល់ការចូលមកធ្វើវិនិយោគរបស់ពួកបរទេសថែមទៀត ។ ហេតុនេះហើយទើបគេឃើញបណ្ដាញរោងចក្រឧស្សាហកម្មដ៏សំខាន់មួយបានរីកដុះដាលជាច្រើនលើជម្រាលភ្នំប៉ែកខាងលិចនៃឧបទ្វីប និងនៅខាងក្នុងតំបន់ទំនេរ ។ ការរីកចម្រើននេះបានបង្ហាញឱ្យឃើញផងដែរ នូវផ្នែកផលិតកម្មប្រេងកាត ទាំងនៅលើជម្រាលទាំងពីរនៃឧបទ្វីប ក៏ដូចនៅលើកោះប័រនេអូ ។ រដ្ឋអំណាចមជ្ឈិមក៏បានយកចិត្តទុកដាក់លើការប្រមូលផ្ដុំឧស្សាហកម្មនៅក្នុងមជ្ឈមណ្ឌលក្រុងសំខាន់ៗផងដែរ ។ ផលិតកម្មអ៊ីដ្រូកាបួនៅក្នុងលំហសមុទ្រ ទាំងនៅឆ្នេរខាងកើតនៃឧបទ្វីប ទាំងនៅតាមឆ្នេរនៃរដ្ឋលើកោះប័រនេអូ ក៏មានសារៈសំខាន់ណាស់ដែរ ។ ក្រៅពីចំណែកដ៏សំខាន់ដែលមាននៅក្នុងការនាំចេញ ឧស្ម័នធម្មជាតិ និងជាពិសេសប្រេងកាត បានចូលរួមទៅក្នុងការប៉ុនប៉ងពីរគឺឧស្សាហូបនីយកម្មសេដ្ឋកិច្ចជាតិ និងការធ្វើវិមជ្ឈការឧស្សាហកម្មឱ្យទៅនៅក្រៅពីជម្រាលភ្នំភាគខាងលិចនៃឧបទ្វីប ។

## ៣.៤. វិស័យពាណិជ្ជកម្មនិងទេសចរណ៍

ជញ្ជីងពាណិជ្ជកម្មរបស់ប្រទេសម៉ាឡេស៊ីមានតុល្យភាពចាប់ពីឆ្នាំ 1993 មក ។ នៅឆ្នាំ 2008 ការនាំទំនិញចេញគិតជាទឹកប្រាក់មាន 198.7 ពាន់លានដុល្លារ និងការនាំទំនិញចូលមាន 154.7 ពាន់លានដុល្លារ ពាណិជ្ជកម្មម៉ាឡេស៊ីទទួលបានផលចំណេញចំនួន 44 ពាន់លានដុល្លារ ។

- ទំនិញនាំចេញទៅក្រៅប្រទេសមានគ្រឿងបរិក្ខារអេឡិចត្រូនិក រថយន្ត ប្រេងកាត ឧស្ម័នធម្មជាតិ ឈើ កៅស៊ូ ប្រេងដូង តែ សំណប៉ាហាំង ... ។ ប្រទេសដៃគូមាន សិង្ហបុរី (14.7 %) សហរដ្ឋអាមេរិក(12.5 %) ជប៉ុន(10.8 %) ចិន(9.5 %) ថៃ(4.8%) ហុងកុង(4.3 %)ក្នុងឆ្នាំ 2008 ។

- ទំនិញនាំចូលមានឧបករណ៍អេឡិចត្រូនិក គ្រឿងយន្ត ផលិតផលប្រេងកាត ប្លាស្ទិច យានយន្ត ដែក ដែកថែប ផលិតផលគីមី ផលិតផលអាហារ ភេសជ្ជៈ ... ។ ប្រទេសដៃគូមានចិន(12.8%) ជប៉ុន(12.5%) សិង្ហបុរី(11%) សហរដ្ឋអាមេរិក(8%) ថៃ(5.6%) កូរ៉េខាងត្បូង (4.6%) ឥណ្ឌូណេស៊ី(4.6%) អាល្លឺម៉ង់(4.3%) នៅឆ្នាំ 2008 ។

ប្រទេសម៉ាឡេស៊ីបានខិតខំលើកស្ទួយវិស័យទេសចរណ៍តាំងពីឆ្នាំ 1972 មកម្ល៉េះ ដោយធ្វើសហប្រតិបត្តិការជាមួយក្រុមហ៊ុនទេសចរណ៍ក្នុងស្រុក និងអន្តរជាតិ ដើម្បីរៀបចំរមណីយដ្ឋាន ។ មជ្ឈមណ្ឌលទេសចរណ៍សំខាន់ៗមាន មណ្ឌលវប្បធម៌ សិល្បៈ ឆ្នេរសមុទ្រ រមណីយដ្ឋានធម្មជាតិនានា... ។ ចំនួនអ្នកទេសចរមកទស្សនាប្រទេសនេះមាន 7.2 លាននាក់ (ឆ្នាំ 1994) ដែលកាលពីឆ្នាំ 1993 មានត្រឹមតែ 6.5 លាននាក់ប៉ុណ្ណោះ គិតជាអត្រាកំណើនមាន 10.7% ។ ទេសចរបរទេសមានមកពីប្រទេសអូស្ត្រាលី ឥណ្ឌា ជប៉ុន អង់គ្លេស ហុងកុង សហរដ្ឋអាមេរិក បារាំង ... ។

## ✍ ពាក្យគន្លឹះ

- **ឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់**: អាចហៅថាឧស្សាហកម្មបញ្ញា ឧស្សាហកម្មរូបធាតុប្រផេះ ឬឧស្សាហកម្មស្រួចស្រាល់ គឺជាប្រភេទឧស្សាហកម្មទំនើបបំផុតដែលផលិតមុខទំនិញ ដែលទាមទារជំនាញខ្ពស់នៃក្រុមកម្មករ ការសិក្សាស្រាវជ្រាវជាមុន ការផ្សាំខ្លួនទៅនិងបន្លាស់ប្តូរថេរ និងឆាប់រហ័សផ្នែកបច្ចេកវិទ្យា ។
- **សុវន្នីកម្ម** : ការធ្វើឱ្យកាន់តែល្អប្រសើរឡើង ។
- **សារិអា (Sharia)** : ច្បាប់ឥស្លាមយកចេញពីគម្ពីរកូរ៉ាន និងប្រពៃណីអ៊ីស្លាម ។

## ? សំណួរ

1. តើប្រទេសម៉ាឡេស៊ីស្ថិតនៅត្រង់ណា ? មានលក្ខណៈសណ្ឋានដូចម្តេច ?
2. តើប្រជាជនម៉ាឡេស៊ី មានជាតិពន្ធុសំខាន់អ្វីខ្លះ ?
3. តើប្រជាជនម៉ាឡេស៊ីមានទម្រង់ដូចម្តេច ?
4. ចូរប្រៀបធៀបតួអង្គព្រះមហាក្សត្រខ្មែរ និងព្រះចៅស៊ុលតង់ម៉ាឡេស៊ី លើចំណុចសំខាន់ៗមានការជ្រើសតាំង និងសិទ្ធិអំណាច ។
5. អ្វីហៅថា "សារិអា" ? NEP មានន័យពេញលេញជាភាសាជាតិយើងដូចម្តេច ?
6. តើ NEP ម៉ាឡេស៊ីមានគោលដៅអ្វីខ្លះ ?

មេរៀនទី

# 4 ប្រទេសព្រុយណេ

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីស្ថានភាពប្រជាជន ប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចប្រទេសព្រុយណេ ។

*ផែនទីប្រទេសព្រុយណេ*




ប្រទេសព្រុយណេ ជារាជាណាចក្រដ៏តូចមួយ ស្ថិតនៅភាគខាងជើងនៃកោះប័រនេអូ ក្នុងតំបន់អាស៊ីអាគ្នេយ៍ចន្លោះខ្សែស្របទី 4° ដល់ទី 5°03' នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្តោយទី 114°06' ដល់ទី 115°24' នៃរយៈបណ្តោយខាងកើត ដាច់ចេញជាពីរផ្នែកដោយផ្ទាំងដីដែលជាជ្រលងទន្លេលីមបាំង ទឹកដីរបស់រដ្ឋសារ៉ាវ៉ាក់(ម៉ាឡេស៊ី) ។ សណ្ឋានដីមានលក្ខណៈជាទំនាបឆ្នេរ ដែលងើបឡើងទៅកាន់ជើងភ្នំនៅប៉ែកខាងកើត និងជាទំនាបសម្បូរកូនភ្នំនៅប៉ែកខាងលិច ។ ភ្នំប៊ូឃីតផាកុង Bukit Pagon (1850m) ជាកំពូលខ្ពស់របស់ព្រុយណេ ។ ប្រទេសនេះមានអាកាសធាតុប្រហាក់ប្រហែលគ្នានឹងអាកាសធាតុម៉ាឡេស៊ីដែរ ។ ព្រុយណេមានផ្ទៃដីសរុប 5 770 $km^2$ និងមានប្រជាជនទាំងអស់ 0.388 លាននាក់(ឆ្នាំ 2009) ។

ប្រទេសព្រុយណេស្ថិតក្រោមអាណាព្យាបាលអង់គ្លេសនៅឆ្នាំ 1888 ទទួលបានឯករាជ្យនៅឆ្នាំ 1984 គ្រប់គ្រងដោយព្រះចៅស៊ុលតង់ មានផលិតផលក្នុងស្រុកសរុប GDP សម្រាប់មនុស្សម្នាក់ៗខ្ពស់បំផុតនៅអាស៊ីអាគ្នេយ៍បន្ទាប់ពីសិង្ហបុរីដែលបានមកពីភាពសម្បូរប្រេងកាត និងឧស្ម័នធម្មជាតិ ។

# 1. ស្ថានភាពប្រជាជន

ប្រជាជនព្រុយណេចម្រុះដោយជនជាតិជាច្រើន មានម៉ាឡេ 66.3% ចិន 11.2% អ្នកស្រុកអាយ ឬជនជាតិដើមម្ចាស់ស្រុក 3.4% និងផ្សេងៗទៀត 19.1% ឆ្នាំ 2004 ។ ចំណែកសាសនិកជនវិញ ក៏មានច្រើនពួកច្រើនក្រុមដែរ ដូចជាពួកឥស្លាម 67% ពុទ្ធសាសនិក 13% គ្រិស្តសាសនិក 10% ផ្សេងៗទៀត (រួមទាំងជំនឿម្ចាស់ស្រុកដើម) 10% ។ ភាសាប្រើប្រាស់ជាផ្លូវការគឺភាសាបាហាសាម៉ាឡេ ។ ភាសាដទៃទៀតមានអង់គ្លេស ចិន ... ។

## 1.1. របាយប្រជាជន

ប្រទេសព្រុយណេ ជាប្រទេសមួយដែលមានប្រជាជនតិចជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ ។ ដង់ស៊ីតេប្រជាជនមាន 67 នាក់/$km^2$ ជាមធ្យម ។ ប្រជាជនព្រុយណេចំនួន 97% រស់នៅលើទឹកដីភាគខាងលិច ផ្ទុយទៅវិញ ប្រជាជនមានចំនួនប្រហែល 10 000 នាក់ប៉ុណ្ណោះ ដែលរស់នៅតំបន់ភ្នំនៃទឹកដីប៉ែកខាងកើត ។ រាជធានីបង់ដាស៊េរីបេកាវ៉ាន់ មានប្រជាជនរស់នៅប្រហែល 130 000 នាក់ ។ ភាគច្រើននៃប្រជាជនព្រុយណេតាំងទីរស់នៅតាមទំនាបឆ្នេរ ។

## 1.2. ទម្រង់ប្រជាជន

ទម្រង់តាមអាយុរបស់ប្រជាជនព្រុយណេមានដូចខាងក្រោម ៖

- ក្រុមអាយុ 0-14 ឆ្នាំ មាន 27.2% (បុរសមាន 53 400 នាក់ ស្ត្រីមាន 50 333 នាក់) ឆ្នាំ 2008 ។
- ក្រុមអាយុ 15-64 ឆ្នាំមាន 69.6% (បុរសមាន 132 895 នាក់ ស្ត្រីមាន 132 391 នាក់) ។
- ក្រុមអាយុចាប់ពី 65 ឆ្នាំឡើងមាន 3.2% (បុរសមាន 5 927 នាក់ ស្ត្រីមាន 6 428 នាក់) ។

តាមរយៈតួលេខខាងលើនេះ ឃើញថាប្រជាជនព្រុយណេស្ថិតក្នុងទម្រង់ក្មេងនៅឡើយ ព្រោះចំនួនកុមារច្រើន (27.2%) ធៀបទៅនឹងប្រទេសអភិវឌ្ឍមានត្រឹមតែជាង 10% តែប៉ុណ្ណោះ ។ ចំណែកមនុស្សពេញវ័យពលកម្មមានអត្រាខ្ពស់ (69.6%) នេះបង្ហាញថាព្រុយណេសម្បូរកម្លាំងរុញច្រានសេដ្ឋកិច្ច តែទន្ទឹមនឹងនេះ គេឃើញមានអ្នកគ្មានការងារធ្វើចំនួន 4% ផងដែរ ។

ទម្រង់តាមភេទបង្ហាញនូវអត្រាទំនាក់ទំនងភេទដូចនេះ

- ពេលកើត : 1.05 បុរស ស្ត្រី
- ក្រោម 15 ឆ្នាំ : 1.06 បុរស ស្ត្រី

- ក្រុម 15-64 ឆ្នាំ : 1.00 បុរស ស្ត្រី
- ចាប់ពី 65 ឆ្នាំឡើង : 0.92 បុរស ស្ត្រី
- ប្រជាជនសរុប : 1.02 បុរស ស្ត្រី មានន័យថា បើស្ត្រីមានចំនួន 100 នាក់ នោះចំនួនបុរសមាន 102 នាក់ ។ ជាទូទៅ នៅប្រទេសព្រុយណេ ចំនួនបុរសមានច្រើនជាងស្ត្រីដែលផ្ទុយពីនៅប្រទេសកម្ពុជា ដែលចំនួនស្ត្រីច្រើនជាងបុរស (0.96 បុរស ស្ត្រី) ។

ក្រៅពីនេះ នៅមានសូចនាករប្រជាសាស្ត្រផ្សេងៗទៀតសម្រាប់វាយតម្លៃទៅលើវឌ្ឍភាពសង្គមសេដ្ឋកិច្ចព្រុយណេ ៖

- អត្រាជាតិប្រមាណមាន 1.839% អត្រាមរណប្រមាណ 0.328% អត្រាកំណើនប្រជាជន 1.511% (ឆ្នាំ 2008) ។
- អត្រាមរណប្រមាណកុមារ 1.269% អត្រាលទ្ធភាពបង្កកំណើត 1.90 នាក់ ស្ត្រីម្នាក់ អត្រាអក្ខរភាព(អាយុ 15 ឆ្នាំឡើងដែលចេះអាន និងសរសេរ) 92.7% (ជំរឿនឆ្នាំ 2001) និងសង្ឃឹមរស់ពីកំណើត 75.52 ឆ្នាំ ។

តាមសូចនាករទាំងនេះ គេអាចសន្និដ្ឋានបានថា សង្គមសេដ្ឋកិច្ចព្រុយណេមានកម្រិតអភិវឌ្ឍខ្ពស់ជាមួយនិង GDP សម្រាប់ម្នាក់ៗ 51 000$ (ឆ្នាំ 2007) ជាប់ចំណាត់ថ្នាក់លេខពីរនៅអាស៊ីអាគ្នេយ៍បន្ទាប់ពីសិង្ហបុរី ។



# 2. ប្រព័ន្ធនយោបាយ

## 2.1. របៀបរៀបចំផ្នែករដ្ឋបាល

ក្រោយពេលទទួលបានឯករាជ្យពីអង់គ្លេសកាលពីថ្ងៃទី 01 មករា 1984មក ប្រទេសនេះមាននាមជាផ្លូវការថា "ព្រុយណេដារូស្សាឡាំ" មានន័យថា "ព្រុយណេលំនៅឋានសន្តិភាព" មានទីក្រុងបង់ដាសេរីបេកាវ៉ាន់ជារាជធានី ។ ព្រះរាជាណាចក្រដ៏តូចនេះចែកចេញជា 4មណ្ឌល គឺបេឡាយត៍ (Belait) ព្រុយណេ និងមូអារ៉ា (Brunei and Muara) តឹមប៊ូរ៉ុង (Temburong) និងទូតុង (Tutong) ។

## 2.2. របៀបរៀបចំផ្នែកនយោបាយ

"ព្រុយណេដារូស្សាឡាំ" ប្រកាន់យករបបប្រជាធិបតេយ្យផ្តាច់ការ ព្រោះថាគណបក្សនយោបាយស៊ឹងតែគ្មានសោះ ។ គេឃើញមានស្ថាប័នរដ្ឋសំខាន់ៗបីដូចគេឯងដែរ តែរបៀបរៀបចំខុសប្លែកពីប្រទេសដទៃ ពិសេសពីសហព័ន្ធម៉ាឡេស៊ីដែលប្រកាន់របបប្រជាធិបតេយ្យ និងសាសនាអ៊ីស្លាមដូចគ្នា ។

- អំណាចនីតិប្រតិបត្តិ ស្ថិតក្នុងព្រះហស្ថព្រះចៅស៊ុលតង់ ព្រះនាមហាស្សាណាល់ បូលគៀហ៍ (Hassanal Bolkiah) តាំងពីថ្ងៃទី 05 ខែតុលា ឆ្នាំ 1967 ។ ព្រះអង្គជាប្រមុខរដ្ឋផង ជាប្រមុខរដ្ឋាភិបាលផង ជារដ្ឋមន្ត្រីក្រសួងការពារជាតិផង និងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុផង ។ ក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រីចាត់តាំងនិងដឹកនាំដោយព្រះមហាក្សត្រលើបញ្ហាអនុវត្តច្បាប់ ។ ក្រុមប្រឹក្សាសាសនាក៏តែងតាំង ឡើងដោយព្រះមហាក្សត្រដែរ មាននាទីដោះស្រាយបញ្ហាសាសនា ។ ក្រុមប្រឹក្សាពិសេសផ្ទាល់របស់ព្រះមហាក្សត្រមួយទៀត បង្កើតឡើងសម្រាប់ដោះស្រាយបញ្ហាធម្មនុញ្ញ និងក្រុមប្រឹក្សាព្រះរាជសម្បត្តិមាននាទីជ្រើសរើសព្រះមហាក្សត្រស្នងរាជ្យបន្តក្នុងករណីចាំបាច់ណាមួយ ។ គេសង្កេតឃើញថា គ្មានការបោះឆ្នោតជ្រើសរើសព្រះមហាក្សត្រដូចនៅម៉ាឡេស៊ីទេ ព្រោះការឡើងសោយរាជសម្បត្តិប្រព្រឹត្តទៅតាមគំណរាជវង្ស ។
- អំណាចនីតិបញ្ញត្តិ ជារបស់ក្រុមប្រឹក្សាតាក់តែងច្បាប់ដែលមានព្រះមហាក្សត្រជាអ្នកតែងតាំងនិងដឹកនាំកិច្ចប្រជុំ កាលពីថ្ងៃទី 25 ខែ កញ្ញា ឆ្នាំ 2004 ជាលើកទីមួយក្នុងរយៈពេល 20ឆ្នាំកន្លងមក ដោយមានសមាជិកចូលរួមចំនួន 21រូប ។ វិសោធនកម្មរដ្ឋធម្មនុញ្ញមួយបានកំណត់ឱ្យក្រុមប្រឹក្សានេះមានអាសនៈទាំងអស់ចំនួន 45 ដែលក្នុងនោះចំនួន 15ត្រូវជ្រើសតាំងដោយការបោះឆ្នោត ។ តែកាលពីថ្ងៃទី 01 ខែកញ្ញា ឆ្នាំ 2005 ព្រះចៅស៊ុលតង់បានរំលាយក្រុមប្រឹក្សាដោយចាត់តាំងក្រុមប្រឹក្សាថ្មីជំនួសវិញដែលមានសមាជិកចំនួន 29រូប ។ ក្រុមប្រឹក្សាថ្មីនេះបានកោះប្រជុំកាលពីខែមីនា 2006 និងខែមីនា 2007 ។

• អំណាចតុលាការមានតុលាការជាន់ខ្ពស់ដែលមានប្រធានតុលាការ និងចៅក្រមដែលត្រូវធ្វើសច្ចាប្រណិធានចូលបម្រើការងារចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រសម្រាប់អាណត្តិ 3ឆ្នាំ គណៈកម្មាធិការនៃអង្គចៅក្រមរបស់ក្រុមប្រឹក្សាពិសេសមួយនៅទីក្រុងឡុងជាតុលាការចុងក្រោយបង្អស់សម្រាប់ឧទ្ធរណ៍រឿងក្តីក្តាំស៊ីវិល តុលាការសារិអា (Shariah Court) ទាក់ទិនទៅនឹងរឿងច្បាប់ទម្លាប់ក្នុងសាសនាអ៊ីស្លាម ។

*សម្គាល់ :* គណបក្សនយោបាយមានបីគឺ NDP PPKB និង PAKAR ជាគណបក្សតូចៗនិងត្រូវបានកំណត់ព្រំដែនសកម្មភាពទៀតផង ។ ចំណែកក្រុមដាក់សម្ពាធនយោបាយមិនមានឡើយ ។

និយាយរួម ក្នុងការគ្រប់គ្រងប្រទេស ឃើញថាព្រះចៅស៊ុលតង់មានតួនាទីធំធេងណាស់ អ្វីៗសព្វបែបយ៉ាងច្រើនតែសម្រេច និងតែងតាំងឡើងដោយព្រះអង្គ គ្មានការបោះឆ្នោតដោយសេរី និងប្រជាធិបតេយ្យសោះឡើយ ។

## 3. សេដ្ឋកិច្ចព្រុយណេ

ភាពសម្បូរភោគទ្រព្យធម្មជាតិ ពិសេសរ៉ែប្រេងកាត និងឧស្ម័នធម្មជាតិ ជាកត្តាផ្តល់ភាពងាយស្រួលដល់ប្រទេសព្រុយណេក្នុងកិច្ចអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិ ។

### 3.1. វិស័យកសិកម្ម

ផ្ទៃដី 80% គ្របដណ្តប់ដោយព្រៃឈើយ៉ាងក្រាស់ ដែលគេអាចជ្រៀតចូលជ្រៅបានតែតាមរយៈផ្លូវទឹកប៉ុណ្ណោះ ។ ទោះបីផ្ទៃដីដាំដុះមានទំហំតូច តែគេឃើញមានដំណាំស្មៀងយ៉ាងធំទូលាយ ។ នៅតាមជ្រលងភ្នំតូចៗ ជនជាតិអ៊ីបាន (Iban) ដុតព្រៃដាំដំណាំ បេះផ្លែឈើដើម្បីចិញ្ចឹមជីវិត ។ ក្នុងតំបន់ដែលមានរយៈកម្ពស់មធ្យម ជនជាតិមុយរុត (Murut) និងឌុយស៊ុន (Dusun) ដាំដំណាំចម្រុះ ។ នៅប្រេបតាមឆ្នេរ ជនជាតិកេដាយ៉ាន់ (Kedayan) និងជនជាតិម៉ាឡេធ្វើស្រែ ។ នៅជុំវិញក្រុង ជនជាតិចិននាំគ្នាដាំបន្លែគ្រប់មុខ ។



*កសិកម្មព្រុយណេ*

កសិកម្មព្រុយណេប្រើប្រាស់កម្លាំងពលកម្មអស់ 2.9% ចូលរួមបាន 0.9% នៃ GDP មានស្រូវ បន្លែ ផ្លែឈើ មាន់ ក្របី គោ ពពែ ស៊ុត ... ។

ក្នុងបំណងសម្រេចឱ្យបាននូវស្វ័យគ្រប់គ្រាន់ខាងចំណីអាហារ ប្រទេសព្រុយណេបានប្ដូរឈ្មោះស្រូវព្រុយណេដារូស្សាឡាំលេខ 1 ទៅជាស្រូវឡៃឡា (Laila Rice) ក្នុងពេលប្រារព្ធពិធីមួយស្ដីអំពី "ការដាំដុះដំណាំស្រូវសំដៅសម្រេចឱ្យបាននូវស្វ័យគ្រប់គ្រាន់ខាងផលិតកម្មស្រូវនៅព្រុយណេដារូស្សាឡាំ" កាលពីខែមេសា ឆ្នាំ 2009 នៅឯវាលស្រែវ៉ាសាន (Wasan) ។ នៅខែសីហា ឆ្នាំ 2009 រាជវង្សានុវង្សព្រុយណេ បានប្រមូលផលស្រូវយ៉ាងច្រើនជាលើកដំបូង ក្នុងការប៉ុនប៉ងលើកស្ទួយផលិតកម្មស្រូវក្នុងស្រុកជាច្រើនលើកច្រើនសាអស់រយៈពេលជាច្រើនឆ្នាំ គឺជាគោលដៅមួយដែលបានគ្រោងទុកប្រហែលជាកន្លះសតវត្សមកហើយ ។

## 3.2. វិស័យឧស្សាហកម្ម

ប្រភពធនធានថាមពលមួយភាគធំមាននៅតាមបាតសមុទ្រ ។ ផលិតផលប្រេងកាតមាន 219 300 ធុងក្នុងមួយថ្ងៃ (ឆ្នាំ 2006) ត្រូវជាជាង 80 លានធុង/ឆ្នាំនិងឧស្ម័នធម្មជាតិ 11.03 ពាន់លាន$m^3$/ឆ្នាំ (ឆ្នាំ 2005) ។ ភាគច្រើនលើសលុបនៃផលិតផលទាំងនេះត្រូវបាននាំចេញទៅលក់នៅក្រៅប្រទេស និងមួយភាគទៀតចម្រាញ់នៅក្នុងស្រុកដោយក្រុមហ៊ុន "ព្រុយណេសែលប៉េត្រូលៀម Brunei Shell Petroleum" ដែលក្នុងនោះទុនរដ្ឋាភិបាលមាន 50% ។ ផលិតកម្មអគ្គិសនីរបស់ព្រុយណេមាន 2.735 ពាន់លាន kWh (ឆ្នាំ 2005) ។ ឧស្សាហកម្មសំខាន់ៗមានប្រេង និងឧស្ម័ន ចម្រាញ់ប្រេង ឧស្ម័នរាវសំណល់" ។ អត្រាកំណើនផលិតកម្មឧស្សាហកម្មមាន 1.8% (ឆ្នាំ 2005) ។ វិស័យឧស្សាហកម្មព្រុយណេស្រូបទាញកម្លាំងពលកម្មបានដល់ទៅ 61.1% ស្មើនិង 71.6% នៃ GDP ។

## 3.3. វិស័យសេវាកម្ម

វិស័យនេះប្រើប្រាស់កម្លាំងពលកម្មអស់ 36% ស្មើនិង 27.5% នៃ GDP ឆ្នាំ 2005 ។

### ក. ពាណិជ្ជកម្ម

ការនាំចេញគិតជាតម្លៃមាន 6.757 ពាន់លានដុល្លារ (2006) ។ ទំនិញនាំចេញមានប្រេងកាតនៅឧស្ម័នធម្មជាតិ ផលិតផលប្រេងចម្រាញ់រួច សម្លៀកបំពាក់... ទៅកាន់ប្រទេសជប៉ុន (30.8%) ឥណ្ឌូណេស៊ី (23.6%) កូរ៉េខាងត្បូង (16.9%) អូស្ត្រាលី (12.2%) សហរដ្ឋអាមេរិក (5.2%) នៅឆ្នាំ 2007 ។

ការនាំចូលគិតជាតម្លៃមាន 2 ពាន់លានដុល្លារ (2006) ។ ទំនិញនាំចូលមានគ្រឿងម៉ាស៊ីន និងគ្រឿងបរិក្ខារសម្រាប់ការដឹកជញ្ជូនផលិតផលឧស្សាហកម្ម ផលិតផលអាហារ ផលិតផលគីមី មកពីរាជាណាចក្ររួម (46.3%) សិង្ហបុរី (19.4%) ម៉ាឡេស៊ី (11.2%) ... នៅឆ្នាំ 2007 ។

ជញ្ជីងពាណិជ្ជកម្មព្រុយណេទទួលបានផលចំណេញច្រើន ។ នេះជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជួយពង្រឹងសេដ្ឋកិច្ចនិងលើកស្ទួយជីវភាពប្រជារាស្ត្ររបស់ប្រទេសនេះ ។

## ខ. គមនាគមន៍ និងការដឹកជញ្ជូន

ប្រទេសព្រុយណេមានអាកាសយានដ្ឋាន 2 កន្លែង ទីមួយមានផ្លូវសម្រាប់ចុះឡើងប្រវែង 3047m ទីពីរមានផ្លូវប្រវែង 1523m ។ ផ្លូវថ្នល់មានប្រវែងសរុប 3650km ដែលក្នុងនោះ 2819km ក្រាលថ្មនិង 831Km មិនទាន់ក្រាលថ្ម ។ ផ្លូវទឹកមានប្រវែង 209km និងកងនាវាសមុទ្រមានកប៉ាល់ចំនួន 8 និងនាវាបរទេសមួយរបស់រាជាណាចក្ររួម ។ កំពង់ផែមានបីគឺ លុយមុត (Lumut) មូអារ៉ា (Muara) និងសឺរីអា (Seria) ។ បំពង់បង្ហូរឧស្ម័នមានប្រវែង 672km និងបំពង់បង្ហូរប្រេង 463km (ឆ្នាំ 2007) ។

ព្រះរាជាណាចក្រដ៏តូចមួយនេះអនុគ្រោះច្រើនដល់ការដឹកជញ្ជូនទាំងតាមផ្លូវអាកាស ផ្លូវសមុទ្រ និងផ្លូវថ្នល់ ។ អាកាសយានដ្ឋានអន្តរជាតិព្រុយណេជាផ្លូវចូលដ៏សំខាន់ទៅកាន់ប្រទេសនេះ ។ ក្រុមហ៊ុនរូយ៉ាល់ព្រុយណេអ៊ែរឡាញ (Royal Brunei Airlines) ជាជំនួយមួយក្នុងការដឹកជញ្ជូនរបស់ជាតិ ។ កំពង់សាឡង់ មូអារ៉ាបម្រើការដឹកជញ្ជូនបានយ៉ាងទៀងទាត់ទៅកាន់កោះឡាប៊ូអាន (ម៉ាឡេស៊ី) ។ នាវាធុនលឿនដឹកជញ្ជូនអ្នកដំណើរ និងទំនិញទៅកាន់តំបន់តឹមប៊ូរ៉ុង ។ ផ្លូវយន្តបថ ខូតុង-មូអារ៉ាជាផ្លូវដ៏សំខាន់មួយរត់កាត់ស៊ុលតាណាប្រ៊ុយណេ ។ បណ្ដាញផ្លូវថ្នល់ព្រុយណេទទួលបានការលូតលាស់ល្អ ។ កំពង់ផែសមុទ្រដ៏ធំមួយនៅមូអារ៉ាមានសកម្មភាពមមាញឹកខាងការនាំចេញផលិតផលប្រេង ។

## គ. វិស័យទេសចរណ៍

វិស័យទេសចរណ៍របស់ប្រទេសនេះក៏មានសារៈសំខាន់ណាស់ដែរ ដោយបានផ្ដល់ប្រាក់ចំណូលក្រាស់ក្រែលបង្គួរ ។

## ៣.៤. របៀបរៀបចំសេដ្ឋកិច្ច

សេដ្ឋកិច្ចស្ដុកស្ដម្ភនៃស៊ុលតាណាដ៏តូចមួយនេះមានលក្ខណៈចម្រុះសហគ្រាសក្នុងស្រុក និងបរទេសត្រឹមត្រូវតាមច្បាប់រដ្ឋ សម្របសម្រួលតាមទំនៀមទម្លាប់ និងគិតគូរដល់សុខុមាលភាពប្រជារាស្ត្រ ។ ផលិតកម្មប្រេងឆៅ និងឧស្ម័នធម្មជាតិស្មើនិងជិតពាក់កណ្ដាលនៃ GDP របស់ជាតិ ។ ចំណូលដែលបានមកពីវិនិយោគនៅឯនាយសមុទ្រយ៉ាងច្រើន ត្រូវបានបំពេញបន្ថែមទៅលើចំណូលដែលបានមកពីផលិតកម្មក្នុងស្រុក ។ រដ្ឋាភិបាលបានផ្ដត់ផ្ដង់លើផ្នែកសេវាសុខាភិបាលទាំងអស់ព្រមទាំងឧបត្ថម្ភស្រូវអង្ករ ផ្ទះសំបែងដល់ប្រជារាស្ត្រទៀតផង ។ មេដឹកនាំព្រុយណេបានយកចិត្តទុកដាក់លើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោកដូចកាលពីឆ្នាំ 2000 ព្រុយណេបានធ្វើជាអធិបតីនៃវេទិកា "សហប្រតិបត្តិការសេដ្ឋកិច្ចតំបន់អាស៊ីប៉ាស៊ីហ្វិក" សរសេរកាត់ថា APEC (Asian Pacific Economic Cooperation) ។ ផែនការអនាគតដែលបានលើកឡើងបានចែងពីការបង្កើនសមត្ថភាពពលកម្ម ការកាត់បន្ថយចំនួនអ្នកគ្មានការងារធ្វើ ការពង្រីកវិស័យទេសចរណ៍ និងកិច្ចការធនាគារ ។ ជាទូទៅ គឺធ្វើឱ្យមូលដ្ឋានសេដ្ឋកិច្ចទទួលបានការរីកចម្រើន ។

អាកាសចរណ៍ជាតិរួយ៉ាល់ព្រុយណេអ៊ែរឡាញ កំពុងតែសាកល្បងធ្វើឱ្យព្រុយណេក្លាយទៅជាស្នូលនៃការធ្វើដំណើររវាងទ្វីបអឺរ៉ុប និងប្រទេសអូស្ត្រាលី នូវែលសេឡង់ និងបម្រើការហោះហើរទៅកាន់ទីដៅមួយចំនួនធំទៀតនៃទ្វីបអាស៊ី ។ ព្រុយណេកំពុងបង្កើនការនាំចូលទំនិញពីប្រទេសដទៃទៀត ។

ស្តេចព្រុយណេជាមហាសេដ្ឋី មានប្រាក់ច្រើនជាងគេក្នុងពិភពលោក ។ ព្រះអង្គបានចំណាយមួយផ្នែកសម្រាប់ពង្រីកវិស័យយោធា ស្ថាបនាអាកាសយានដ្ឋាន កសាងវិហារអ៊ិស្លាម និងរាជវាំងដែលមានតម្លៃលើសពី 500 លានដុល្លារ ។ ផលិតផលក្នុងស្រុកសរុបរបស់ព្រុយណេមាន 11.471 ពាន់លានដុល្លារ(ឆ្នាំ 2009) ។ ជនបរទេសមាន ចិន ម៉ាឡេ ឥណ្ឌូណេស៊ីបានចូលមកធ្វើការនៅក្នុងប្រទេសព្រុយណេ ។ ពួកនេះមិនបានទទួលសិទ្ធិអប់រំ និងព្យាបាលដោយឥតគិតថ្លៃដូចជនជាតិម៉ាឡេ និងជនជាតិភាគតិចដែលជាពួកម្ចាស់ស្រុកនោះទេ ។ នេះជាការប្រកាន់ពូជសាសន៍ តែទោះជាយ៉ាងនេះក្តី គេឃើញថា ជនជាតិចិនបានដើរតួយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចព្រុយណេ ។

## ✍ ពាក្យគន្លឹះ:

- **ស៊ុលតង់** : គោរមងាររបស់ស្តេចនៅប្រទេសដែលកាន់សាសនាអ៊ិស្លាម ។
- **ស៊ុលតាណា** : ប្រទេសដែលគ្រប់គ្រងដោយព្រះចៅស៊ុលតង់ឬរាជ្យរបស់ព្រះចៅស៊ុលតង់ ។

## ? សំណួរ

1. តើប្រទេសព្រុយណេមានទីតាំងស្ថិតនៅត្រង់ណា ?
2. តើទម្រង់តាមភេទរបស់ប្រជាជនព្រុយណេ និងប្រជាជនកម្ពុជាខុសគ្នាដូចម្តេច ? ព្រោះអ្វី ?
3. តើតួនាទីព្រះមហាក្សត្រព្រុយណេ និងព្រះមហាក្សត្រកម្ពុជាយើងខុសគ្នាដូចម្តេចខ្លះ ?
4. ចូរពន្យល់អត្រាទំនាក់ទំនងភេទ :
   - 1.02 បុរស/ស្ត្រី (ព្រុយណេ)
   - 0.96 បុរស/ស្ត្រី (កម្ពុជា)
5. ចូរនិយាយអំពីសារៈសំខាន់កសិកម្ម ឧស្សាហកម្ម និងសេវាកម្មក្នុងសេដ្ឋកិច្ចព្រុយណេ ។
6. ក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច តើមេដឹកនាំព្រុយណេមានវិធានការអនុវត្តអ្វីខ្លះ ?
7. តើ APEC មានន័យពេញលេញជាភាសាខ្មែរដូចម្តេច ?
8. ហេតុអ្វីបានជាគេថា នៅក្នុងសង្គមព្រុយណេមានការប្រកាន់ពូជសាសន៍ ?
9. តើប្រទេសព្រុយណេនាំចេញ និងនាំចូលនូវផលិតផលអ្វីខ្លះ ?
10. តើជញ្ជីងពាណិជ្ជកម្មព្រុយណេស្ថិតក្នុងស្ថានភាពដូចម្តេច ?

# 5 ប្រទេសមីយ៉ាន់ម៉ា (ភូមា)

**ចប់មេរៀននេះ សិស្សអាច**

❑ ពណ៌នាពីស្ថានភាពប្រជាជន ប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចប្រទេសមីយ៉ាន់ម៉ា ។

នៅអាស៊ីអាគ្នេយ៍ដីគោក មីយ៉ាន់ម៉ាជាប្រទេសមួយដែលមានផ្ទៃដីធំជាងគេ មានព្រំប្រទល់ជាប់ប្រទេសបង់ក្លាដែស ឥណ្ឌា ចិន ឡាវ និងថៃ ស្ថិតនៅជាប់ឈូងសមុទ្របិងហ្គាល់ និងឈូងសមុទ្រម៉ាយ៉ាតាបង់ មានជួរភ្នំជាច្រើនសណ្ដូកតាមទិសជើង-ត្បូង ។ ចន្លោះជួរភ្នំទាំងនោះ គឺជាជ្រលងទន្លេសំខាន់ៗដូចជា ទន្លេអ៊ីយ៉ាវ៉ាទី សិងលិងសាល្វេង ... ។ ទំនាបឆ្នេរតូចៗភ្ជាប់មកដីសណ្ដទន្លេអ៊ីយ៉ាវ៉ាទីដ៏ធំធេង ។ ខ្ពង់រាបសានស្ថិតនៅប៉ែកខាងកើតប្រទេស ។ អាកាសធាតុត្រូពិចមូសុង ក្ដៅសើមនាំឱ្យសម្បូរព្រៃឈើ និងដំណាំច្រើនមុខ ។

ជាប្រទេសអតីតអាណានិគមនៃរាជាណាចក្ររួម បានទទួលឯករាជ្យកាលពី ថ្ងៃទី 4 មករា 1948 មកទល់បច្ចុប្បន្ន មីយ៉ាន់ម៉ានៅតែជាប្រទេសកំពុងអភិវឌ្ឍនៅឡើយ ហើយសេដ្ឋកិច្ចផ្អែកលើផលិតកម្មកសិកម្មជាធំ ។




*ផែនទីសណ្ឋានដីប្រទេសមីយ៉ាន់ម៉ា*

# 1. ស្ថានភាពប្រជាជន



ប្រជាជនមីយ៉ាន់ម៉ា

នៅថ្ងៃទី 18 មិថុនា 1989 ក្រុមប្រឹក្សារៀបចំសណ្តាប់ធ្នាប់ និងនីតិរដ្ឋ (SLORC) បានសម្រេចប្តូរឈ្មោះប្រទេសពីសហភាពភូមាមកជា "សហភាពមីយ៉ាន់ម៉ា" ។ ប្រទេសនេះមានប្រជាជនសរុបប្រហែល 48.14 លាននាក់នៅឆ្នាំ 2009 ដែលចម្រុះដោយជនជាតិជាច្រើនមាន ភូមា(68%) សាន(9%) ការ៉េន(7%) រ៉ាឃីន(4%) ចិន(3%) ឥណ្ឌា(2%) មន (2%) និងជនជាតិផ្សេងៗទៀត (5%) ។ ប្រជាជនមីយ៉ាន់ម៉ាភាគច្រើនជាពុទ្ធសាសនិក (89%) ។ សាសនិកដទៃទៀតមានគ្រិស្តសាសនិក(4%) ឥស្លាមសាសនិក(4%) អ្នកវិញ្ញាណនិយម(1%) និងផ្សេងៗ(2%) ។

## 1.1. ទម្រង់ប្រជាជន

### ក. ទម្រង់តាមអាយុ

តាមតួលេខខាងក្រោមឃើញថាប្រជាជនមីយ៉ាន់ម៉ាមានទម្រង់ក្មេងនៅឡើយ ពោលគឺចំនួនកុមារមានច្រើន(25.3%)ធៀបទៅនឹងប្រទេសកំពុងអភិវឌ្ឍមានត្រឹមតែជាង 10%ប៉ុណ្ណោះ ។ ប្រជាជនសកម្មមានច្រើនទាមទារឱ្យរដ្ឋាភិបាលបង្កើតការងារឱ្យបានគ្រប់គ្រាន់សំដៅកាត់បន្ថយអត្រាអ្នកអត់ការងារធ្វើ ដែលសព្វថ្ងៃមានដល់ទៅ 5% ។

- ក្រុមអាយុ 0-14 ឆ្នាំ : 25.3% (កុមារាមានចំនួន 6 193 263 នាក់ កុមារីមាន 5 990 462 នាក់) ។
- ក្រុមអាយុ 15-64 ឆ្នាំ : 69% (បុរសមានចំនួន 16 510 648 នាក់ ស្ត្រី 16 828 462 នាក់) ។
- ក្រុមអាយុ 65 ឆ្នាំឡើង : 5.4% (បុរសមានចំនួន 1 121 412 នាក់ ស្ត្រី 1 493 298 នាក់) ។

### ខ. ទម្រង់តាមភេទ

អត្រាភេទនៃប្រជាជនមីយ៉ាន់ម៉ាគិតជាទូទៅ បុរសមានចំនួនតិចជាងស្ត្រីប្រហាក់ប្រហែលគ្នានឹងនៅកម្ពុជាយើងដែរ ។ អត្រាភេទប្រជាជនមីយ៉ាន់ម៉ាមាន ៖

- ពេលកើតមានអត្រា 1.06 ទារក/ទារិកា មានន័យថាចំនួនទារកពេលកើតមានច្រើនជាងទារិកាគឺ 1.06 ទារកទល់នឹង 1 ទារិកា ឬទារក 106 នាក់ទល់នឹងទារិកា 100 នាក់
- ក្រោមអាយុ 15 ឆ្នាំ អត្រាភេទមាន 1.03 កុមារា កុមារី

- អាយុ 15-64ឆ្នាំ មាន 0.98បុរសស្ត្រី
- អាយុ 65 ឡើង មាន 0.75 បុរសស្ត្រី
- អត្រាភេទទូទៅមាន 0.98 បុរសស្ត្រី ។

### គ. សូចនាករផ្សេងៗទៀតមាន

- អត្រាជាតិប្រមាណ 1.697%
- អត្រាមរណប្រមាណ 0.914%
- អត្រាកំណើនធម្មជាតិ 0.783%
- អត្រាមរណប្រមាណនៃកុមារ 4.761%
- អត្រាលទ្ធភាពបង្កកំណើត 1.89 កូនស្ត្រី
- អត្រាអក្ខរភាព(គិតពីអាយុ 15ឆ្នាំឡើងដែលចេះអាន និងសរសេរ) 89.9% ដែលក្នុងនោះបុរស 93.9% ស្ត្រី 86.4%
- សង្ឃឹមរស់ពីកំណើត 63.39ឆ្នាំ(គិតជាទូទៅ)ដែលក្នុងនោះបុរស 61.17ឆ្នាំ ស្ត្រី 65.74ឆ្នាំ ។

តាមសូចនាករប្រជាសាស្ត្រទាំងនេះ គេអាចសន្និដ្ឋានបានថា សង្គម និងសេដ្ឋកិច្ចមីយ៉ាន់ម៉ាស្ថិតក្នុងស្ថានភាពអន់ថយនៅឡើយ ។ នេះជាបញ្ហាដែលរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ដោះស្រាយ ។

## 2. ប្រព័ន្ធនយោបាយ

ក្រោយឯករាជ្យពីឆ្នាំ 1948 ដល់ 1962 ប្រទេសភូមាជាសាធារណរដ្ឋប្រជាធិបតេយ្យមានឈ្មោះថា "សហភាពភូមា" ដែលមានលោក សៅ ស្វេ ថេក(Sao Shwe Thaik)ជាប្រធានាធិបតីទីមួយ និងលោក អ៊ូ នូ ជានាយករដ្ឋមន្ត្រី ។ ពេលនោះ ប្រទេសភូមាមានសភាពីរគឺសភាតំណាងរាស្ត្រ និងសភានៃប្រជាជាតិ មានគណបក្សច្រើនចូលរួមក្នុងការបោះឆ្នោតនៅឆ្នាំ 1951-1952ឆ្នាំ 1956 និងឆ្នាំ 1960 ។ របបប្រជាធិបតេយ្យត្រូវបានបញ្ចប់នៅឆ្នាំ 1962 បន្ទាប់ពីរដ្ឋប្រហារយោធារបស់លោកឧត្តមសេនីយ៍ នេវិនដែលបានដឹកនាំប្រទេសអស់ជិត 26ឆ្នាំ ដែលមានឈ្មោះថា "សហភាពសាធារណរដ្ឋសង្គមនិយមភូមា" ។ នៅឆ្នាំ 1989 SLORC បានប្តូរឈ្មោះប្រទេសទៅជា "សហភាពមីយ៉ាន់ម៉ា" ។ នៅឆ្នាំ 1997 SLORCមានឈ្មោះថ្មីថា ក្រុមប្រឹក្សាអភិវឌ្ឍន៍ និងសន្តិរដ្ឋ(SPDC) ។

## 2.1. របៀបរៀបចំផ្នែករដ្ឋបាល

ប្រទេសមីយ៉ាន់ម៉ា មានផ្ទៃដីសរុប 678 578Km$^2$ មានទីក្រុងរ៉ង់ហ្គូន(យ៉ាងគូន)ជារដ្ឋធានីចែកចេញជា 7 ភូមិភាគមាន អ៊ីយ៉ាវ៉ាឌី បាគូ ម៉ាកវេ ម៉ាន់ដាលេ សាកាំង តានីនថារី និងយ៉ាងគូន និង 7 រដ្ឋមាន រដ្ឋឈិន កាឈិន កាយ៉ាស កាយិន មន រ៉ាឃីន និងសាន ។

## 2.2. របៀបរៀបចំផ្នែកនយោបាយ

ពួកមេដឹកនាំមីយ៉ាន់ម៉ាបានបង្កើតឱ្យមានស្ថាប័នរដ្ឋចំនួនបី និងបើកឱ្យគណបក្សនយោបាយមួយចំនួនចូលរួមដូចប្រទេសជិតខាងមួយចំនួនដែរ ។

### ក. អំណាចនីតិប្រតិបត្តិ

ដឹកនាំដោយប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល :

- ប្រមុខរដ្ឋឬប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍ និងសន្តិរដ្ឋ SLORC លោកឧត្តមសេនីយ៍ ថាន់ស្វេ ជាប្រធានាធិបតីតាំងពីថ្ងៃ 23 មេសា 1992 ។
- ប្រមុខរដ្ឋាភិបាលឬនាយករដ្ឋមន្ត្រី លោកឧត្តមសេនីយ៍ ថេនសេន ឡើងកាន់អំណាចតាំងពីថ្ងៃ 24 តុលា 2007 ។ គណៈរដ្ឋមន្ត្រីត្រូវបានត្រួតពិនិត្យពីលើដោយ SPDC ។
- របបយោធាបានឡើងកាន់កាប់អំណាចរដ្ឋតាំងពីថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 1988 ក្នុងនាមក្រុមប្រឹក្សារៀបចំសណ្ដាប់ធ្នាប់ និងសន្តិរដ្ឋ SLORC ។

### ខ. អំណាចនីតិបញ្ញត្តិ

ជារបស់ "សភាប្រជាជន" មាន 485 អាសនៈ ជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយប្រជាជនអាយុ 18 ឆ្នាំឡើង សម្រាប់អាណត្តិ 4 ឆ្នាំ ។ ក្នុងការបោះឆ្នោតមួយ(ថ្ងៃ 27 ឧសភា 1990)ដែលរៀបចំឡើងដោយពួកអ្នកកាន់អំណាច គណបក្សប្រឆាំង NLD បានឈ្នះឆ្នោតយ៉ាងសន្ធឹកសន្ធាប់លើគណបក្សដទៃទៀត ដោយទទួលបាន 392 អាសនៈ តែរដ្ឋាភិបាលមិនព្រមប្រគល់អំណាច ។ សភានេះមិនត្រូវបានអនុញ្ញាតឱ្យកោះប្រជុំម្ដងណាសោះឡើយ ។ ថ្មីៗនេះ ពួកអ្នកកាន់អំណាចមីយ៉ាន់ម៉ាបានប្រកាសថានឹងរៀបចំការបោះឆ្នោតនៅឆ្នាំ 2010 ។

### គ. អំណាចតុលាការ

មួយផ្នែកតូចនៃប្រព័ន្ធច្បាប់សម័យអាណានិគមអង់គ្លេសត្រូវបានយកមកប្រើប្រាស់ក្នុងតុលាការតែមិនអាចធានាបាននូវការកាត់ក្ដីប្រកបដោយយុត្តិធម៌ជូនសាធារណជនបានឡើយ ដោយហេតុថាតុលាការគ្មានឯករាជ្យក្នុងការអនុវត្តការងាររបស់ខ្លួន ។

*សម្គាល់ :* គណបក្សសំខាន់ៗមានបី គឺគណបក្សប្រឆាំង NLD និង SNLD គណបក្សរដ្ឋាភិបាល NUD និងគណបក្សតូចៗមួយចំនួនទៀត ។

និយាយរួម បញ្ហាសិទ្ធិ និងប្រជាធិបតេយ្យនៅមីយ៉ាន់ម៉ានៅតែមានលក្ខណៈស្រួចស្រាល់នៅឡើយ នាំឆ្ពោះទៅរកការដាក់ទណ្ឌកម្មសេដ្ឋកិច្ចពីសំណាក់ប្រទេសមហាអំណាចប្រជាធិបតេយ្យសេរី មានសហរដ្ឋអាមេរិក សហភាពអឺរ៉ុប ទៅលើប្រទេសអតីតអាណានិគមមួយនេះ ។

## ៣. សេដ្ឋកិច្ចមីយ៉ាន់ម៉ា

មីយ៉ាន់ម៉ាជាប្រជាជាតិមួយដែលក្រីក្រជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍ ស្ថិតក្នុងភាពមិនរីកលូតលាស់អស់ពេលជាច្រើនទសវត្សរ៍មកហើយ ស្ថិតក្រោមការគ្រប់គ្រងមិនល្អ និងក្នុងភាពឯកោ ។ អត្រាកំណើន GDP ជាមធ្យមប្រចាំឆ្នាំមាន 2.9% គឺជាអត្រាកំណើនសេដ្ឋកិច្ចទាបជាងគេនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ។

### ៣.១. វិស័យកសិកម្ម



សេដ្ឋកិច្ចប្រទេសនេះផ្អែកលើកសិកម្មជាធំ ។ ស្រូវជាដំណាំសំខាន់សម្រាប់បំពេញតម្រូវការក្នុងស្រុក និងសម្រាប់ការនាំចេញ ។ ផ្ទៃដីដែលអាចភ្ជួររាស់ដាំដុះបានមាន 14.92% ផ្ទៃដីបញ្ចូលទឹកមាន 1 870 000 ហិកតា ។ កសិកម្មស្រូបយកកម្លាំងពលកម្មអស់ 70% ស្មើនឹង 42.4% នៃ GDP ។

ផលិតផលកសិកម្មភាគច្រើនគឺជាដំណាំស្រូវដាំដុះលើផ្ទៃដីប្រហែល 60% នៃផ្ទៃដីដាំដុះទាំងអស់របស់ប្រទេស ។ ដំណាំស្រូវបើគិតជាទម្ងន់ស្មើនឹង 97% នៃផលិតកម្មអាហារជាធញ្ញជាតិសរុប ។

ដោយមានកិច្ចសហការជាមួយវិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ IRRI ពូជស្រូវថ្មីៗចំនួន 52 ប្រភេទត្រូវបានបង្កើតឡើងនៅរវាងឆ្នាំ 1966-1997 ហើយបានជួយបង្កើតផលិតផលស្រូវដល់ 14 លានតោន(1987) និងដល់ 19 លានតោន(1996) ។ នៅឆ្នាំ 1988 ពូជស្រូវថ្មីៗត្រូវបានដាំដុះលើផ្ទៃដីពាក់កណ្តាលនៃដំណាំស្រូវរួមបញ្ចូលទាំងផ្ទៃដីបញ្ចូលទឹក 98%ផង ។

ដំណាំស្រូវមានដាំនៅលើទីដីខ្ពស់នៃតំបន់ភ្នំ និងខ្ពង់រាប ស្រូវឡើងទឹកនៅតាមដងទន្លេសំខាន់ៗ ស្រូវបញ្ចូលទឹកនៅត្រង់ភាគកណ្តាលនៃប្រទេស និងដំណាំកៅស៊ូនៅតាមតំបន់ឆ្នេរនៃឈូងសមុទ្រម៉ាយ៉ាតាបង់ ។ ក្នុងការចិញ្ចឹមសត្វ មីយ៉ាន់ម៉ាច្រើនចិញ្ចឹមសត្វពាហនៈ ។ ការនេសាទពុំសូវមានសកម្មភាពខ្លាំងក្លាទេ ។

ផលិតផលកសិកម្មសំខាន់ៗមានស្រូវ សណ្តែក ល្ង សណ្តែកដី អំពៅស្ករ ឈើមានតម្លៃ នេសាទ និងផលិតផលនេសាទ ។

## 3.2. វិស័យឧស្សាហកម្ម

មជ្ឈមណ្ឌលឧស្សាហកម្មធំជាងគេរបស់មីយ៉ាន់ម៉ាគឺរដ្ឋធានីយ៉ាងគូន(រ៉ង់ហ្គូន) ។ មជ្ឈមណ្ឌលឧស្សាហកម្មសំខាន់ៗដទៃទៀតមាននៅតាមទីក្រុងផ្សេងៗ ។ រោងចក្រអគ្គិសនីបានកើតឡើងយ៉ាងច្រើនដើម្បីបំពេញតម្រូវការក្នុងស្រុក ។ ក្រៅពីនេះ មានរោងចក្រតម្បាញ ស៊ីម៉ងត៍ គីមី ចម្រាញ់ប្រេងកាត ក្រដាស ស្ករ ស្លដែក កិនស្រូវ អារឈើ ភេសជ្ជៈ បារី ត្រីខកំប៉ុង ... ។ កម្មកររោងចក្រ 10%ជាកម្មកររដ្ឋ ។

ឧស្សាហកម្មមីយ៉ាន់ម៉ា ប្រើប្រាស់កម្លាំងពលកម្មអស់ត្រឹមតែ 7%ប៉ុណ្ណោះ ស្មើនឹង 18.9%នៃ GDP ។ ផលិតផលឧស្សាហកម្មមានអត្រាកំណើន 9% (2007) ។ ផលិតផលឧស្សាហកម្មមានផលិតផលកសិកម្មកែច្នៃ ឈើ និងផលិតផលឈើ ទង់ដែង សំណ តង់ស្តែន ដែក ស៊ីម៉ងត៍ គ្រឿងសម្ភារៈ ឱសថ ជី ឧស្ម័នធម្មជាតិ សម្លៀកបំពាក់ ថ្មើមថ្ម ត្បូងថ្មៃ ... ។ ផលិតកម្មអគ្គិសនីបាន 6.154 ពាន់លាន kwh ផលិតកម្មប្រេងបាន 18 000 ធុង/ថ្ងៃ ផលិតកម្មឧស្ម័នធម្មជាតិបាន 12.47 ពាន់លាន $m^3$ ។

មេដឹកនាំសហភាពមីយ៉ាន់ម៉ាពឹងផ្អែកលើការលក់ត្បូងមានតម្លៃដូចជា កណ្តៀង តជ និងថ្មើមថ្មសម្រាប់ទ្រទ្រង់របបគ្រប់គ្រងរបស់ពួកគេ ។ ត្បូងទទឹមផ្តល់ប្រាក់កម្រៃច្រើនបំផុត ។ 90%នៃត្បូងទទឹមពិភពលោកបានមកពីប្រទេសនេះដែលលក់បានថ្លៃខ្ពស់ដោយសារពណ៌ និងភាពសុទ្ធរបស់វា ។ ប្រទេសថៃបានទិញត្បូងថ្មៃពីប្រទេសនេះយ៉ាងច្រើន ។ "ជ្រលងត្បូងទទឹម" នៃតំបន់ភ្នំម៉ូកុករបស់ភូមាដែលស្ថិតនៅចម្ងាយ 200km ពីម៉ាន់ដាលេ ល្បីល្បាញដោយសារវត្តមាននៃទទឹមឈាមព្រាប និងកណ្តៀងពណ៌ខៀវដ៏មានតម្លៃ ។

## ៣.៣. វិស័យសេវាកម្ម

វិស័យនេះប្រើប្រាស់កម្លាំងពលកម្មចំនួន 23% ស្មើនិង 38.7% នៃ GDP រួមមានគមនាគមន៍និងការដឹកជញ្ជូនទេសចរណ៍ និងពាណិជ្ជកម្ម ។

### ក. គមនាគមន៍និងការដឹកជញ្ជូន

ផ្លូវដែកមីយ៉ាន់ម៉ាមានប្រវែងទាំងអស់ 3 955km ជារបស់រដ្ឋភ្ជាប់រដ្ឋធានីរ៉ង់ហ្គូន(យ៉ាងគូន)ទៅរដ្ឋនានា ។ មធ្យោបាយដឹកជញ្ជូនតាមផ្លូវគោកភាគច្រើនជារបស់ឯកជន ។ ប្រព័ន្ធផ្លូវថ្នល់មានប្រវែងសរុប 27 000km (ផ្លូវក្រាលកៅស៊ូ 3 200km មិនទាន់ក្រាលកៅស៊ូ 23 800km) ។ ប្រជាជនតិចតួចមានទោចក្រយានយន្តប្រើ ភាគច្រើនធ្វើដំណើរតាមផ្លូវទឹក និងរទេះគោ(សម្រាប់ប្រជាជនជនបទ) ។ ទំនិញភាគច្រើនដឹកជញ្ជូនតាមផ្លូវទឹក ពិសេសឈើម៉ៃសាក់(ចម្ងាយ 8 000km) ។ ទន្លេអ៊ីយ៉ាវ៉ាឌី ជាផ្លូវទឹកសំខាន់ជាងគេប្រើបានចម្ងាយ 1 500km ទន្លេសិងលិុងបានចម្ងាយ 400km បន្ទាប់មកមានទន្លេសាល្វេង និងស្ទឹងស៊ីតុង ។ ផ្លូវទឹកសរុបមានប្រវែង 12 800km ។ នាវាដំនួញមាន 27 គ្រឿងនិងនាវាបរទេស 3 (2 ជារបស់អាល្លឺម៉ង់ 1 ជារបស់ជប៉ុន) ឆ្នាំ 2008 ។ កំពង់ផែសំខាន់ៗមាន មូលម៉េន រ៉ង់ហ្គូន ស៊ីតវេ ។ ចំណែកផ្លូវអាកាស ប្រទេសនេះមានអាកាសយានដ្ឋានចំនួន 86 (ឆ្នាំ 2007) ក្នុងនោះមានចំនួន 25 ដែលមានផ្លូវយន្តហោះចាក់បេតុង និងចំនួន 61 ទៀតមិនទាន់ចាក់បេតុង ។ មីយ៉ាន់ម៉ាមានបំពង់បង្ហូរឧស្ម័នប្រវែង 2 700km និងបំពង់បង្ហូរប្រេង 558km ។

### ខ. ទេសចរណ៍និងពាណិជ្ជកម្ម

- រដ្ឋាភិបាលមីយ៉ាន់ម៉ាបានយកចិត្តទុកដាក់ជំរុញវិស័យទេសចរណ៍របស់ប្រទេសតាំងពីឆ្នាំ 1992 ។ តែទោះជាយ៉ាងណានេះក្តី គេឃើញមានអ្នកទេសចរចំនួនតិចជាង 75 000 នាក់បានចូលមកទស្សនាប្រទេសក្នុងមួយឆ្នាំៗ ។ ច្បាប់បានហាមប្រាមប្រជាជនមីយ៉ាន់ម៉ាមិនឱ្យប្រាស្រ័យទាក់ទងជាមួយជនបរទេសពីរឿងនយោបាយ បើពុំនោះសោតទេនឹងត្រូវទោសទណ្ឌដោយចាប់ដាក់ពន្ធនាគារ ហើយនៅឆ្នាំ 2001 គណៈកម្មការផ្សព្វផ្សាយព័ត៌មានផ្នែកទេសចរណ៍មីយ៉ាន់ម៉ាបានដាក់បញ្ជាទៅមន្ត្រីប្រចាំតំបន់ឱ្យការពារអ្នកទេសចរនិងកំណត់ព្រំដែននៃទំនាក់ទំនងមិនចាំបាច់រវាងជនបរទេស និងប្រជាជនភូមាសាមញ្ញ ។
- រដ្ឋបានគ្រប់គ្រងសេដ្ឋកិច្ចយ៉ាងតឹងរ៉ឹងបំផុត ដែលជាហេតុនាំឱ្យកើតមានទីផ្សារងងឹត ។

ការនាំចេញទំនិញទៅលក់នៅក្រៅប្រទេសគិតជាតម្លៃមាន 6.112 ពាន់លានដុល្លារ ។ តម្លៃលេខនេះមានកម្រិតទាបបំផុតដែលទាក់ទងទៅនឹងតម្លៃឈើ ត្បូង ណាកូខិច ស្រូវ និងទំនិញគេចពន្ធផ្សេងៗទៀតទៅកាន់ប្រទេសថៃ ចិន និងបង់ក្លាដែស ។

ទំនិញនាំចេញមានឧស្ម័នធម្មជាតិ ផលិតផលឈើ សណ្ដែក ត្រី ស្រូវ សម្លៀកបំពាក់ ថ្មើមថ្មនិងត្បូងថ្លៃ ។ ប្រទេសដៃគូក្នុងការនាំចេញមានថៃ(44%) ឥណ្ឌា(14.4%) ចិន(7%) ជប៉ុន(5.6%) ។

ការនាំចូលពីបរទេសគិតជាតម្លៃមាន 2.942 ពាន់លានដុល្លារ ។ ដូចគ្នាដែរ តម្លៃនេះទាបណាស់ដោយសារការនាំទំនិញចូលគេចពន្ធច្រើនពេកពីប្រទេសថៃ ចិន ម៉ាឡេស៊ី និងឥណ្ឌា ។

ទំនិញនាំចូលមាន កំណាត់សំពត់ ផលិតផលប្រេង ជី ប្លាស្ទិច គ្រឿងយន្ត បរិក្ខារដឹកជញ្ជូន ស៊ីម៉ងត៍ គ្រឿងសំណង់ ប្រេងឆៅ ផលិតអាហារ ប្រេងឆា ។ ប្រទេសដៃគូ ក្នុងការនាំទំនិញចូលមាន ចិន(35.9%) ថៃ(20.4%) សិង្ហបុរី(16.5%) ម៉ាឡេស៊ី(4.5%)នៅឆ្នាំ 2007 ។

សព្វថ្ងៃ ប្រទេសនេះបានចូលជាសមាជិកអាស៊ាន(23 មិថុនា 1997)ក្នុងន័យចូលរួមធ្វើសហប្រតិបត្តិការក្នុងតំបន់ ។

## ✍ ពាក្យគន្លឹះ

- **ទារក** : កូនក្មេងទើបកើតភេទប្រុស
- **ទារិកា** : កូនក្មេងទើបកើតជាភេទស្រី
- **ពន្ធនាគារ** : មន្ទីរឃុំឃាំងអ្នកទោសឬគុក
- **អ្នកវិញ្ញាណនិយម** : អ្នកមានជំនឿថាមនុស្សស្លាប់ទៅវិញ្ញាណឬព្រលឹងវិលមកចាប់កំណើតវិញ ។

## ? សំណួរ

1. តើ "សហភាពមីយ៉ាន់ម៉ា" ស្ថិតនៅត្រង់ណា ? មានព្រំប្រទល់ជាប់ប្រទេសណាខ្លះ ? ជាប់និងឈូងសមុទ្រណាខ្លះ ? មានសណ្ឋានដីដូចម្ដេច ? មានទន្លេសំខាន់ៗអ្វីខ្លះ ?
2. តើប្រទេសភូមាស្ថិតនៅក្រោមអាណានិគមប្រទេសណា ? បានទទួលឯករាជ្យនៅឆ្នាំណា ? ក្រោយឯករាជ្យប្រទេសនេះមានការវិវត្តនយោបាយដូចម្ដេចខ្លះ ?
3. តើគណបក្សនយោបាយសំខាន់ៗនៅមីយ៉ាន់ម៉ាមានឈ្មោះអ្វីខ្លះ ? តើគណបក្សណាដែលឈ្នះឆ្នោតនៅឆ្នាំ 1990 ? ក្រោយការបោះឆ្នោត តើមានហេតុការណ៍អ្វីកើតឡើង ?
4. ចូរនិយាយអំពីសារៈសំខាន់កសិកម្មក្នុងសេដ្ឋកិច្ចមីយ៉ាន់ម៉ា ។
5. ចូរនិយាយអំពីសារៈសំខាន់ឧស្សាហកម្មក្នុងសេដ្ឋកិច្ចមីយ៉ាន់ម៉ា ។
6. ចូរនិយាយអំពីសារៈសំខាន់សេវាកម្មក្នុងសេដ្ឋកិច្ចមីយ៉ាន់ម៉ា ។

## សំណួរបញ្ចប់ជំពូកទី២

I. ចូរគូសសញ្ញា ✓ មុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់

1. នយោបាយ "កូនទោល" ត្រូវបានអនុវត្តនៅ ៖

☐ ក. ប្រទេសឥណ្ឌា ☐ ខ. ម៉ាឡេស៊ី

☐ គ. ប្រទេសភូមា ☐ ឃ. ចិន ។

2. រូបិយវត្ថុ(លុយ)របស់ប្រទេសឥណ្ឌាមានឈ្មោះថា ៖

☐ ក. ប្រាក់យេន ☐ ខ. ប្រាក់បាត

☐ គ. ប្រាក់រូពី ☐ ឃ. ប្រាក់ក្យាត ។

II. ចូរផ្គូផ្គងផ្នែក A និង B រួចសរសេរចម្លើយត្រូវក្នុងផ្នែក C

| A (ឈ្មោះប្រទេស) | B (ឈ្មោះរបបនយោបាយ) | C ចម្លើយ |
|---|---|---|
| 1. ប្រទេសចិន | ក. សាធារណរដ្ឋសេរី | 1. → |
| 2. ប្រទេសម៉ាឡេស៊ី | ខ. សាធារណរដ្ឋសង្គមនិយម | 2. → |
| 3. ប្រទេសមីយ៉ាន់ម៉ា | គ. រាជាធិបតេយ្យអាស្រ័យសភា | 3. → |
| | ឃ. សាធារណរដ្ឋយោធានិយម | |

III. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. ការផ្លាស់ប្តូរមួយយ៉ាងរហ័សក្នុងវិស័យកសិកម្ម ដែលកត់សម្គាល់ដោយកំណើនដ៏សំខាន់ខាងផលិតផលហៅថា ........................ ។

2. ដោយសារវឌ្ឍនភាពសេដ្ឋកិច្ច ប្រទេសម៉ាឡេស៊ីសព្វថ្ងៃមានឈ្មោះថាជា ........................ ដូចឥណ្ឌូណេស៊ី និងហ្វីលីពីនដែរ ។

IV. សំណួរត្រិះរិះ

1. ក្នុងការធ្វើទំនើបកម្មសេដ្ឋកិច្ច តើមេដឹកនាំចិនផ្តល់អាទិភាពទៅលើផ្នែកអ្វីខ្លះ ?
2. តើប្រទេសឥណ្ឌាជួបប្រទះនិងបញ្ហាសំខាន់ៗអ្វីខ្លះ ?
3. តើនយោបាយសេដ្ឋកិច្ចថ្មីរបស់ម៉ាឡេស៊ីមានគោលដៅធំៗអ្វីខ្លះ ?
4. ចូរនិយាយអំពីសារៈសំខាន់កសិកម្ម ឧស្សាហកម្ម និងសេវាកម្មក្នុងសេដ្ឋកិច្ចព្រុយណេ ។
5. ចូរប្រៀបធៀបតួនាទីព្រះមហាក្សត្រខ្មែរ និងព្រះចៅស៊ុលតង់ព្រុយណេ ។
6. ចូរនិយាយអំពីរបៀបជ្រើសរើសព្រះមហាក្សត្រឱ្យឡើងសោយរាជសម្បត្តិនៅកម្ពុជា និងនៅម៉ាឡេស៊ី ។